## រាជបណ្ឌិត្យសភាកម្ពុជា

## វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

# កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរី កម្ពុជា-ចិន

## បញ្ហាប្រឈម សក្តានុពលនិងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា










រាជបណ្ឌិត្យសភាកម្ពុជា

ខែធ្នូ ២០២១

# កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន

## បញ្ហាប្រឈម សក្តានុពលនិងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា


### អត្ថបទស្រាវជ្រាវដោយ៖

១. លោក លី តុង ២. បណ្ឌិត ផុន កសិកា ៣. បណ្ឌិត តូច សុធារី


### សមាសភាពគម្រោងស្រាវជ្រាវ

| ល.រ | គោត្តនាមនិងនាម | តួនាទីក្នុងគម្រោង |
|---|---|---|
| ១ | បណ្ឌិត **ផុន កសិកា** | ប្រធានគម្រោង |
| ២ | លោក **លី តុង** | អនុប្រធានគម្រោង |
| ៣ | បណ្ឌិត **តូច សុធារី** | អនុប្រធានគម្រោង |
| ៤ | បណ្ឌិត **ទុយ យូឃីម** | សមាជិកគម្រោង |
| ៥ | បណ្ឌិត **ឈឿន សារ៉ន** | សមាជិកគម្រោង |
| ៦ | លោក **ឃិន យ៉ង់** | សមាជិកគម្រោង |
| ៧ | លោក **ឃិន ពោ** | សមាជិកគម្រោង |
| ៨ | លោក **សាន ចេង** | សមាជិកគម្រោង |
| សរុបសមាជិកគម្រោង៖ ៨នាក់ | | |

# អំពីរាជបណ្ឌិត្យសភាកម្ពុជា

រាជបណ្ឌិត្យសភាកម្ពុជាគឺជាស្ថាប័នស្រាវជ្រាវធំបំផុតមួយរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានបេសកកម្មសិក្សាស្រាវជ្រាវ ទាំងក្នុងក្របខណ្ឌសិក្សាអប់រំ (Academic Research) និងក្របខណ្ឌស្រាវជ្រាវគោលនយោបាយ (Policy Research) ទៅលើមុខជំនាញឯកទេស និងបញ្ហានានាដែលពាក់ព័ន្ធទៅនឹងវិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រធម្មជាតិជាដើម។ ក្រៅពីបេសកកម្មស្រាវជ្រាវ រាជបណ្ឌិត្យសភាកម្ពុជាក៏បានដើរតួយ៉ាងសកម្ម ក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើគ្រប់មុខជំនាញឯកទេស ចាប់ពីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ រហូតដល់ថ្នាក់បណ្ឌិត ដោយផ្តោតជាសំខាន់លើការសិក្សាស្រាវជ្រាវ ដើម្បីពង្រឹងការអភិវឌ្ឍប្រទេសជាតិ ដោយផ្អែកលើចំណេះដឹង ជំនាញប្រកបដោយចក្ខុវិស័យវែងឆ្ងាយ។

## ចក្ខុវិស័យ

រាជបណ្ឌិត្យសភាកម្ពុជា នឹងប្រែក្លាយខ្លួនទៅជាស្ថាប័នស្រាវជ្រាវជាន់ខ្ពស់ និងឈានមុខគេរបស់ប្រទេសកម្ពុជា ដើម្បីអភិវឌ្ឍកម្លាំងបញ្ញាញាណសម្រាប់ជាតិ ពង្រឹង និងពង្រីកការសិក្សាស្រាវជ្រាវលើគ្រប់វិស័យ និងជំនាញឯកទេស។

## បេសកកម្ម

ផ្អែកទៅលើក្របខណ្ឌតួនាទី និងចក្ខុវិស័យក្នុងការចូលរួមអភិវឌ្ឍប្រទេស រាជបណ្ឌិត្យសភាកម្ពុជាមានបេសកកម្មដូចខាងក្រោម៖

- គ្រប់គ្រង និងពង្រីកការស្រាវជ្រាវខេមរវិទ្យា និងគ្រប់មុខជំនាញឯកទេស
- រៀបចំវេទិកាស្រាវជ្រាវបែបវិទ្យាសាស្ត្រទាំងថ្នាក់ជាតិ និងអន្តរជាតិដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់គ្រប់មជ្ឈដ្ឋាន
- បោះពុម្ពឯកសារ ស្នាដៃស្រាវជ្រាវ និងបកគំហើញវិទ្យាសាស្ត្រជាភាសាជាតិ និងភាសាបរទេសឱ្យបានទូលំទូលាយដល់មហាជននៅក្នុងប្រទេស ក៏ដូចជាផ្សព្វផ្សាយខេមរវិទ្យានៅលើវេទិកាអន្តរជាតិ

- ប្រមូល និងតម្កល់ឯកសារស្រាវជ្រាវអំពីប្រទេសកម្ពុជាពីបណ្តាប្រទេសនានានៅក្នុងតំបន់ និងលើពិភពលោក
- ពិនិត្យ និងវាយតម្លៃស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រដើម្បីផ្តល់ជាគ្រឿងឥស្សរយសដល់ម្ចាស់ស្នាដៃទៅតាមសម្មិទ្ធផលជាក់ស្តែង

## អាសយដ្ឋានទំនាក់ទំនង៖

- មហាវិថីសហព័ន្ធរុស្សី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- ទូរសព្ទ៖ (+៨៥៥) ២៣ ៨៩០ ១៨០
- គេហទំព័រ៖ www.rac.gov.kh
- អ៊ីមែល៖ info@rac.gov.kh
- ប្រអប់សំបុត្រ៖ P.O. Box 531 Phnom Penh, Cambodia

# មាតិកាអត្ថបទ

**អំពីរាជបណ្ឌិត្យសភាកម្ពុជា**............................................2

**មាតិកាអត្ថបទ**............................................4

**បញ្ជីតារាង**............................................7

**ជំពូក ១៖ សេចក្តីផ្តើម**............................................8

១.១. ទិដ្ឋភាពទូទៅ............................................8

១.១.១. អ្វីជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី............................................9

១.១.២. អំពីជញ្ជីងពាណិជ្ជកម្មកម្ពុជា............................................11

១.២. ដំណើរការនៃស្រាវជ្រាវ............................................14

១.២.១. គោលបំណងនិងវិសាលភាព............................................14

១.២.២. បញ្ហាប្រឈមក្នុងការស្រាវជ្រាវ............................................15

**ជំពូក ២៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន**............................................16

២.១. អំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន............................................16

២.១.១. សារតានៃកិច្ចព្រមព្រៀង............................................16

២.១.២. វិសាលភាពនិងអត្ថប្រយោជន៍............................................17

២.២. មតិនានាជុំវិញកិច្ចព្រមព្រៀង............................................21

**ជំពូក ៣៖ បញ្ហាប្រឈមសម្រាប់កម្ពុជា**............................................25

៣.១. បញ្ហាប្រឈមក្នុងវិស័យផលិតកម្ម............................................25

៣.១.១. បញ្ហាប្រឈមក្នុងវិស័យកសិកម្ម............................................26

៣.១.២. បញ្ហាប្រឈមក្នុងវិស័យឧស្សាហកម្ម ........ 33

៣.២. បញ្ហាប្រឈមក្នុងវិស័យសេវាកម្ម ........ 35

៣.៣. បញ្ហាប្រឈមក្នុងវិស័យដឹកជញ្ជូន ........ 40

៣.៤. បញ្ហាប្រឈមក្នុងបរិស្ថានវិនិយោគ ........ 41

**ជំពូក ៤៖ សក្តានុពលនិងឱកាសសម្រាប់កម្ពុជា ........ 45**

៤.១. សក្តានុពលរបស់កម្ពុជា ........ 46

៤.១.១. សក្តានុពលក្នុងការវិនិយោគ ........ 46

៤.១.២. សក្តានុពលក្នុងវិស័យផលិតកម្ម ........ 48

៤.២. ឱកាសសម្រាប់កម្ពុជា ........ 50

៤.២.១. កិច្ចព្រមព្រៀងមានស្រាប់ ........ 50

៤.២.២. កត្តាទំនាក់ទំនងជាមួយប្រទេសចិន ........ 50

៤.២.៣. តម្រូវការរបស់ប្រទេសចិន ........ 51

**ជំពូក ៥៖ សន្និដ្ឋាននិងអនុសាសន៍ ........ 52**

៥.១. សេចក្តីសន្និដ្ឋាន ........ 52

៥.២. អនុសាសន៍សម្រាប់កម្ពុជា ........ 53

៥.២.១. ពង្រឹងកិច្ចសហការរដ្ឋនិងឯកជន ........ 53

៥.២.២. ធ្វើទំនើបកម្មវិស័យកសិកម្ម ........ 55

៥.២.៣. សិក្សាពីតម្រូវការរបស់ប្រទេសចិន ........ 60

៥.២.៤. វិនិយោគលើផលិតកម្មវត្ថុធាតុដើម ........ 60

៥.២.៥. ធ្វើឱ្យប្រសើរនូវបរិស្ថានវិនិយោគ ........ 61

៥.២.៦. លើកទឹកចិត្តសហគ្រាសតូចនិងមធ្យម ........ 61

៥.២.៧. ពង្រឹងនិងវិនិយោគវិស័យដឹកជញ្ជូន ........ 62
៥.២.៨. បង្កើតឱ្យមានចង្កោមឧស្សាហកម្ម ........ 63
៥.២.៩. ពង្រឹងការអភិវឌ្ឍធនធានមនុស្ស ........ 63

**ឯកសារយោង** ........ 65

**ឧបសម្ព័ន្ធ** ........ 70

# បញ្ជីតារាង

តារាងទី 1៖ ការនាំចេញរបស់កម្ពុជាឆ្នាំ២០១៩ ............ 12
តារាងទី 2៖ ទំហំការវិនិយោគនៅកម្ពុជា (គិតជាដុល្លាសហរដ្ឋអាមេរិក) ............ 47

# ជំពូក ១
# សេចក្តីផ្តើម

## ១.១. ទិដ្ឋភាពទូទៅ

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចជាតិខ្ពស់គួរឱ្យកត់សម្គាល់។ បើតាមទិន្នន័យរបស់រាជរដ្ឋាភិបាល ធនាគារពិភពលោក ក៏ដូចជាធនាគារអភិវឌ្ឍអាស៊ីបានបង្ហាញថា មុនពេលកើតមាននូវវិបត្តិជំងឺកូវីដ-១៩ ប្រទេសកម្ពុជាទទួលបានអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំប្រមាណ៧.៧% ក្នុងចន្លោះឆ្នាំ១៩៩៥-២០១៨។ អត្រាកំណើនប្រចាំឆ្នាំដ៏ខ្ពស់នេះ បានធ្វើឱ្យកម្ពុជាក្លាយទៅជាប្រទេសមួយដែលមានកំណើនសេដ្ឋកិច្ចលឿនជាងគេក្នុងពិភពលោក។ ពិតប្រាកដណាស់ ការរីកចម្រើននៃសេដ្ឋកិច្ច និងសង្គមកម្ពុជា មានការចូលរួមពីវិស័យជាច្រើនដូចជា វិស័យឧស្សាហកម្មប្រមាណ ៣៨,៣%, វិស័យសេវាកម្មប្រមាណ ៣៨,១%, និងវិស័យកសិកម្មប្រមាណ ១៦% (ហ៊ុន សិរីវឌ្ឍន៍, ២០២០)។ ជាក់ស្តែង វិស័យពាណិជ្ជកម្មរបស់កម្ពុជាបានដើរតួយ៉ាងសំខាន់ក្នុងការជំរុញនូវការអភិវឌ្ឍក្នុងវិស័យទាំងនេះ ជាពិសេសពាណិជ្ជកម្មផលិតផលឧស្សាហកម្ម និងកសិកម្ម។ ដើម្បីបន្តពង្រឹង និងជំរុញកំណើននៃវិស័យពាណិជ្ជកម្មរបស់ខ្លួន កម្ពុជាបានខិតខំពង្រីកនូវវិសាលភាពនៃពាណិជ្ជកម្មអន្តរជាតិរបស់ខ្លួនជាមួយប្រទេសជិតខាង ក្នុងតំបន់ ក៏ដូចជាពិភពលោកផងដែរ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយប្រទេសជាដៃគូ បានប្រព្រឹត្តទៅជាបន្តបន្ទាប់ទាំងក្នុងក្របខណ្ឌទ្វេភាគី និងក្រមខណ្ឌតំបន់អាស៊ានទាំងមូល។ កាលពីពេលថ្មីៗនេះ កម្ពុជាបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយនឹងប្រទេសចិន ដែលកិច្ចព្រមព្រៀងនេះ មានគោលបំណងក្នុងការពង្រីកនូវជញ្ជីងពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងប្រទេសចិនឱ្យមានវិសាលភាពកាន់តែធំជាងមុនពីមួយឆ្នាំទៅមួយឆ្នាំ។ ក្រៅពីប្រទេសចិន កម្ពុជាក៏មានបំណងបន្តការពិភាក្សា និងការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយប្រទេសជាច្រើនផ្សេងទៀតដូចជា សហរដ្ឋអាមេរិក ជប៉ុន អាឡឺម៉ង់ ស្វីស កូរ៉េខាងជើង កូរ៉េខាងត្បូង ឥណ្ឌា និងប្រទេសនានាផ្សេងទៀតក្នុងតំបន់អាស៊ានផងដែរ (Moc, 2015 as cited in Open and Development Cambodia , 2015)។

បន្ថែមពីលើការពង្រីកនូវវិសាលភាពនៃពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួន កម្ពុជាក៏បានខិតខំផងដែរក្នុងការបង្កើតនូវបរិយាកាសវិនិយោគ ក៏ដូចជាអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិនិយោគក្នុងប្រទេសឱ្យកាន់តែប្រសើរជាងមុន ដើម្បីទាក់ទាញអ្នកវិនិយោគទុនទាំងក្នុងស្រុក និងក្រៅស្រុក។ ជាមួយគ្នានេះ ក្រៅពីទំហំពាណិជ្ជកម្មនាំចេញដែលធំជាងមុនជាលំដាប់ (១៦ប៊ីលានដុល្លារ ក្នុងឆ្នាំ២០២០) យើងក៏សង្កេតឃើញថា ទំហំនៃការវិនិយោគនៅកម្ពុជាគិតត្រឹមឆ្នាំ២០១៩ ក៏មានការកើនឡើងផងដែរ ដោយមានវិសាលភាពរហូតដល់ ៨៥,៨៨ប៊ីលានដុល្លារសហរដ្ឋអាមេរិក។

## ១.១.១. អ្វីជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី គឺជាទំនាក់ទំនងផ្នែកពាណិជ្ជកម្មរវាងប្រទេសពីរ រដ្ឋពីរ ឬច្រើនក្នុងគោលដៅកាត់បន្ថយនូវរនាំង ឬឧបសគ្គនានាដែលរារាំងដល់ការនាំចូល និងនាំចេញទំនិញរវាងប្រទេសដែលជាដៃគូពាណិជ្ជកម្មរបស់ខ្លួន។ ផ្អែកលើគោលនយោបាយពាណិជ្ជកម្មសេរី ប្រទេសដែលមានទំនាក់ទំនងពាណិជ្ជកម្មសេរីជាមួយគ្នា អាចធ្វើការទិញ ឬលក់នូវទំនិញ ផលិតផលឧស្សាហកម្ម កសិកម្ម សិប្បកម្ម ឬសេវាកម្មនានាជាមួយគ្នាដោយមានការកាត់បន្ថយនូវឧបសគ្គមួយចំនួនដែលធ្វើឱ្យរាំងស្ទះដល់ការនាំចេញដូចជា ការទទួលបាននូវការលើកលែងពន្ធគយ ឬមានការបង់ពន្ធតិចតួចទៅតាមលក្ខន្តិកៈនៃកិច្ចព្រមព្រៀងរបស់ប្រទេសដែលជាដៃគូ (Adam Barone, 2020)។ ជាគោលការណ៍ ការធ្វើពាណិជ្ជកម្មសេរីអន្តរជាតិរវាងប្រទេសនិងប្រទេស មិនខុសគ្នាអ្វីអំពីការធ្វើពាណិជ្ជកម្មរវាងប្រទេសភូមិផងរបងជាមួយគ្នា រវាងខេត្តនិងខេត្ត ឬតំបន់និងតំបន់នោះឡើយ គ្រាន់តែទម្រង់នៃការផ្លាស់ប្តូរទំនិញរវាងគ្នានឹងគ្នាមានលក្ខណៈធំទូលាយជាង និងលក្ខខណ្ឌគតិយុត្តិ បច្ចេកទេសអាចមានភាពស្មុគស្មាញច្រើនបន្តិច។

អត្ថប្រយោជន៍ចម្បងនៃការធ្វើពាណិជ្ជកម្មសេរីគឺថា អ្នកវិនិយោគទុន ឬផលិតករក្នុងប្រទេសមួយនឹងព្យាយាមផលិតនូវទំនិញគ្រប់ប្រភេទដែលជាតម្រូវការរបស់ប្រទេសជាដៃគូរបស់ខ្លួន ដោយការប្រើធនធានក្នុងស្រុកដើម្បីនាំយកទៅលក់។ ជាមួយគ្នានេះ ប្រទេស ឬរដ្ឋដែលជាដៃគូពាណិជ្ជកម្ម ក៏នឹងប្រឹងប្រែងធ្វើការផលិត ឬនាំចូលមកវិញនូវរាល់ប្រភេទទំនិញ និងផលិតផលដែលកម្រ ឬជាតម្រូវការនៅក្នុងប្រទេសរបស់ខ្លួនវិញផងដែរ។ ការផ្លាស់ប្តូរទំនិញបែបនេះ នឹងធ្វើឱ្យមាននានាភាព និងការប្រកួតប្រជែងទាំងលើប្រភេទទំនិញ តម្លៃ និងគុណភាព ដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់អតិថិជន

នៅក្នុងប្រទេសសាម៉ីផងខ្លួន។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី នឹងផ្តល់ឱ្យប្រទេសដែលជាដៃគូនូវការប្រកួតប្រជែងដែលល្អប្រសើរជាងមុន បើធៀបជាមួយនឹងផលិតផលដូចគ្នាដែលនាំចូលពីប្រទេសផ្សេងដែលពុំមែនជាដៃគូពាណិជ្ជកម្មសេរី។

បើទោះបីជាការធ្វើពាណិជ្ជកម្មសេរី មើលទៅហាក់ដូចជាផ្តល់នូវអត្ថប្រយោជន៍ច្រើនក៏ពិតមែន ក៏ប៉ុន្តែ យើងក៏មិនត្រូវមើលរំលងនូវគុណវិបត្តិរបស់វាផងដែរ។ អ្នកសេដ្ឋកិច្ចវិទូឈ្មោះ David Ricardo បានធ្វើការបកស្រាយនូវទស្សនៈរបស់គាត់ ស្តីអំពីគុណវិបត្តិនៃពាណិជ្ជកម្មសេរីនេះក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើង "*On the Principles of Political Economy and Taxation*" ថា ការធ្វើពាណិជ្ជកម្មសេរីបានបង្កើននូវនានាភាពនៃមុខទំនិញ ព្រមទាំងធ្វើឱ្យទំនិញដែលមាននៅប្រទេសមួយមានការធ្លាក់ថ្លៃ[1] ស្របពេលដែលប្រទេសនោះបាននឹងកំពុងប្រើប្រាស់នូវធនធានរបស់ខ្លួនទាំងចំណេះជំនាញ ធនធានមនុស្ស និងវត្ថុធាតុដើមជាដើមស្ទើរតែខ្សោះខ្លួនទៅហើយ។ ជាមួយនឹងគំនិតនេះ យើងអាចទាញសេចក្តីសន្និដ្ឋានបានថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី បានផ្តល់អត្ថប្រយោជន៍ច្រើនចំពោះការនាំចេញ តាមរយៈការទទួលបាននូវការអនុគ្រោះនានា ក៏ប៉ុន្តែវាក៏បានធ្វើឱ្យទំនិញលើទីផ្សារក្នុងស្រុករបស់ខ្លួនមានការធ្លាក់ថ្លៃផងដែរ តាមរយៈការហូរចូលនៃទំនិញនានាពីប្រទេសដែលជាដៃគូ និងដែលមានតម្លៃទាបជាងផលិតផលក្នុងស្រុក។ ការធ្លាក់ថ្លៃទំនិញក្នុងស្រុកក្នុងរូបភាពបែបនេះ នឹងនាំមកនូវគុណវិបត្តិសម្រាប់ផលិតករ អ្នកវិនិយោគ ក៏ដូចជានិយោជកដែលបម្រើការងារក្នុងផលិតកម្មដែលបំពេញទីផ្សារក្នុងស្រុក។ ដោយសារតែការប្រកួតប្រជែងកាន់តែច្រើន អាចនឹងធ្វើឱ្យខ្សែសង្វាក់ផលិតកម្មរបស់ផលិតផលដែលបំពេញតម្រូវការក្នុងស្រុកមានបញ្ហា ដែលប្រសិនបើស្ថានភាពកាន់តែធ្ងន់ធ្ងរនោះ អាចនឹងធ្វើឱ្យមានការបាត់បង់មុខរបរ ឬការងារដោយសារតែការដួលរលំនៃការផ្គត់ផ្គង់ក្នុងស្រុក និងអាចឈានទៅដល់ការពឹងពាក់កាន់តែខ្លាំងលើផលិតផលនាំចូល។

[1] ដោយសារតែមានការនាំចូលនៃទំនិញពីប្រទេសជាដៃគូដែលទំនិញខ្លះអាចមានតម្លៃទាបជាងទំនិញដែលផលិតក្នុងស្រុក ដូចនេះ ដើម្បីបង្កើននូវការប្រកួតប្រជែងរបស់ខ្លួន អ្នកវិនិយោគ ឬផលិតករក្នុងស្រុកចាំបាច់ត្រូវបញ្ចុះតម្លៃទំនិញរបស់ខ្លួន ដើម្បីប្រកួតប្រជែងជាមួយនឹងទំនិញនាំចូលទាំងនោះ។ ក្រៅពីការចាំបាច់ត្រូវប្រកួតប្រជែងផ្នែកតម្លៃ ផលិតករក្នុងស្រុកក៏ចាំបាច់ត្រូវពង្រឹងបន្ថែមនូវគុណភាព និងសេវាកម្មនានារបស់ខ្លួនដើម្បីអាចប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូលទាំងនោះបាន។

ក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច វិស័យពាណិជ្ជកម្ម ជាពិសេសពាណិជ្ជកម្មអន្តរជាតិគឺជាចលករដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេស ក៏ដូចជាជំរុញនូវផលិតកម្មលើគ្រប់វិស័យទាំងអស់រាប់ទាំង ផលិតផលកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្មផងដែរ។ ការពង្រីកវិសាលភាពពាណិជ្ជកម្មរបស់ខ្លួនក្នុងក្របខណ្ឌអន្តរជាតិ គឺជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតក្នុងការរក្សានូវស្ថិរភាពនៃការវិនិយោគក្នុងស្រុក ព្រមទាំងអាចទាក់ទាញនូវការវិនិយោគថ្មីៗបន្ថែមទៀត។ ជាមួយគ្នានេះ យើងសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាបានបន្តខិតខំ ប្រឹងប្រែងយ៉ាងសកម្ម ក្នុងកិច្ចការងារពង្រីកវិសាលភាពពាណិជ្ជកម្មអន្តរជាតិរបស់ខ្លួនជាមួយប្រទេសជាដៃគូនានា ទាំងក្នុងក្របខណ្ឌតំបន់ ពិភពលោក ក៏ដូចជាក្របខណ្ឌទ្វេភាគីផងដែរ។ ជាក់ស្តែង ដូចដែលបានបញ្ជាក់ខាងលើ កម្ពុជាបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ដែលកិច្ចព្រមព្រៀងនេះ គឺជាយន្តការមួយក្នុងការពង្រីកវិសាលភាពវិស័យពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាផងដែរ (VOA News, 2020)។ យ៉ាងណាមិញ ក្រៅពីការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយនឹងប្រទេសចិន កម្ពុជាក៏បានកំពុងសិក្សា និងចរចាជាមួយប្រទេសកូរ៉េខាងត្បូងផងដែរ ក្នុងន័យធ្វើឱ្យលេចចេញជារូបរាងឡើងនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ។ បន្ថែមពីលើនេះ កម្ពុជាក៏គ្រោងនឹងធ្វើការចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសផ្សេងៗទៀតដូចជា ប្រទេសអង់គ្លេស សហរដ្ឋអាមេរិក ប្រទេសជប៉ុន ប្រទេសម៉ុងហ្គោលី ប្រទេសឥណ្ឌា និងសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ានផងដែរ (Sangeetha Amarthalingam, 2020)។

## ១.១.២. អំពីជញ្ជីងពាណិជ្ជកម្មកម្ពុជា

ក្នុងឆ្នាំ២០១៩ ទិន្នន័យការនាំចូល និងនាំចេញរបស់កម្ពុជាមានតម្លៃប្រមាណ ៣៦,៧ប៊ីលានដុល្លារអាមេរិក (១៤៩,៦ទ្រីលានរៀល) ដែលក្នុងនោះការនាំចេញទំនិញគ្រប់ប្រភេទទៅកាន់ប្រទេសជាដៃគូទាំងឡាយ មានតម្លៃសរុបប្រមាណ ១៤,៥៣ប៊ីលានដុល្លារ (៥៩,២ទ្រីលានរៀល) ដោយឡែកការនាំចូលវិញមានប្រមាណជាង ២២,១៩ប៊ីលានដុល្លារ (៩០,៤ទ្រីលានរៀល) (Chea Vannak, 2020)។ តុល្យភាពនេះ មានទំហំជិតស្មើនឹងពីរដង បើប្រៀបធៀបទំហំពាណិជ្ជកម្មនាំចេញជាមួយនឹងទំហំនៃការនាំចូលមកកាន់កម្ពុជាវិញ។ ខាងក្រោមនេះ ជាទិន្នន័យការនាំចេញរបស់កម្ពុជាក្នុងឆ្នាំ២០១៩ ទៅកាន់ប្រទេសជាដៃគូដែលមានទំហំពាណិជ្ជកម្មធំជាងគេទាំង១០។

| តារាងទី 1៖ ទំហំការនាំចេញទំនិញគ្រប់ប្រភេទរបស់កម្ពុជាក្នុងឆ្នាំ២០១៩ ទៅកាន់ទីផ្សារប្រទេសជាដៃគូធំៗទាំង១០ | | | |
|---|---|---|---|
| ល.រ | ប្រទេស/តំបន់ | ទំហំទឹកប្រាក់ ($USD) | ចំណែកក្នុងពាណិជ្ជកម្ម |
| ១ | សហរដ្ឋអាមេរិក | 4.41 | 29% |
| ២ | ប្រទេសជប៉ុន | 1.14 | 7.68% |
| ៣ | ប្រទេសអាឡឺម៉ង់ | 1.08 | 7.29% |
| ៤ | ប្រទេសចិន | 1.01 | 6.82% |
| ៥ | ចក្រភពអង់គ្លេស | 979m | 6.6% |
| ៦ | ប្រទេសកាណាដា | 839 | 5.66% |
| ៧ | ប្រទេសបែលហ្សិក | 544 | 3.67% |
| ៨ | ប្រទេសអេស្ប៉ាញ | 518 | 3.49% |
| ៩ | ប្រទេសថៃ | 507 | 3.42% |
| ១០ | ប្រទេសហូឡង់ | 464 | 3.13% |

*ប្រភព៖ Trend Economy, 2020*

ជាក់ស្តែង បើទោះបីជាស្ថិតក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ក្តី ក៏នៅក្នុងរយៈពេល៦ខែដំបូងនៃឆ្នាំ២០២១នេះ កម្ពុជាបាននាំចេញកសិផលកសិកម្មសំខាន់ៗក្នុងបរិមាណជាង៤លានតោន (៤ ៤៥៤ ៥០៥,៣៣) ទៅកាន់ទិសដៅ ៦២ប្រទេស ដែលចំនួននេះ មានការកើនឡើងជាង ២លានតោន (២ ០៤១ ៩៨២,៧២) ស្មើនឹង ៨៤,៦៤% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០កន្លងទៅ (Deth Ieng, ២០២១)។

ដោយឡែកបើយើងពិនិត្យទៅលើជញ្ជីងពាណិជ្ជកម្មរវាងកម្ពុជាជាមួយនឹងប្រទេសចិនវិញ យើងឃើញថា ការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសនេះមានការកើនឡើងក្នុងឆ្នាំ២០២០កន្លងទៅ បើទោះបីជាមានការរាំងស្ទះខ្លះៗដោយសារតែមានការរីករាលដាលនៃជំងឺកូវីដ-១៩ក្តី។ ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារប្រទេសចិនបានកើនឡើងក្នុងរង្វង់ ៨% ដោយមានទំហំទឹកប្រាក់សរុបប្រមាណ ១,០៨៦ប៊ីលានដុល្លាអាមេរិក បើធៀបទៅនឹងទំហំកាលពីឆ្នាំ២០១៩ ដែលមានត្រឹមតែ ១,០០៤ប៊ីលានដុល្លារអាមេរិកប៉ុណ្ណោះ (May Kunmakara, ២០២១)។ ជាមួយគ្នានេះ កម្ពុជាបានធ្វើការនាំចូលទំនិញសព្វសារពើពីប្រទេសចិនក្នុងរង្វង់ទឹកប្រាក់សរុបប្រមាណ ៧ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ

២០២០ ដោយមានការកើនឡើងប្រហែល ១០% បើធៀបនឹងឆ្នាំ២០១៩ (May Kunmakara, ២០២១)។ ជាមួយនឹងអតុល្យភាពនេះ យើងសង្កេតឃើញថា ទំហំពាណិជ្ជកម្មរបស់កម្ពុជា និងចិន មានលម្អៀងខ្លាំង ដោយជិតស្មើនឹង៧ដង បើធៀបទំហំការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសចិន ជាមួយនឹងការនាំចូលមកវិញពីប្រទេសចិន។

ជាមួយនឹងការនាំចេញផលិតផលរបស់កម្ពុជាទៅកាន់ប្រទេសចិន ទំនិញដែលជាផលិតផលកសិកម្មគ្រាន់តែជាផ្នែកតូចមួយប៉ុណ្ណោះបើធៀបនឹងវិសាលភាពនាំចេញទាំងស្រុងរបស់កម្ពុជាទៅកាន់ទីផ្សារប្រទេសចិន។ ទាក់ទងនឹងចំណុចនេះ លោកបណ្ឌិតធេង គឹមឡុង បានធ្វើការគូសបញ្ជាក់ថា៖

*«ក្នុងជញ្ជីងពាណិជ្ជកម្មកម្ពុជា-ចិនរយៈពេលជាង១០ឆ្នាំកន្លងមកនេះ ទំនិញកសិកម្មគឺជាទំនិញនាំចេញតែមួយផ្នែកតូចប៉ុណ្ណោះរបស់កម្ពុជា ហើយទំនិញនេះក៏ពុំបានធ្វើឱ្យកម្ពុជាចំណេញកប់ក្តោងនោះទេ*[2]។ *គាត់បានបញ្ជាក់បន្ថែមថា កម្ពុជាបានធ្វើការនាំចេញទំនិញពុំមែនកសិកម្មច្រើនជាងគេទៅកាន់ទីផ្សារប្រទេសចិន ក្នុងនោះមានផលិតផលពាក់កណ្តាលសម្រេច ដែលប្រើប្រាស់នៅក្នុងវិស័យឧស្សាហកម្មរបស់ប្រទេសចិន ផលិតផលកសិកម្មកែច្នៃ គ្រាប់ធុញ្ញជាតិ ស្បែកសត្វ និងផលិតផលសម្លៀកបំពាក់ជាដើម»*។

ផលិតផលសំខាន់ៗដែលកម្ពុជាបានធ្វើការនាំចេញទៅកាន់ទីផ្សារប្រទេសចិនមានដូចជា អង្ករ ចេក កៅស៊ូស្ងួត ដំឡូងមី ផលិតផលនេសាទ និងផលិតផលចេញពីឧស្សាហកម្មកាត់ដេរជាច្រើនប្រភេទទៀត។ នៅក្នុងដើមឆ្នាំ២០២១នេះ កម្ពុជាក៏បាននាំចេញផងដែរនូវផ្លែស្វាយស្រស់ ដែលនេះជាឱកាសមួយទៀតសម្រាប់កម្ពុជាក្នុងការរកទីផ្សារជូនប្រជាកសិករយើង។ ដោយឡែក ទំនិញដែលប្រទេសកម្ពុជាធ្វើការនាំចូលពីប្រទេសចិនវិញមានដូចជា វត្ថុធាតុដើមសម្រាប់ផលិតកម្មវិស័យកាត់ដេរ គ្រឿងម៉ាស៊ីន យានយន្ត អាហារ បរិក្ខារអេឡិចត្រូនិច ថ្នាំពេទ្យ និងគ្រឿងសម្អាងជាដើម។ ស្របពេលដែលកម្ពុជាបាននាំចេញទំនិញកសិកម្មជាច្រើនប្រភេទទៅប្រទេសចិន កម្ពុជាក៏បានធ្វើការនាំចូលបន្លែជាច្រើនប្រភេទពីប្រទេសចិនវិញដូចគ្នា ដែលបន្លែទាំងនោះភាគច្រើនជាប្រភេទបន្លែកម្រ ឬពិបាកធ្វើការដាំដុះនៅក្នុងប្រទេសកម្ពុជា។

[2] គួរបញ្ជាក់ថា ក្រុមការងារស្រាវជ្រាវពុំអាចទទួលបាននូវទិន្នន័យច្បាស់ការនៃការនាំចេញផលិតផលនានាដែលមិនមែនកសិកម្មនោះទេ។

## ១.២. ដំណើរការនៃស្រាវជ្រាវ

ការសិក្សានេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ (Qualitative Approach) ដែលមានការចូលរួមពីក្រុមគោលដៅ និងអ្នកជំនាញនានាពីមជ្ឈដ្ឋានផ្សេងៗទាំងក្នុងវិស័យរដ្ឋ ឯកជន និងជាលក្ខណៈបុគ្គលផងដែរ។ ទិន្នន័យត្រូវបានប្រមូលតាមវិធីសាស្ត្រដូចជា ការសម្ភាសជាមួយនឹងក្រុមគោលដៅដោយផ្ទាល់ ការរៀបចំកិច្ចពិភាក្សាជាមួយនឹងអ្នកជំនាញខាងសេដ្ឋកិច្ច នយោបាយ ពាណិជ្ជកម្ម ឧស្សាហកម្ម និងកសិកម្មជាដើម។ បន្ថែមពីលើនេះ ក្រុមអ្នកស្រាវជ្រាវក៏បានប្រើប្រាស់ទិន្នន័យ និងព័ត៌មានជាច្រើនទៀតដែលប្រមូលបានឯកសារស្រាវជ្រាវ ឯកសារគោលនយោបាយ និងចេញពីប្រព័ន្ធអ៊ីនធើណេត និងបណ្តាញព័ត៌មានជាតិ និងអន្តរជាតិផងដែរ។

### ១.២.១. គោលបំណងនិងវិសាលភាព

ការស្រាវជ្រាវនេះមានគោលបំណងសិក្សាអំពីសក្តានុពល បញ្ហាប្រឈម ព្រមទាំងឱកាសនានាដែលកម្ពុជាអាចទទួលបានពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ទាំងក្នុងក្របខណ្ឌសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសង្គម។ ជាមួយនឹងគោលបំណងនេះ ការសិក្សានេះ មានវត្ថុបំណងចំនួនបួនដែលមានវិសាលភាពនៃការស្រាវជ្រាវដូចខាងក្រោម។

**វត្ថុបំណងទី១៖** សិក្សា និងវិភាគអំពីអត្ថប្រយោជន៍ដែលកម្ពុជា អាចទទួលបានពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន

**វត្ថុបំណងទី២៖** សិក្សា និងវិភាគអំពីបញ្ហាប្រឈមនានា ដែលកម្ពុជាមានក្នុងការទាញយកនូវអត្ថប្រយោជន៍ជាអតិបរមាចេញពីពាណិជ្ជកម្មសេរីកម្ពុជា-ចិន

**វត្ថុបំណងទី៣៖** សិក្សា និងវិភាគអំពីសក្តានុពលទៅតាមវិស័យនានា ដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន

**វត្ថុបំណងទី៤៖** សិក្សា និងវិភាគអំពីអត្ថប្រយោជន៍ និងឱកាស ដែលកើតមានសម្រាប់កម្ពុជាចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន

## ១.២.២. បញ្ហាប្រឈមក្នុងការស្រាវជ្រាវ

ការសិក្សានេះធ្វើឡើងក្នុងអំឡុងនៃការរីករាលដាលខ្លាំងនៃជំងឺកូវីដ-១៩ ក្នុងសហគមដំណាក់កាលទី២ (ព្រឹត្តិការណ៍២០កុម្ភៈ) ដែលធ្វើឱ្យដំណើរការស្រាវជ្រាវ និងការប្រមូលទិន្នន័យត្រូវជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ។ ដោយសារតែមានភាពចាំបាច់ក្នុងការរក្សាគម្លាតសង្គម និងការអនុវត្តនូវវិធានការពារផ្សេងៗទៀត ដំណើរការប្រមូលទិន្នន័យដូចជាការសម្ភាស ការរៀបចំកិច្ចពិភាក្សាជាដើម ត្រូវបានរៀបចំឡើងតាមប្រព័ន្ធអនឡាញ។ ចំពោះទិន្នន័យ និងព័ត៌មានចាំបាច់មួយចំនួនទៀត ក្រុមការងារគម្រោង បានធ្វើការស្នើសុំដោយផ្ទាល់ទៅស្ថាប័នជំនាញ ឬអ្នកជំនាញការទៅតាមវិស័យនីមួយៗទាំងក្នុងក្របខណ្ឌផ្លូវការ និងមិនផ្លូវការ។

# ជំពូក ២
# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន

កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ប្រទេសកម្ពុជា និងចិនបានចុះហត្ថលេខាផ្លូវការលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (ប្រកាសក្រសួងពាណិជ្ជកម្ម, ២០២០) ដែលកិច្ចព្រមព្រៀងនេះ នឹងពង្រីកឱកាសបន្ថែមទៀតនូវលំហូរពាណិជ្ជកម្ម ក៏ដូចជាការបើកនូវសម័យកាលថ្មីមួយទៀតនៃយុទ្ធសាស្ត្រសហការគ្រប់ជ្រុងជ្រោយរបស់ប្រទេសទាំងពីរផងដែរ។ កិច្ចព្រមព្រៀងនេះ ត្រូវបានគេមើលឃើញថា នឹងដើរតួយ៉ាងសំខាន់ក្នុងការកសាងនូវសហគមន៍រួមគ្នា កម្ពុជា-ចិន ដោយពង្រឹងទាំងទំនាក់ទំនងវប្បធម៌ ក៏ដូចជាការកសាងខឿនសេដ្ឋកិច្ចតាមយុទ្ធសាស្ត្រ "**ផ្លូវមួយខ្សែក្រវ៉ាត់មួយ**" របស់ប្រទេសចិនផងដែរ (Chris Devonshire-Ellis, ២០២០)។ យើងសង្កេតឃើញថា ជញ្ជីងពាណិជ្ជកម្មរបស់ប្រទេសទាំងពីរមានទំហំ ៧.៤ប៊ីលានដុល្លារអាមេរិក កាលពីឆ្នាំ២០១៨ ដែលក្នុងនោះប្រទេសចិនបានធ្វើការនាំចូលទំនិញគ្រប់ប្រភេទមកកម្ពុជាក្នុងទំហំទឹកប្រាក់សរុបប្រមាណ ៦ប៊ីលានដុល្លារអាមេរិក។ តាមរយៈកិច្ចព្រមព្រៀងនេះ ប្រទេសទាំងពីរប្តេជ្ញាជំរុញពាណិជ្ជកម្មរវាងទាំងពីរប្រទេសឱ្យមានទំហំ ១០ប៊ីលានដុល្លារអាមេរិកនៅត្រឹមឆ្នាំ២០២៣ខាងមុខ (Chris Devonshire-Ellis, 2020)។

## ២.១. អំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន

### ២.១.១. សាវតានៃកិច្ចព្រមព្រៀង

សាវតានៃការពិភាក្សាលើការបង្កើតនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះ បានចាប់ផ្តើមក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចអគ្គមហាសេនាធិបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់រដ្ឋធានីប៉េកាំងសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២១-២៣ ខែមករាឆ្នាំ២០១៩មកម្ល៉េះ។ ស្ថិតក្នុងឱកាសនោះ តំណាងរដ្ឋាភិបាលនៃប្រទេសទាំងពីរបានឯកភាពគ្នាបង្កើតក្រុមការងារចម្រុះដើម្បីធ្វើការសិក្សាមួយ ក្នុងន័យពិនិត្យលើលទ្ធភាពទាំងអត្ថ

ប្រយោជន៍ និងបញ្ហាប្រឈមនានានៃការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (ប្រកាសក្រសួងពាណិជ្ជកម្ម, ២០២០)។ តាមប្រកាសដដែលនេះបានបញ្ជាក់ថា កិច្ចព្រមព្រៀងនេះ ត្រូវបានក្រុមអ្នកជំនាញទាំងពីរប្រទេស កម្ពុជា-ចិន បានបើកការចរចាជាផ្លូវការចំនួនបីដំណាក់កាលតាមកាលបរិច្ឆេទដូចខាងក្រោម៖

- លើកទី១៖ នៅថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២០ នៅក្រុងប៉េកាំងប្រទេសចិន
- លើកទី២៖ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីឌីអូ
- លើកទី៣៖ នៅថ្ងៃទី៩ ខែមីថុនា ឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីឌីអូ(ជាចុងក្រោយ)

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលមានគុណតម្លៃខ្ពស់ក្នុងការជំរុញកំណើនពាណិជ្ជកម្មរវាងកម្ពុជានិងចិន ត្រូវបានចុះហត្ថលេខាតាំងពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ក៏ប៉ុន្តែកិច្ចព្រមព្រៀងនេះមិនទាន់ត្រូវបានអនុវត្តនៅឡើយទេ ដោយត្រូវរង់ចាំបំពេញលក្ខខណ្ឌផ្លូវច្បាប់តាមប្រទេសនីមួយៗ ក៏ដូចជាការអនុម័តយល់ព្រមពីស្ថាប័នសភានៃប្រទេសទាំងពីរសិន។ តាមការរំពឹងទុក កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅខែមករាឆ្នាំ២០២២ ដោយភាគីទាំងពីរបានប្តេជ្ញាជំរុញពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ឱ្យបានកើនឡើងដល់១០ប៊ីលានដុល្លារក្នុងមួយឆ្នាំ (Freshnews, 2021)។

## ២.១.២. ទិសាលភាពនិងអត្ថប្រយោជន៍

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នឹងបើកផ្លូវឱ្យកម្ពុជាអាចធ្វើការនាំចេញផលិតផលជាង៣៤០មុខបន្ថែមទៀត ហើយ៩៥% នៃផលិតផលទាំងនេះ នឹងទទួលបានការអនុគ្រោះពន្ធទាំងស្រុង ហើយនៅសល់៥% ទៀតនឹងទទួលបានការបន្ធូរបន្ថយជាលំដាប់។ កិច្ចព្រមព្រៀងនេះ នឹងសម្រួលរបាំងពន្ធអាករ ការកំណត់ចំនួនទំនិញ ពង្រីកការធ្វើពាណិជ្ជកម្ម សេវាកម្ម និងកិច្ចសហប្រតិបត្តិការឲ្យកាន់តែស៊ីជម្រៅជាងមុន និងសំដៅសម្រេចឲ្យបានគោលដៅ ពាណិជ្ជកម្មសរុបចំនួន១០ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០២៣។ ជាមួយគ្នានេះ Sorn Sarath. (2020) បានធ្វើការគូសបញ្ជាក់ថា ជាមួយនឹងការបន្ថែមផលិតផលចំនួន៣៤០ទៀតក្នុងកិច្ចព្រមព្រៀងនេះ បានធ្វើឱ្យកម្ពុជា

អាចធ្វើការនាំចេញទំនិញកសិកម្ម កសិ-ឧស្សាហកម្ម និងទំនិញផ្សេងទៀតសរុបរហូតដល់១០,០០០ មុខ បើគិតទាំងកិច្ចព្រមព្រៀងអាស៊ាន-ចិនដែលមានស្រាប់។

ក្រៅពីអត្ថប្រយោជន៍ទីផ្សារទំនិញកាន់តែទូលាយជាងមុន កិច្ចព្រមព្រៀងនេះត្រូវបានគេមើលឃើញថា នឹងដើរតួជាកាតាលីករដ៏សំខាន់ក្នុងការកៀងគរការវិនិយោគទុនពីបរទេស ក្នុងនោះក៏មានការវិនិយោគដោយផ្ទាល់ពីប្រទេសចិនផងដែរ។ ផលចំណេញមួយទៀតដែលកម្ពុជាអាចទទួលបានពីកិច្ចព្រមព្រៀងនេះ គឺការកាត់បន្ថយបាននូវចំណាយផ្សេងៗ ឬការមិនយកពន្ធគ្រួតស៊ីគ្នាជាដើម។

បើតាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះ មានវិសាលភាព និងអត្ថប្រយោជន៍ចម្បងដូចខាងក្រោមៈ

- ការទទួលបានទីផ្សារធំទូលាយជាងមុន និងប្រសើរជាងមុន សម្រាប់ទំនិញកសិផលនានាដូចជា បន្លែ ផ្លែឈើ ត្រី សាច់គ្រប់ប្រភេទ ផលិតផលកែច្នៃ ផលិតផលសិប្បកម្ម និងផលិតផលជាច្រើនទៀតដែលកម្ពុជាអាចផលិតបាន និងអនុលោមទៅតាមវិធានអនាម័យ សុខភាព និងមានស្តង់ដាត្រឹមត្រូវ។
- ការទទួលបានលំហូរទីផ្សារក្នុងវិស័យសេវាកម្ម ដូចជាករណីបណ្តុះបណ្តាលជំនាញ និងមានគុណវុឌ្ឍិគ្រប់គ្រាន់ ជាពិសេសធ្វើឱ្យកម្ពុជាអាចពង្រឹងខ្លួនឯងបានរឹងមាំក្នុងវិស័យសេវាកម្មនាពេលអនាគត។ លើសពីនេះ កម្ពុជានឹងទទួលបានផលប្រយោជន៍ពីការប្រមូលពន្ធជា ការទទួលបានការងារ ការទទួលបានការបណ្តុះបណ្តាលចំណេះដឹង ចំណេះធ្វើ ជំនាញពីអ្នកផ្គត់ផ្គង់សេវា និងក្រុមហ៊ុនផ្គត់ផ្គង់សេវាបរទេស ដែលជាកត្តាដ៏សំខាន់ ដើម្បីពង្រឹងដល់វិស័យផលិតកម្មក្នុងស្រុក។
- ការកំណត់ឱ្យបានកាន់តែច្បាស់នូវរាល់នីតិវិធីទាក់ទងទៅនឹងវិធាននានាសម្រាប់ ប្រភពទំនិញ នីតិវិធីគយ ការសម្រួលពាណិជ្ជកម្ម អនាម័យ ភូតគាមអនាម័យ និងរបាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម និងការធ្វើសាមញ្ញកម្ម ដើម្បីងាយស្រួលអនុវត្ត និងសម្រួលដល់ការធ្វើពាណិជ្ជកម្ម។
- ការរៀបចំបង្កើតបរិយាកាសវិនិយោគ និងនយោបាយ សម្រាប់ជំរុញការវិនិយោគពីបរទេស។

- កម្ពុជានឹងទទួលបានទីផ្សារក្នុងប្រទេសចិនសម្រាប់ទំនិញប្រមាណ៩៨% នៃមុខទំនិញសរុប បើធៀបជាមួយនឹងសម្បទាន ដែលកម្ពុជាទទួលបានក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិន ដែលមានត្រឹមតែ៩៤%ប៉ុណ្ណោះ។ កិច្ចព្រមព្រៀងនេះបានបើកផ្លូវចរចារបន្តទៀតក្នុងការបើកច្រកទីផ្សារបន្ថែមលើមុខទំនិញសំខាន់ៗ ដែលមិនទាន់បានសម្រួលលក្ខខណ្ឌទីផ្សារបានល្អប្រសើរនៅឡើយ។
- កម្ពុជាបានផ្តល់ការបើកច្រកទីផ្សារសម្រាប់ទំនិញចិនប្រមាណ ៩០% នៃបន្ទាត់ពន្ធគយសរុបប៉ុណ្ណោះ គឺប្រហាក់ប្រហែលនឹងកម្រិតនៃការបើកច្រកទីផ្សារក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិន។
- ភាគីចិនក៏បានផ្តល់នូវកញ្ចប់សន្យាតាមវិស័យសេវាកម្ម ដោយបានធ្វើឱ្យប្រសើរជាងមុននូវលក្ខខណ្ឌមួយចំនួនក្នុងផ្នែកច្រកចូលទីផ្សារ និងប្រព្រឹត្តិកម្មជាតិលើវិស័យសេវាកម្មមួយចំនួន ដូចជាសេវាកម្មធានារ៉ាប់រង សេវាកម្មធនាគារ សេវាកម្មវេជ្ជសាស្ត្រ និងទន្តពេទ្យ សេវាកម្មស្រាវជ្រាវទីផ្សារ សេវាកម្មពិគ្រោះយោបល់ផ្នែកគ្រប់គ្រង សេវាកម្មពាក់ព័ន្ធនឹងរុក្ខសាស្ត្រ សេវាកម្មផ្គត់ផ្គង់បុគ្គលិក សេវាកម្មថតរូប សេវាកម្មបរិស្ថាន សេវាកម្មសណ្ឋាគារ និងភោជនីយដ្ឋាន សេវាកម្មដឹកជញ្ជូនតាមផ្លូវសមុទ្រ និងសេវាកម្មលើកដាក់ទំនិញ។
- ភាគីកម្ពុជាបានផ្តល់នូវការបើកច្រកទីផ្សារ ដូចជាស្របទៅនឹងកម្រិតដែលបានសន្យាក្រោមលក្ខខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិន។ ក្នុងនោះក៏បានធ្វើការកែលម្អលើអនុវិស័យសេវាកម្មដែលបម្រើដល់ផលប្រយោជន៍ក្នុងវិស័យអប់រំ និងដឹកជញ្ជូនទំនិញតាមសមុទ្រផងដែរ។
- យកលំនាំតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិន (ACFTA) ជាពិសេសក្នុងផ្នែកស្តីពីវិធានដើមកំណើតទំនិញ (Rules of Origin-ROO) និងផ្នែកស្តីពីនីតិវិធីប្រតិបត្តិការវិញ្ញាបនប័ត្រ (Operational Certification Procedures-OCP) ដោយមាត្រានៅក្នុង ROO និងវិធាននៅក្នុង OCP ភាគច្រើនត្រូវបានកែសម្រួល ដើម្បីឱ្យមានអនុលោមភាពជាមួយកិច្ចព្រមព្រៀងអន្តរជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដោយបញ្ចូលនូវប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីសម្រួលដល់ការទទួលស្គាល់ឯកសារប្រព័ន្ធអេឡិចត្រូនិក និងជម្រះបញ្ជី និងបញ្ចេញទំនិញ។

- នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម មានគោលបំណងដើម្បីៈ
  - ជានាបាននូវភាពអាចព្យាករណ៍បាន សង្គតិភាព និងតម្លាភាពក្នុងការអនុវត្តច្បាប់គយនៃប្រទេសរៀងៗខ្លួន
  - ជំរុញប្រសិទ្ធភាព និងភាពសន្សំសំចៃនៃការគ្រប់គ្រងអនុវត្ត នីតិវិធីគយ និងការបញ្ចេញទំនិញរហ័ស
  - ធ្វើសាមញ្ញកម្ម និងសុខដុមនីយកម្មលើនីតិវិធីគយតាមលទ្ធភាពដែលអាចធ្វើទៅបានស្របតាមច្បាប់ជាតិ និងអន្តរជាតិ
  - ជំរុញកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយនៃប្រទេសទាំងពីរ និងសម្រួលពាណិជ្ជកម្មឱ្យបានប្រសើរឡើង។
- កិច្ចសហប្រតិបត្តិការវិនិយោគ ត្រូវរៀបចំឱ្យគ្រប់ដណ្តប់លើកិច្ចសហប្រតិបត្តិការក្នុងសរសរស្តម្ភពីរសំខាន់ គឺ ការជំរុញ និងកិច្ចសម្រួលវិនិយោគ ដើម្បីទាក់ទាញវិនិយោគពីចិន និងប្រទេសទីបី និងគ្របដណ្តប់ការធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងភាពអាចប៉ាន់ប្រមាណបាននៃវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីពាក់ព័ន្ធនឹងការវិនិយោគ ព្រមទាំងបង្កើតក្របខណ្ឌចាំបាច់នានាសំដៅកែលម្អបរិស្ថានវិនិយោគនៃប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរឡើង។
- អនាម័យ និងភូតគាមអនាម័យ(SPS) មានកំណត់អំពីការផ្លាស់ប្តូរព័ត៌មានរវាងគ្នាឱ្យបានលឿនលើបញ្ហាវិភាគលើអនាម័យនិងដំណើរការកំណត់សមមូលភាព(equivalence)នៃវិធានការណ៍អនាម័យណាមួយដែលភាគីទាំងពីរយល់ព្រមថា មានសារៈសំខាន់ក្នុងកិច្ចសម្រួលពាណិជ្ជកម្មលើផលិតផលជាក់លាក់ណាមួយ និងកំណត់អំពីការផ្លាស់ប្តូរឯកសារអត្ថបទបច្ចេកទេសក្នុងទម្រង់ពេញលេញ និងជាភាសាអង់គ្លេសដើម្បីងាយស្រួលដល់ពាណិជ្ជករ និងផលិតករងាយយល់ និងយោងសម្រាប់រៀបចំផលិតផលឱ្យត្រូវតាមការតម្រូវ។ ផ្នែកនេះក៏បានចែងអំពីការអនុវត្តនីតិវិធីអនាម័យ និងភូតគាមអនាម័យទៅលើទំនិញដែលហាមឃាត់ទុកនៅច្រកទ្វារព្រំដែនដែល ដោយសារមិនមានអនុលោមភាពខាង SPS ដែលភាគីទាំងពីរបានឯកភាពឱ្យមានការជូនដំណឹងគ្នាទៅវិញទៅមកឱ្យបានលឿនបំផុត។

- កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បច្ចេកទេស និងខ្សែក្រវ៉ាត់ និងផ្លូវមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរស្របតាមគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ ដោយផ្តោតលើកិច្ចសហប្រតិបត្តិការ លើការកសាងវិស័យហេដ្ឋរចនាសម្ព័ន្ធ និងវិនិយោគច្រករបៀងសេដ្ឋកិច្ចតំបន់ សហប្រតិបត្តិការសេដ្ឋកិច្ច កសិកម្ម ការកសាងសមត្ថភាព វប្បធម៌ និងទេសចរណ៍ ហិរញ្ញវត្ថុ និងការការពារបរិស្ថាន ដែលនឹងជួយការវិនិយោគ និងពាណិជ្ជកម្មទ្វេភាគី។ ហើយជាក្របខណ្ឌជំរុញការអនុវត្តគម្រោងនានាសម្រាប់គាំទ្រវិស័យពាណិជ្ជកម្ម និងពង្រឹងសមត្ថភាពស្ថាប័ន និងកសាងធនធានមនុស្ស ដោយប្រើប្រាស់ហិរញ្ញប្បទានតាមយន្តការដែលមានស្រាប់។ កិច្ចសហប្រតិបត្តិការផ្តោតសំខាន់លើវិស័យអាទិភាព គឺកិច្ចជំរុញពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវា កិច្ចជំរុញទេសចរណ៍ វិស័យឧស្សាហកម្មដឹកជញ្ជូន និងភស្តុភារកម្មកសិកម្ម វិធានមិនមែនពន្ធគយ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងវិស័យផ្សេងទៀតដែលកម្ពុជាត្រូវការ។
- ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ក្របដណ្តប់លើការបង្កើនកិច្ចសហប្រតិបត្តិការទាក់ទងនឹងការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិក ដើម្បីបង្កើតការជឿទុកចិត្ត និងភាពជឿជាក់ ដោយផ្តោតសំខាន់លើការចរាចរណ៍ទំនិញបម្រើឱ្យវិស័យព័ត៌មានវិទ្យា ការកំណត់យថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិក កិច្ចការពារអ្នកប្រើប្រាស់តាមអនឡាញ កិច្ចការពារព័ត៌មានផ្ទាល់ខ្លួនអនឡាញ ពាណិជ្ជកម្មដោយមិនប្រើក្រដាសស្នាម ឧបករណ៍បណ្តាញកុំព្យូទ័រ និងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## ២.២. មតិនានាជុំវិញកិច្ចព្រមព្រៀង

បើពិនិត្យទៅលើវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន គេសង្កេតឃើញថា កម្ពុជាអាចនឹងទទួលបាននូវអត្ថប្រយោជន៍ និងលក្ខខណ្ឌពាណិជ្ជកម្មដែលប្រសើរជាងមុនជាមួយប្រទេសចិន ជាពិសេសសម្រាប់ផលិតផលកសិកម្ម កសិ-ឧស្សាហកម្ម និងសេវាកម្មជាដើម។ ជាក់ស្តែង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះ ត្រូវបានមតិជាច្រើនគាំទ្រថាជាយន្តការសំខាន់បំផុតមួយក្នុងការពង្រីកវិសាលភាពវិស័យពាណិជ្ជកម្មរបស់ជាតិ ក៏ដូចជាចូលរួមក្នុងការអភិវឌ្ឍសង្គម និង

សេដ្ឋកិច្ចកម្ពុជា។ បើទោះបីជាកិច្ចព្រមព្រៀងពាណិជ្ជកម្មនេះ អាចនឹងផ្ដល់ផលវិជ្ជមានបន្ថែមទៀតមកលើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់កម្ពុជាក្ដី ក៏យើងសង្កេតឃើញមានក្ដីកង្វល់ខ្លះៗក្នុងចំណោមមហាជន អ្នកជំនាញ ក៏ដូចជាអ្នកវិភាគនយោបាយមួយចំនួនផងដែរ។

មតិខ្លះបានលើកឡើងថា ជាមួយនឹងកិច្ចព្រមព្រៀងនេះ កម្ពុជានឹងចាញ់ប្រៀបប្រទេសចិនខ្លាំង ដោយសារតែចិនគឺជាប្រទេសអ្នកផលិត ដោយឡែកកម្ពុជាជាប្រទេសអ្នកប្រើប្រាស់ ហើយលទ្ធភាពនៃផលិតកម្មរបស់ខ្លួននៅមានកម្រិតទាប បើធៀបជាមួយនឹងលទ្ធភាពផលិតកម្មរបស់ប្រទេសចិន (NOU SEYHA, ២០២០; Heimkhemra SUY, 2020; Sorn Sarath, 2020)។ ប្រទេសចិនគឺជាឃ្លាំងនៃផលិតកម្មទំនិញគ្រប់ប្រភេទ ដែលបាននាំចេញទៅកាន់ទីផ្សារអន្តរជាតិ រួមទាំងកម្ពុជាផងដែរ។ ដោយមិនអាចប្រកែកបាន សមត្ថភាពផលិតកម្មគ្រប់ប្រភេទរបស់កម្ពុជានៅមានកម្រិតទាប ទាំងបរិមាណ និងគុណភាព ដែលកត្តាទាំងនេះនឹងក្លាយទៅជាឧបសគ្គដ៏ចម្បងក្នុងការទាញយកអត្ថប្រយោជន៍ឱ្យបានជាអតិបរមាពីកិច្ចព្រមព្រៀងនេះ។ ជាទូទៅ ថ្លៃដើមផលិតផលស្ទើរគ្រប់ប្រភេទរបស់កម្ពុជាមានកម្រិតខ្ពស់ជាងផលិតផលក្នុងប្រទេសចិន ចំពោះផលិតផលដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដែលកត្តាមួយនេះ អាចធ្វើឱ្យប៉ះពាល់ដល់តុល្យភាពនៃពាណិជ្ជកម្ម ព្រមទាំងលទ្ធភាពនៃការប្រកួតប្រជែងនៃទំនិញកម្ពុជាលើទីផ្សារប្រទេសចិនផងដែរ (Sangeetha Amarthalingam, 2020)។

ទាក់ទងនឹងបញ្ហានេះផងដែរ លោកបណ្ឌិត ឆេង គឹមឡុង បានធ្វើការគូសបញ្ជាក់ថា កិច្ចព្រមព្រៀងពាណិជ្ជកម្មនេះ នឹងធ្វើឱ្យប្រទេសទាំងពីរចំណេញដូចគ្នា ប៉ុន្តែសួរថានរណាចំណេញច្រើនជាងនោះយើងមិនអាចប្រៀបធៀបបាននោះទេ ដោយសារមូលដ្ឋានសេដ្ឋកិច្ច ខ្សែសង្វាក់ផលិតកម្ម តម្រូវការរបស់ប្រទេសទាំងពីរខុសគ្នា។ លោកបណ្ឌិតបានបញ្ជាក់បន្ថែមថា ប្រទេសចិននឹងចំណេញច្រើនជាងកម្ពុជា ដោយសារតែទំហំផលិតកម្មរបស់គេធំជាងយើង ដោយឡែកកម្ពុជាក៏នឹងទទួលបានផលចំណេញដូចគ្នាដោយអាស្រ័យទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន។ ជាមួយគ្នានេះ តាមរយៈវិទ្យុបារាំងអន្តរជាតិ (សឿង ភារៈ, ២០២០) លោកបណ្ឌិត គី សេរីវឌ្ឍន៍ ប្រធានមជ្ឈមណ្ឌលសិក្សាចិននៃរាជបណ្ឌិត្យសភាកម្ពុជា បានអះអាងថា៖

*«កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នឹងធ្វើឱ្យភាគីចិនចំណេញច្រើនជាងកម្ពុជាព្រោះថា ទោះបីកម្ពុជាបើកឲ្យមានការនាំចេញខាងវិស័យចិញ្ចឹមសត្វច្រើនមែន តែបច្ចុប្បន្ននេះ កម្ពុជាមិនទាន់រៀបចំខ្លួន*

*រួចរាល់នៅឡើយទេ ដូច្នេះកម្ពុជាត្រូវការពេលវេលាបន្ថែម ខណៈប្រទេសចិនបានត្រៀមរួចរាល់សម្រាប់ធ្វើការនាំចេញមកកម្ពុជា។»*

មតិខ្លះទៀតបានលើកឡើងថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នឹងធ្វើឱ្យកម្ពុជាបាត់បង់ចំណូលពន្ធជាតិយ៉ាងច្រើន តាមរយៈយន្តការអនុគ្រោះពន្ធដែលមានក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ។ នៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន នោះទំនិញនាំចូលពីប្រទេសចិននឹងមានការកើនឡើង ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជានឹងបាត់បង់នូវប្រាក់ចំណូលជាតិពីការអនុគ្រោះពន្ធនាំចូលលើទំនិញទាំងនេះ។ ដើម្បីបំពេញនូវការបាត់បង់ចំណូលពន្ធនេះ កម្ពុជាអាចនឹងងាកមកបង្កើនចំណូលជាតិពីការតម្លើងពន្ធលើការប្រើប្រាស់ក្នុងស្រុកវិញ (Domestic Consumption Taxes) ដែលនេះជាការដាក់បន្ទុកបន្ថែមទៀតទៅដល់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ក្នុងស្រុក។ ប្រសិនបើករណីនេះក្លាយជាការពិតមែន ការណ៍នេះ នឹងប៉ះពាល់យ៉ាងខ្លាំងដល់ស្ថានភាពសេដ្ឋកិច្ច និងការរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ឬប្រជាពលរដ្ឋដែលស្ថិតនៅជាមួយនឹងស្ថានភាពងាយរងគ្រោះទាំងឡាយ។

ក្តីបារម្ភមួយទៀតរបស់សារធារណៈជន ក៏ដូចជាអ្នកជំនាញក្នុងវិស័យផ្សេងៗគឺថា កិច្ចព្រមព្រៀងនេះកើតឡើងដោយពុំមានការសិក្សាឱ្យបានលម្អិតពីគុណសម្បត្តិ និងគុណវិបត្តិ ដែលកម្ពុជាអាចទទួលបាន ឬបាត់បង់ទៅវិញ បើទោះបីជាមានការគូសបញ្ជាក់ពីមន្ត្រីនៃក្រសួងពាណិជ្ជកម្មថា ផលប្រយោជន៍ដែលកម្ពុជានឹងទទួលបានពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះ មានច្រើនជាងគុណវិបត្តិក៏ដោយចុះ (Sangeetha Amarthalingam, 2020)។ មតិខ្លះបានសង្កត់ធ្ងន់ថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កើតឡើងស្របពេលដែលកម្ពុជាបានបាត់បង់ផ្នែកខ្លះៗនៃលក្ខខណ្ឌអនុគ្រោះពន្ធ (EBA) ពីសហភាពអឺរ៉ុប ដោយមានការចោទប្រកាន់កម្ពុជាថាបានរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬបិទសិទ្ធិក្នុងការបញ្ចេញមតិជាដើម (Shaun Turton, 2020)។

មតិខ្លះទៀតបានលើកឡើងថា កិច្ចព្រមព្រៀងនេះនឹងកាន់តែពង្រឹងនូវការគ្របដណ្តប់នៃឥទ្ធិពលរបស់ចិនមកលើកម្ពុជា ហើយនឹងកាន់តែធ្វើឱ្យប្រទេសកម្ពុជាចាំបាច់ត្រូវពឹងផ្អែកលើប្រទេសចិនកាន់តែខ្លាំង។ ការណ៍នេះ យើងអាចកត់សម្គាល់បានតាមរយៈការពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រទេសចិន ដោយសារតែតម្រូវការផលិតផលវត្ថុធាតុដើមសម្រាប់ដំណើរការឧស្សាហកម្មកាត់ដេរនៅក្នុងស្រុក

ក្នុងអំឡុងនៃវិបត្តិកូវីដ-១៩នេះ។ ឧស្សាហកម្មកាត់ដេររបស់កម្ពុជាមួយភាគធំត្រូវបានផ្អាកដំណើរការ និងរងផលប៉ះពាល់ដោយសារចិនបានផ្អាកដំណើរការផ្គត់ផ្គង់វត្ថុធាតុដើម ឬដោយសារតែបញ្ហានៃការដឹកជញ្ជូនវត្ថុធាតុដើមទាំងនោះ ដោយសារតែវិបត្តិកូវីដ-១៩។

បន្ថែមពីលើនេះ អ្នកវិភាគគោលនយោបាយ និងសេដ្ឋកិច្ចជាន់ខ្ពស់នៃមូលនិធិបេតិកភណ្ឌ (The Heritage Foundation) លោក Riley Walters បានមានប្រសាសន៍ថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះ នឹងមិនផ្តល់ឱ្យកម្ពុជានូវអត្ថប្រយោជន៍ច្រើនខ្លាំងនោះទេ ដោយសារកម្ពុជាមានស្រាប់នូវកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិន ដែលប្រទេសជាសមាជិកទាំងឡាយ កំពុងទទួលបាននូវអត្ថប្រយោជន៍នេះស្រាប់ទៅហើយ (Shaun Turton, 2020)។ មតិនេះក៏គូសបញ្ជាក់បន្ថែមថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះ អាចពង្រីកឱកាសនៃការនាំចេញរបស់កម្ពុជាប្រមាណតែ ៤% បន្ថែមទៀតប៉ុណ្ណោះទៅលើលក្ខខណ្ឌដែលកម្ពុជាទទួលបានស្រាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិន។

បន្ថែមពីលើក្តីបារម្ភលើលទ្ធភាពផលិតកម្មរបស់កម្ពុជា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បណ្ឌិតសភាចារ្យ សុខ ទូច ក៏បានសម្តែងនូវការព្រួយបារម្ភផងដែរទៅលើការកេងប្រវ័ញ្ចដោយប្រទេសជិតខាង ក្រោមរូបភាពទំនិញផលិតនៅប្រទេសគេ ប៉ុន្តែបិទស្លាកផលិតនៅកម្ពុជា រួចធ្វើការនាំចេញទៅប្រទេសចិនជាដើម (NOU SEYHA, ២០២០)។

# ជំពូក ៣
# បញ្ហាប្រឈមសម្រាប់កម្ពុជា

នៅក្នុងជំពូកទី២ខាងលើ យើងបានបង្ហាញអំពីវិសាលភាព អត្ថប្រយោជន៍ ព្រមទាំងឱកាស ដែលកម្ពុជាអាចទទួលបានចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន យ៉ាងហោចណាស់ក្នុងក្របខណ្ឌនៃគោលការណ៍នៃកិច្ចព្រមព្រៀងមួយនេះ។ ដូចដែលបានបញ្ជាក់ក្នុង**ចំណុច២.២**ខាងលើ អំពីមតិនានាទាក់ទងនឹងកិច្ចព្រមព្រៀងនេះ យើងអាចចោទជាសំណួរបានថា ក្នុងក្របខណ្ឌជាក់ស្តែង ថា "*តើកម្ពុជាពិតជាទទួលបាននូវឱកាស ឬកម្ពុជាពិតជាមាននូវសក្តានុពលគ្រប់គ្រាន់ក្នុងការទាញអត្ថប្រយោជន៍ជាអតិបរមាចេញពីកិច្ចព្រមព្រៀងនេះដែរ ឬយ៉ាងណា?*" ដើម្បីអាចឆ្លើយនូវសំណួរនេះបាន បើទោះបីជាមិនត្រឹមត្រូវទាំងស្រុង យើងចាំបាច់ត្រូវស្វែងយល់ពីស្ថានភាពជាក់ស្តែងទាក់ទងនឹងបញ្ហាប្រឈមដែលកម្ពុជាមាន ដែលបញ្ហាទាំងនេះនឹងក្លាយទៅជាឧបសគ្គដ៏ធំសម្រាប់កម្ពុជា ក្នុងការក្តោបយកឱកាសក្នុងការនាំចេញនូវផលិតផលរបស់ខ្លួនទៅកាន់ទីផ្សារប្រទេសចិន។

នៅក្នុងជំពូកនេះ យើងនឹងធ្វើការសិក្សា វិភាគ និងបង្ហាញនូវបញ្ហាប្រឈមនានាដែលកម្ពុជាកំពុងមាន ឬអាចនឹងជួបប្រទះទាំងក្នុងក្របខណ្ឌនៃផលិតកម្ម ដំណើរការអនុវត្ត ក៏ដូចជាត្រួតពិនិត្យអំពីប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះ។ លទ្ធផលនៅក្នុងជំពូកនេះ បានមកពីកិច្ចពិភាក្សាជាមួយជាមួយមន្ត្រីជំនាញរបស់ក្រសួងពាណិជ្ជកម្ម និងអ្នកជំនាញតាមវិស័យមួយចំនួនដូចជាវិស័យកសិកម្ម សេដ្ឋកិច្ច ឧស្សាហកម្ម និងសេវាកម្មជាដើម។ ក្រៅពីនេះ យើងក៏បានសិក្សា និងវិភាគទៅលើអត្ថបទស្រាវជ្រាវ អត្ថបទវិភាគរបស់អ្នកជំនាញ ព្រមទាំងអត្ថបទចេញពីគេហទំព័រជំនាញឯកទេស ឬសារព័ត៌មានជាតិ និងអន្តរជាតិនានាផងដែរ។

## ៣.១. បញ្ហាប្រឈមក្នុងវិស័យផលិតកម្ម

ក្រោយពីទទួលបានសន្តិភាពពេញលេញ គេសង្កេតឃើញថាកម្ពុជាបានដើរក្នុងផ្លូវដ៏ត្រឹមត្រូវ ក្នុងការរក្សាសន្តិភាព ក៏ដូចជាការអភិវឌ្ឍប្រទេសលើគ្រប់វិស័យទាំងមូល។ ជាក់ស្តែង ក្នុងអំឡុងពេល

ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ វិស័យនានាដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិនិងសង្គម ទទួលបាននូវកំណើន និងការអភិវឌ្ឍគួរជាទីមោទនៈ។ ក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន និងដើម្បីទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនជាអតិបរមា ការពង្រីកនូវផលិតកម្មរាល់មុខទំនិញទាំងឡាយ និងការបង្កើនការវិនិយោគបន្ថែមទៅលើផលិតផលដែលមានស្រាប់ និងផលិតផលថ្មីៗ គឺជារឿងចាំបាច់បំផុតសម្រាប់កម្ពុជា។ ដោយមិនអាចប្រកែកបាន ផលិតកម្មក្នុងវិស័យនានាដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចកម្ពុជាបាននឹងកំពុងប្រឈមមុខនឹងបញ្ហាជាច្រើន ដែលបញ្ហាទាំងនេះអាចជាបញ្ហាថ្មីថ្មោង និងខ្លះទៀតកើតមានជាយូរមកហើយ។ ដើម្បីឆ្លើយតបទៅនឹងវិសាលភាពនៃក្របខណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន បញ្ហាប្រឈមដែលនឹងលើកយកមកសិក្សា និងវិភាគគឺផ្តោតជាសំខាន់ទៅលើផលិតកម្មក្នុងវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។

### ៣.១.១. បញ្ហាប្រឈមក្នុងវិស័យកសិកម្ម

វិស័យកសិកម្ម ត្រូវបានគេចាត់ទុកថាជាវិស័យមួយដែលដើរតួយ៉ាងសំខាន់សម្រាប់ឆ្អឹងខ្នងសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា ជាពិសេសសេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋទូទៅ។ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២០% ក្នុងផលិតផលជាតិសរុប និងមានប្រជាពលរដ្ឋប្រមាណ ៦៥% ប្រកបមុខរបរនេះ (Husain Haider, 2021)។ គេសង្កេតឃើញថា បើទោះបីជាវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន បានផ្តោតជាសំខាន់លើវិស័យកសិកម្មក្តី ប៉ុន្តែបើផ្អែកលើស្ថានភាពបច្ចុប្បន្នកម្ពុជាពុំទាន់អាចទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនពីវិស័យនេះនៅឡើយទេ។ ជាក់ស្តែង គេពិនិត្យឃើញមានបញ្ហាប្រឈមជាច្រើនដែលកំពុងកើតមាននៅក្នុងវិស័យកសិកម្ម ដែលបញ្ហាទាំងនេះក៏បានធ្វើឱ្យប៉ះពាល់ដល់ផលិតកម្ម ក៏ដូចជាលទ្ធភាពប្រកួតប្រជែងនៃមុខទំនិញនានាក្នុងវិស័យនេះ ក្នុងទីផ្សារបរទេស ក៏ដូចជាទីផ្សារប្រទេសចិនផងដែរ។ អ្នកជំនាញខាងសេដ្ឋកិច្ច និងកសិកម្មដែលបានចូលរួមក្នុងការសិក្សានេះ បានកំណត់នូវបញ្ហាប្រឈមសំខាន់ៗក្នុងវិស័យកសិកម្មចំនួនប្រាំចំណុចដូចជា៖ (១) កង្វះការវិនិយោគក្នុងវិស័យកសិកម្ម, (២) តម្លៃផលិតកម្មខ្ពស់, (៣) គុណភាពនិងបរិមាណទាប, (៤) បញ្ហាទាក់ទងនឹងទីផ្សារផលិតផលកសិកម្ម និង (៥) ខ្វះការកែច្នៃផលិតផលកសិកម្ម។ ជាក់ស្តែង បញ្ហាប្រឈមទាំងនេះមួយចំនួនមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ដែលយើងពិបាកនឹងកាត់ផ្តាច់ពីគ្នាបាន ហើយវាក៏មានការពឹងផ្អែកលើគ្នាទៅវិញទៅមកតាមរូបភាពជាច្រើនផងដែរ។

## ក) កង្វះការវិនិយោគ

តាមទិន្នន័យពីគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ការវិនិយោគដោយផ្ទាល់ពីបរទេសបានផ្តោតទៅលើវិស័យមួយចំនួនដូចជា វិស័យឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ (៥៣%) វិស័យទេសចរណ៍ (៤១%) និងវិស័យកសិកម្ម (៦%)។ ជាមួយនឹងតួលេខនេះ យើងសង្កេតឃើញថា វិស័យកសិកម្មកម្ពុជាទទួលបានការវិនិយោគតិចជាងគេខ្លាំងបើធៀបនឹងវិស័យផ្សេងៗ។ កង្វះការវិនិយោគក្នុងវិស័យនេះ ក៏បានធ្វើឱ្យប៉ះពាល់ ឬបង្កើតឱ្យមានបញ្ហាប្រឈមទៅលើផលិតភាព និងតម្លៃផលិតកម្មផងដែរ។ ទាក់ទងនឹងចំណុចនេះ លោកបណ្ឌិតឆេង គឹមឡុងបានមានប្រសាសន៍គូសបញ្ជាក់ថា៖

> *"ការវិនិយោគផ្នែកមូលធនលើវិស័យកសិកម្មកម្ពុជានៅមានកម្រិតទាប បានធ្វើឱ្យផលិតភាពនិងគុណភាពទទួលបានមានកម្រិតទាប និងតម្លៃផលិតកម្មក៏ថ្លៃផងដែរ"*

ជាក់ស្តែង ការវិនិយោគក្នុងវិស័យកសិកម្មនៅកម្ពុជាច្រើនតែមានទម្រង់តូចៗជាងការវិនិយោគក្នុងវិស័យផ្សេងទៀត ដោយឡែកការវិនិយោគទៀតសោធ ក៏ពុំមានភាពសម្បូរបែបផងដែរ។ គេសង្កេតឃើញថា ការវិនិយោគក្នុងវិស័យកសិកម្ម ច្រើនតែផ្តោតលើដំណាំយុទ្ធសាស្ត្រមួយចំនួនដូចជាដូងប្រេង កៅស៊ូ និងដំណាំចេកជាដើម។

## ខ) តម្លៃផលិតកម្មខ្ពស់

យើងដឹងហើយថា ក្នុងការធ្វើពាណិជ្ជកម្ម ក្រៅពីកត្តាគុណភាព តម្លៃក៏ជាកត្តាកំណត់ដ៏សំខាន់បំផុតមួយផងដែរក្នុងការប្រកួតប្រជែងលើទីផ្សារសេរី។ ជាក់ស្តែង ដោយសារតែស្ថានភាពជាក់ស្តែងនៃវិស័យកសិកម្មរបស់កម្ពុជា ស្ទើរតែគ្រប់ផលិតផលកសិកម្មដែលផលិតនៅក្នុងស្រុក មានតម្លៃខ្ពស់ជាងផលិតផលរបស់ប្រទេសជិតខាងរបស់ខ្លួនដូចជាប្រទេសថៃ និងវៀតណាមជាដើម។ រហូតមកដល់ពេលនេះ ទាំងរាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា នៅពុំទាន់អាចកំណត់បាននូវយុទ្ធសាស្ត្រ ឬកវិធានការ និងដំណោះស្រាយឱ្យបានសមស្របនៅឡើយទេចំពោះលើបញ្ហានេះ។ តាមរយៈការស្រាវជ្រាវពីឯកសារពាក់ព័ន្ធនានា ក៏ដូចជាការសម្ភាសជាមួយនឹងអ្នកជំនាញក្នុងវិស័យនេះ យើងអាចកំណត់បាននូវកត្តាសំខាន់ៗមួយចំនួន ដែលបានចូលរួមចំណែកក្នុងការធ្វើឱ្យតម្លៃផលិតកម្មក្នុងវិស័យកសិកម្មរបស់កម្ពុជាមានតម្លៃខ្ពស់។ កត្តាទាំងនេះមានដូចខាងក្រោម៖

### ○ កង្វះខាតវត្ថុធាតុដើមផលិតកម្ម

វត្ថុធាតុដើមកសិកម្មរាប់តាំងពីគ្រាប់ពូជ ជីរ ថ្នាំសម្លាប់សត្វល្អិត និងបរិក្ខាកសិកម្មជាច្រើនទៀតគឺជាកត្តាដ៏សំខាន់ដែលមិនត្រឹមតែចូលរួមកំណត់នូវគុណភាពផលិតផលប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានតួនាទីយ៉ាងសំខាន់ផងដែរក្នុងការកំណត់តម្លៃផលិតកម្មក្នុងវិស័យនេះ។ ជាក់ស្តែង រហូតមកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផលិតវត្ថុធាតុដើមកសិកម្មដូចជា គ្រាប់ពូជ ជីរ ថ្នាំផ្លែផ្កា ឬថ្នាំសម្លាប់សត្វល្អិតជាដើមឱ្យបានសម្បូរបែប ដើម្បីបំពេញតម្រូវរបស់ប្រជាកសិកររបស់ខ្លួននៅឡើយទេ។ គេសង្កេតឃើញថា កសិករកម្ពុជាតែងតែស្វះស្វែងរកទិញវត្ថុធាតុដើមកសិកម្ម ដែលមានប្រភពពីប្រទេសជិតខាង ឬប្រទេសផ្សេងទៀតដើម្បីបន្តការដាំដុះរបស់ខ្លួនជាប្រចាំ។ ការពឹងផ្អែកស្ទើរទាំងស្រុងទៅលើវត្ថុធាតុដើមកសិកម្ម ដែលនាំចូលពីបរទេសបានធ្វើឱ្យតម្លៃផលិតកម្មក្នុងស្រុកមានការកើនឡើងយ៉ាងខ្លាំង ជាពិសេសបើធៀបជាមួយនឹងប្រទេសជិតខាង។ ជាមួយនឹងស្ថានភាពតម្លៃផលិតផលទាំងនេះនៅលើទីផ្សារ ដែលតែងតែមានការប្រែប្រួលជាប្រចាំស្រាប់ទៀត បានធ្វើឱ្យការចំណាយរបស់ប្រជាកសិករមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ជាការពិត កម្ពុជាក៏មានសិប្បកម្មក្នុងស្រុកមួយចំនួនផងដែរ ដែលកំពុងដំណើរការផលិតថ្នាំសម្លាប់សត្វល្អិត ជីរ និងវត្ថុធាតុដើមមួយចំនួនទៀត ក៏ប៉ុន្តែតម្លៃ និងគុណភាពនៃផលិតផលទាំងនោះនៅពុំទាន់អាចធ្វើការប្រកួតប្រជែងបានជាមួយនឹងផលិតផលប្រភេទដូចគ្នា ដែលនាំចូលពីបរទេសនៅឡើយទេ។ ម្យ៉ាងទៀត ទាក់ទងនឹងកត្តាមួយនេះ លទ្ធផលស្រាវជ្រាវក៏បានបង្ហាញផងដែរថា វត្ថុធាតុដើមកសិកម្មដែលផលិតក្នុងស្រុកទាំងនេះ នៅមិនទាន់មានភាពសម្បូរបែប និងមិនអាចឆ្លើយតបទៅតាមស្ថានភាពជាក់ស្តែងនៃគុណភាពដី អាកាសធាតុ ឬបច្ចេកទេសដាំដុះរបស់ប្រជាពលរដ្ឋនៅតាមតំបន់ផ្សេងៗនៅឡើយទេ។

### ○ ឧបករណ៍ និងបរិក្ខារកសិកម្ម

ឧបករណ៍ និងបរិក្ខារកសិកម្មបានដើរតួយ៉ាងសំខាន់ក្នុងដំណើរការផលិតកម្មក្នុងវិស័យនេះ ជាពិសេសការកែប្រែទម្លាប់នៃការដាំដុះបែបប្រពៃណី មកជាការដាំដុះបែបទំនើប ឬការដាំដុះដោយប្រើប្រាស់បច្ចេកទេសខ្ពស់ជាដើម។ ជាមួយនឹងការទទួលយកនូវបច្ចេកទេសដាំដុះថ្មីៗ និងទំនើបជាងមុន កម្ពុជាមានតម្រូវការខ្ពស់លើបរិក្ខារកសិកម្មគ្រប់ប្រភេទ រួមទាំងយានយន្ត ឬម៉ាស៊ីនធុនតូច មធ្យម និង

ធំជាដើម។ តាមរយៈបទពិសោធន៍របស់ប្រទេសដែលមានកសិកម្មជឿនលឿន គេសង្កេតឃើញថា ការប្រើប្រាស់ឧបករណ៍ ឬបរិក្ខារកសិកម្មទំនើបៗ ក្នុងដំណើរការផលិតកម្មនានាមិនត្រឹមតែបានចូលរួមក្នុងការកាត់បន្ថយនូវតម្លៃដើមផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងចូលរួមចំណែកក្នុងគុណភាពផលិតផល ចំណេញពេលវេលា និងកម្លាំងពលកម្មផងដែរ។

យើងសង្កេតឃើញថា ក្នុងមួយឆ្នាំៗ កម្ពុជាបានធ្វើការនាំចូលនូវឧបករណ៍ និងបរិក្ខារកសិកម្មយ៉ាងច្រើនប្រភេទពីប្រទេសជិតខាង ក៏ដូចជាប្រទេសនានាផ្សេងទៀតដើម្បីបំពេញតម្រូវការកសិករក្នុងស្រុក។ ដោយមិនគិតទៅលើបរិក្ខារធុនធ្ងន់ដូចជាយានយន្ត និងម៉ាស៊ីននានាជាដើម នាពេលបច្ចុប្បន្នកម្ពុជាមានលទ្ធភាពតិចតួចប៉ុណ្ណោះក្នុងការផលិត ឬកែច្នៃឧបករណ៍ និងបរិក្ខារកសិកម្មនានា ហើយចំពោះគុណភាពក៏មានកម្រិត និងតម្លៃទៀតសោធក៏ខ្ពស់ផងដែរ។ ការពឹងផ្អែកខ្លាំងទៅលើឧបករណ៍ និងបរិក្ខារកសិកម្មនាំចូលពីបរទេស បានធ្វើឱ្យផលិតផលកសិកម្មរបស់កម្ពុជាបានបាត់បង់នូវលទ្ធភាពប្រកួតប្រជែង មិនត្រឹមតែទីផ្សារក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែក៏អាចនឹងបាត់បង់នូវលទ្ធភាពប្រកួតប្រជែងផ្នែកតម្លៃលើទីផ្សារបរទេសថែមទៀត។ ទឡ្ហីករណ៍នេះ យើងតែងតែឃើញជារឿយៗនូវការចាញ់ប្រៀបក្នុងការប្រកួតប្រជែងផ្នែកតម្លៃតាមរយៈផលិតផលបន្លែ និងផ្លែឈើកម្ពុជាជាមួយនឹងបន្លែ និងផ្លែឈើនាំចូលពីប្រទេសជិតខាងជាពិសេសប្រទេសវៀតណាម (លី, ត. et al., 2020)។

### ○ ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម

ក្រៅពីកត្តាទាំងពីរខាងលើ យើងសង្កេតឃើញថា ទឹកគឺជាធនធានធម្មជាតិដែលមិនអាចខ្វះបានសម្រាប់ការបង្កបង្កើនផលដំណាំកសិកម្មគ្រប់ប្រភេទ ហើយវាក៏បានដើរតួយ៉ាងសំខាន់ក្នុងការកំណត់នូវបរិមាណទិន្នផល គុណភាព និងតម្លៃផលិតកម្មក្នុងវិស័យនេះផងដែរ។ ផ្អែកលើកត្តាទីតាំងភូមិសាស្ត្រ អាកាសធាតុ និងសណ្ឋានដី យើងអាចនិយាយបានថា កម្ពុជាមានអំណោយផលខ្ពស់ចំពោះវិស័យកសិកម្ម និងការដាំដុះដំណាំកសិកម្មគ្រប់។ អាកាសធាតុត្រូពិក សណ្ឋានដីរាងបាតខ្ទះរបបទឹកភ្លៀងគ្រប់គ្រាន់ និងប្រព័ន្ធផ្លូវទឹកធម្មជាតិ (អូរ ស្ទឹង បឹង បួរ និងទន្លេជាដើម) ខ្វាត់ខ្វែងស្ទើរពាសពេញប្រទេស ប៉ុន្តែកម្ពុជានៅតែជួបប្រទះនូវបញ្ហាកង្វះទឹកសម្រាប់វិស័យកសិកម្ម។ យើងសង្កេតឃើញថា កម្ពុជាពុំទាន់អាចទាញយកទឹកពីប្រភពធម្មជាតិទាំងនោះ មកធ្វើការស្រោចស្រពដំណាំរបស់ខ្លួនឱ្យបានតាមតម្រូវការនោះទេ ហើយជារឿយៗ ប្រជាកសិករកម្ពុជាតែងតែជួបប្រទះនឹងបញ្ហាខ្វះ

ខាតទឹកសម្រាប់បង្កបង្កើនផលដំណាំ។ កម្ពុជាមានប្រព័ន្ធទន្លេ បឹង បួរ ស្ទឹង អូរ ព្រមទាំងរបបទឹកភ្លៀងគ្រប់គ្រាន់ ប៉ុន្តែយើងខ្វះវិធីសាស្ត្រ ឬហេដ្ឋារចនាសម្ព័ន្ធសមស្របដើម្បីប្រមូលទឹកទុក ចែកចាយ ឬបង្វែរទឹកទាំងនោះដើម្បីបំពេញតម្រូវការកសិកម្ម (លី, ត. et all., ២០២០)។ លទ្ធផលនៃការស្រាវជ្រាវនេះ បានបង្ហាញថា ក្រៅពីប្រព័ន្ធទឹកធម្មជាតិដែលមានស្រាប់ កម្ពុជាពុំទាន់មានប្រព័ន្ធធារាសាស្ត្រត្រឹមត្រូវ[3] ដើម្បីស្តុកទឹកទុក ឬចែកចាយឱ្យប្រជាពលរដ្ឋធ្វើការដាំដុះឱ្យបានខួបប្រាំងវស្សានោះទេ។ ប្រជាកសិករចាំបាច់ត្រូវចំណាយថវិកាច្រើន ក្នុងការជីកស្រះ អណ្តូង ឬបូមទឹកពីទីឆ្ងាយដើម្បីស្រោចស្រពដំណាំរបស់ខ្លួន។ ការចំណាយថវិកាច្រើនទៅលើការបូមទឹក ការជីកស្រះ ឬអណ្តូង បានធ្វើឱ្យតម្លៃដើមផលិតកម្មរបស់ប្រជាកសិករកម្ពុជាមានការកើនឡើងខ្ពស់ និងពិបាកប្រកួតប្រជែងជាមួយនឹងផលិតផលកសិកម្មនាំចូលពីបរទេស។

កង្វះខាតនូវប្រព័ន្ធធារាសាស្ត្រសម្រាប់វិស័យកសិកម្មនេះ មិនត្រឹមតែធ្វើឱ្យតម្លៃផលិតកម្មកើនឡើងប៉ុណ្ណោះទេ ក៏ប៉ុន្តែវាក៏បានប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់សម្រាប់ការលូតលាស់របស់ផលដំណាំគ្រប់ប្រភេទផងដែរ។ ម្យ៉ាងទៀត កង្វះខាតនូវទឹកសម្រាប់ស្រោចស្រពដំណាំ ក៏បានធ្វើឱ្យកើតមាននូវជំងឺនានា និងប៉ះពាល់ដល់បរិមាណផលិតផលផងដែរ (Sithirith, 2017)។ បន្ថែមពីលើនេះ កង្វះខាតនូវប្រព័ន្ធធារាសាស្ត្រសមស្រប ក៏អាចធ្វើឱ្យការដាំដុះដំណាំកសិកម្មរបស់ប្រជាពលរដ្ឋប្រឈមនឹងការជន់លិចផងដែរ។

### ○ បច្ចេកទេស និងទម្លាប់ដាំដុះ

លទ្ធផលនៃការស្រាវជ្រាវនេះ ក៏ដូចជាការស្រាវជ្រាវរបស់ លី, ត. et all. (២០២០) ក៏បានបង្ហាញផងដែរថា បច្ចេកទេសនៃការដាំដុះដំណាំកសិកម្មរបស់ប្រជាកសិករកម្ពុជានៅមានកម្រិតទាបដោយការដាំដុះមានលក្ខណៈប្រពៃណីច្រើន ធ្វើឱ្យចំណាយកម្លាំងពលកម្ម និងដើមទុនច្រើន។ បើធៀបជាមួយនឹងប្រទេសជិតខាង គេប្រើប្រាស់គ្រឿងចក្រសម្បូរបែប បូកជាមួយនឹងបច្ចេកទេសនៃការដាំដុះប្រកបដោយគុណភាព និងប្រសិទ្ធភាព នោះមិនត្រឹមតែកាត់បន្ថយថ្លៃដើមផលិតកម្មប៉ុណ្ណោះទេ

[3] ប្រព័ន្ធធារាសាស្ត្រត្រឹមត្រូវនៅត្រង់ចំណុចនេះ ចង់សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានបច្ចេកទេសត្រឹមត្រូវ មានគុណភាព មានប្រព័ន្ធចែកចាយតូចៗចេញពីប្រភពស្តុកទឹក ទៅកាន់តំបន់បង្កបង្កើនផលដំណាំរបស់ប្រជាកសិករ។

ក៏ប៉ុន្តែបរិមាណផលិតផលក៏កើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ម្យ៉ាងទៀត ទម្លាប់នៃការដាំដុះរបស់ប្រជាកសិករកម្ពុជាមានលក្ខណៈតូចៗទៅលើដីដែលខ្លួនមាន ដែលកត្តាទាំងនេះ ក៏បានរួមចំណែកដល់ការកើនឡើងជារួមលើតម្លៃផលិតកម្មផងដែរ។ ដោយមិនគិតលើការដាំដុះដំណាំយុទ្ធសាស្ត្រមួយចំនួនដែលទទួលបានការវិនិយោគពីអ្នកជំនួញក្នុងស្រុក ឬបរទេស យើងពិនិត្យឃើញថា ផ្ទៃដីដាំដុះ និងការដាំដុះមានលក្ខណៈគ្រួសារ និងស្ថិតនៅរាយប៉ាយ។ ការដាំដុះក្រោមទម្រង់នេះ ធ្វើឱ្យមានការពិបាកក្នុងការរៀបចំរចនាសម្ព័ន្ធទឹក និងជាពសាស្ត្រឱ្យបានសមស្រប ក៏ដូចជាពិបាកផងដែរក្នុងការរក្សាឱ្យបាននូវបរិមាណទិន្នផល គុណភាព ការបណ្តុះបណ្តាលផ្នែកបច្ចេកទេស ក៏ដូចជាការទទួលបាននូវប្រភពទុនសម្រាប់ពង្រីកការដាំដុះផងដែរ។

### គ) គុណភាពនិងបរិមាណទាប

ដូចដែលបានបញ្ជាក់ពីខាងលើ ក្រៅពីតម្លៃ កត្តាគុណភាពក៏បានដើរតួយ៉ាងចម្បងក្នុងលទ្ធភាពនៃការប្រកួតប្រជែងផ្នែកទីផ្សារសម្រាប់ផលិតផលគ្រប់ប្រភេទ មិនត្រឹមតែផលិតផលកសិកម្មប៉ុណ្ណោះទេ។ បើយើងពិនិត្យទៅលើទំនិញកសិកម្មរបស់កម្ពុជា យើងឃើញថាមានផលិតផលកសិកម្មជាច្រើនប្រភេទ ពុំទាន់មានគុណភាពស្របតាមស្តង់ដាសម្រាប់ការនាំចេញនៅឡើយទេ។ ជាឧទាហរណ៍ បើទោះបីជាកន្លងមក កម្ពុជាធ្លាប់បានធ្វើការនាំចេញផលិតផលអង្ករទៅកាន់ទីផ្សារអន្តរជាតិជាច្រើនក្តី ក៏សង្កេតឃើញមានព័ត៌មានថាអង្កររបស់កម្ពុជាមួយចំនួនខ្វះគុណភាព ឬមានគុណភាពពុំស្របនឹងបទដ្ឋានកំណត់របស់ប្រទេសធំៗមួយចំនួនផងដែរ។ កត្តាគុណភាពនេះ បានក្លាយជាដើមហេតុក្នុងការបង្អាក់នូវការនាំចេញប្រភេទទំនិញជាច្រើនរបស់កម្ពុជាទៅកាន់ទីផ្សារពិភពលោក ព្រមទាំងបានធ្វើឱ្យកម្ពុជាបាត់បង់នូវការប្រកួតប្រជែងលើចំណែកទីផ្សារអន្តរជាតិផងដែរ។

ឧទាហរណ៍មួយទៀតទាក់ទងនឹងការផលិតស្រូវ ឬអង្ករនេះ គេសង្កេតឃើញថា កម្ពុជាពុំបានផ្តោតជាសំខាន់ទៅលើប្រភេទស្រូវដែលមានគុណភាពខ្ពស់នោះទេ (Aromatic Rice) ដែលផ្ទុយពីប្រទេសវៀតណាម និងថៃដែលគោលនយោបាយកសិកម្មរបស់ប្រទេសទាំងនេះ បានផ្តោតជាសំខាន់ទៅលើប្រភេទស្រូវដែលមានតម្លៃ និងគុណភាពខ្ពស់ដើម្បីធ្វើការនាំចេញទៅក្រៅប្រទេស។ នេះគ្រាន់តែជាឧទាហរណ៍មួយនៃដំណាំស្រូវប៉ុណ្ណោះ ដែលជាក់ស្តែង កម្ពុជានៅមានផលិតផលកសិកម្មជា

ច្រើនប្រភេទទៀតដែលមានលំនាំប្រហាក់ប្រហែលនេះ និងខ្លះទៀតជាប្រភេទដំណាំល្អ ប៉ុន្តែដោយសារតែកង្វះខាតនូវបច្ចេកទេសដាំដុះ ការថែទាំ និងកត្តាផ្សេងទៀត បានធ្វើឱ្យផលិតផលដែលផលិតបានមានគុណភាពទាបជាងការរំពឹងទុក។

ក្រៅពីកត្តាគុណភាពដែលបានលើកឡើងនេះ បញ្ហាបរិមាណទិន្នផលទាបក៏ជាបញ្ហាចោទមួយផងដែរសម្រាប់កម្ពុជា។ បើធៀបទៅនឹងផ្ទៃដីដាំដុះ បរិមាណផលិតកម្មរបស់កម្ពុជានៅមានកម្រិតទាបដោយផលិតករភាគច្រើន ពុំទាន់អាចទាញយកអត្ថប្រយោជន៍ឱ្យបានជាអតិបរមាចេញពីផ្ទៃដីដាំដុះជាក់ស្តែងរបស់ខ្លួនបាននៅឡើយទេ។ មានកត្តាជាច្រើនដែលបានរួមចំណែកក្នុងបញ្ហាមួយនេះ ដែលមានដូចជា កង្វះខាតនូវគោលនយោបាយទឹក បញ្ហាវត្ថុធាតុដើមកសិកម្មពុំសមស្របនឹងស្ថានភាពដីធ្លី និងអាកាសធាតុរបស់ខ្លួនជាដើម។ ជាមួយនឹងកង្វះខាតទឹក បានធ្វើឱ្យការដាំដុះដែលអាចត្រូវធ្វើបាន ២-៣ដងក្នុងមួយឆ្នាំ បែរជាពុំអាចធ្វើបាន ដែលធ្វើឱ្យកសិករកម្ពុជាខាតបង់នូវការប្រើប្រាស់ដីកសិកម្មដែលគាត់មានឱ្យអស់លទ្ធភាព។ ម្យ៉ាងទៀត ការប្រើប្រាស់វត្ថុធាតុដើមកសិកម្មមិនសូវសមស្របនឹងស្ថានភាពដី និងអាកាសធាតុរបស់កម្ពុជា ដែលជាហេតុធ្វើឱ្យទិន្នផលមិនបានពេញលេញ និងប៉ះពាល់ដល់គុណភាពផងដែរ។

## ឃ) បញ្ហាទីផ្សារផលិតផលកសិកម្ម

ក្រៅពីបញ្ហាទាក់ទងនឹងវត្ថុធាតុដើមកសិកម្ម តម្លៃ គុណភាពនិងបរិមាណដូចដែលបានរៀបរាប់ខាងលើ គេក៏សង្កេតឃើញថា កត្តាទីផ្សារផលិតផលកសិកម្មក៏ជាបញ្ហាចម្បងមួយផងដែរក្នុងវិស័យកសិកម្មរបស់កម្ពុជា។ គេសង្កេតឃើញថា ស្ទើររៀងរាល់ឆ្នាំ ប្រជាកសិករកម្ពុជាតែងតែជួបប្រទះនឹងបញ្ហាទីផ្សារកសិផលរបស់ពួកគាត់ ដែលបញ្ហានេះបានលេចចេញក្នុងរូបភាពផ្សេងៗដូចជា គ្មានតម្រូវការផលិតផល ឬផលិតផលលើសតម្រូវការ ឬការធ្លាក់ថ្លៃជាដើម។ បើទោះបីជាបញ្ហានេះពុំកើតឡើងជាមួយនឹងផលិតផលដដែលក្តី ក៏វាបានក្លាយទៅជាក្តីកង្វល់ដ៏ធំមួយរបស់ប្រជាកសិករកម្ពុជាទូទៅ។ ជាមួយនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កម្ពុជាក៏សង្ឃឹមថាកិច្ចព្រមព្រៀងនេះ នឹងអាចដើរតួយ៉ាងសកម្ម ក្នុងការចូលរួមដោះស្រាយបញ្ហាទីផ្សារផលិតផលកសិកម្មរបស់ខ្លួនឱ្យបានកាន់តែប្រសើរជាងមុន។

### ខ) ខ្វះការកែច្នៃផលិតផលកសិកម្ម

បន្ថែមពីលើចំណុចសំខាន់ៗដែលបានរៀបរាប់ខាងលើ យើងក៏សង្កេតឃើញថា កម្ពុជាពុំទាន់អាចទាញយកអត្ថប្រយោជន៍ឱ្យបានអតិបរមា ពីផលិតផលកសិកម្មដែលខ្លួនផលិតបាននៅឡើយទេ។ កម្ពុជាពឹងផ្អែកស្ទើរតែទាំងស្រុងលើការនាំចេញផលិតផលកសិកម្មស្រស់ៗសុទ្ធសាធ ដោយពុំបានធ្វើការកែច្នៃ ឬធ្វើការបង្កើនតម្លៃបន្ថែមទៅលើផលិតផលរបស់ខ្លួននៅឡើយទេ។ ការដែលពុំមានលទ្ធភាពក្នុងការកែច្នៃផលិតផលកសិកម្ម មិនត្រឹមតែធ្វើឱ្យកម្ពុជាបាត់បង់នូវចំណែកទីផ្សារផលិតផលកសិកម្មកែច្នៃប៉ុណ្ណោះទេ ប៉ុន្តែកង្វះខាតនូវបច្ចេកទេសកែច្នៃផលិតផលកសិកម្ម ក៏បានធ្វើឱ្យកសិករកម្ពុជាត្រូវបង្ខំចិត្តបោះបង់ចោលផលិតផលដែលលើសតម្រូវការ ឬផលិតផលដែលមិនស្របនឹងស្តង់ដានាំចេញជាដើម។

ដូចដែលបានបញ្ជាក់ពីខាងដើមថា បញ្ហាប្រឈមមួយចំនួនដែលបានលើកឡើងមានទំនាក់ទំនងនឹងគ្នា ឬយើងក៏អាចនិយាបានថាពឹងផ្អែកលើគ្នាទៅវិញទៅមកផងដែរ។ ឧទាហរណ៍ កង្វះខាតការវិនិយោគក្នុងវិស័យកសិកម្ម បានធ្វើឱ្យប៉ះពាល់ដល់បរិមាណទិន្នផល ហើយក៏អាចប៉ះពាល់ទៅដល់គុណភាពផលិតផលផងដែរ។ កង្វះខាតនៃការវិនិយោគក្នុងវិស័យកសិកម្ម ក៏អាចប៉ះពាល់ដល់ការស្រាវជ្រាវ និងអភិវឌ្ឍក្នុងវិស័យមួយផងដែរ ទាំងការស្រាវជ្រាវទៅលើគ្រាប់ពូជ វិធីសាស្ត្រផលិតកម្ម និងបច្ចេកវិទ្យាផលិតកម្មផងដែរ។ បន្ថែមពីលើនេះ កង្វះការវិនិយោគក្នុងវិស័យកសិកម្ម ក៏អាចធ្វើឱ្យតម្លៃផលិតផលកើនឡើង និងបាត់បង់ទីផ្សារផងដែរ។ ជាក់ស្តែង មានរូបភាពនៃទំនាក់ទំនង ឬការពឹងអាស្រ័យគ្នាទៅវិញទៅមក រវាងបញ្ហាប្រឈមទាំងនេះ ជាច្រើនទៀត ដែលយើងពុំអាចបកស្រាយបានអស់នៅក្នុងរបាយការណ៍ស្រាវជ្រាវមួយនេះ។

## ៣.១.២. បញ្ហាប្រឈមក្នុងវិស័យឧស្សាហកម្ម

បើទោះបីជាក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន បានផ្តោតជាសំខាន់ទៅលើផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្មក្តី ក៏ប៉ុន្តែផលិតផលក្នុងវិស័យឧស្សាកម្មជាច្រើនរបស់កម្ពុជាក៏បានស្ថិតក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ក៏ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិនផងដែរ។ ស្ថិតក្នុងបរិបទនេះ មានន័យថា ក្រៅពីទំនិញកសិកម្ម និងកសិ-ឧស្សាហកម្ម កម្ពុជាក៏អាចធ្វើ

ការនាំចេញទំនិញផ្សេងៗទៅកាន់ទីផ្សារប្រទេសចិនបានផងដែរ។ នៅក្នុងបរិបទបច្ចុប្បន្ន យើងសង្កេតឃើញថា វិស័យឧស្សាហកម្មរបស់កម្ពុជាពុំទាន់អាចបញ្ចេញសក្ដានុពលរបស់ខ្លួនបានដល់កម្រិតដែលអាចទាញយកអត្ថប្រយោជន៍បានជាអតិបរមានៅឡើយទេ ដែលបញ្ហាទាំងនេះ ក៏ដោយសារតែវិស័យឧស្សាហកម្មកម្ពុជាកំពុងមាននូវបញ្ហាប្រឈមមួយចំនួនដូចជា៖

## ក) កង្វះការវិនិយោគក្នុងស្រុក

បើធៀបជាមួយនឹងវិស័យផ្សេង វិស័យឧស្សាហកម្មកម្ពុជាទទួលបានការវិនិយោគច្រើនជាងគេ បើទោះជាយ៉ាងនេះក្ដី ការវិនិយោគក្នុងវិស័យនេះ ក៏ពុំទាន់មានភាពសម្បូរបែបនៅឡើយដែរ ដោយការវិនិយោគភាគច្រើនផ្ដោតលើផលិតកម្មសម្លៀកបំពាក់ និងផលិតផលកាត់ដេរផ្សេងៗទៀត។ បន្ថែមពីលើនេះ បើផ្អែកលើស្ថានភាពបច្ចុប្បន្ន យើងសង្កេតឃើញថា កម្ពុជាពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ដោយខ្លួនឯង ក្នុងការវិនិយោគលើវិស័យនេះដែរ ដោយភាគច្រើននៃវិនិយោគទុនក្នុងវិស័យនេះគឺមានប្រភពពីបរទេស។ ការពឹងផ្អែកលើការវិនិយោគពីបរទេសទាំងស្រុងអាចវាជាហានិភ័យសម្រាប់កម្ពុជាក្នុងពេលមានវិបត្តិសេដ្ឋកិច្ចណាមួយកើតឡើង ដោយអ្នកវិនិយោគទាំងនោះអាចនឹងវេចបង្វេចត្រឡប់ទៅស្រុកគេវិញ។ ក្នុងករណីបែបនេះ វិស័យឧស្សាកម្មរបស់កម្ពុជានឹងជួបនូវវិបត្តិធ្ងន់ធ្ងរ ដោយមិនត្រឹមតែកម្ពុជាអាចបាត់បង់នូវលទ្ធភាគផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ការងារ និងប្រាក់ចំណូលរបស់ជាតិផងដែរ។

ពាក់ព័ន្ធនឹងចំណុចនេះ ការស្រាវជ្រាវក៏បានបង្ហាញបន្ថែមថា កម្ពុជាខ្វះការវិនិយោគលើប្រភេទផលិតផលឧស្សាហកម្មដែលអាចពឹងអាស្រ័យគ្នាទៅវិញទៅមកបាន ដោយផលិតផលមួយ ឬច្រើនប្រភេទ អាចដើរតួជាគ្រឿងផ្សំ សម្រាប់ផលិតផលឧស្សាហកម្មប្រភេទផ្សេងទៀត។ ម្យ៉ាងទៀត កម្ពុជាក៏ពុំសូវបានផ្ដោតលើការវិនិយោគលើប្រភេទផលិតផលឧស្សាហកម្មដែលជាតម្រូវការប្រចាំថ្ងៃ ឬតម្រូវការរបស់ប្រជាពលរដ្ឋក្នុងស្រុកផងដែរ ដោយទំនិញដែលទទួលបានការវិនិយោគច្រើនជាងគេគឺផ្ដោតលើទីផ្សារនាំចេញទៅក្រៅប្រទេសច្រើនជាង។ ក្រៅពីនេះ យើងក៏សង្កេតឃើញថា កម្ពុជាក៏ពុំសូវទទួលបានការវិនិយោគទៅលើផលិតកម្មវត្ថុធាតុដើមសម្រាប់បម្រើឱ្យវិស័យឧស្សាហកម្មផងដែរ ដែលករណីនេះបានធ្វើឱ្យកម្ពុជាត្រូវពឹងផ្អែកលើការនាំចូលនូវវត្ថុធាតុដើមពីបរទេសស្ទើរទាំងស្រុង។

### ខ) បញ្ហាបច្ចេកវិទ្យាបែបនវានុវត្តន៍

ក្រៅពីកង្វះខាតការវិនិយោគលើប្រភេទផលិតផលឱ្យកាន់តែសម្បូរបែប យើងក៏សង្កេតឃើញថា ការវិនិយោគក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ពុំទាន់មានប្រើប្រាស់នូវបច្ចេកវិទ្យាបែបទំនើបៗ ឬបច្ចេកវិទ្យាបែបនវានុវត្តន៍ខ្ពស់ៗនៅឡើយទេ ដោយផលិតកម្មភាគច្រើនគឺធ្វើឡើងដោយដៃ (មនុស្សធ្វើដោយផ្ទាល់) ជាជាងការផលិតដោយប្រើម៉ាស៊ីនស្វ័យប្រវត្តិ។ ជាក់ស្តែង ការប្រើប្រាស់កម្លាំងពលកម្មមនុស្សច្រើនក្នុងផលិតកម្ម យើងទទួលបានផលចំណេញខាងផ្នែកការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋ ក៏ប៉ុន្តែវាក៏បានផ្តល់មកវិញនូវគុណវិបត្តិមួយចំនួនផងដែរដូចជាផលិតកម្មមានតម្លៃថ្លៃដើមថ្លៃ ផលិតកម្មទទួលបានបរិមាណតិច និងគុណភាពក៏ទាបជាដើម។

### គ) បញ្ហាវត្ថុធាតុដើម

វត្ថុធាតុដើមបានដើរតួយ៉ាងសំខាន់ក្នុងវិស័យផលិតកម្ម មិនថាក្នុងវិស័យកសិកម្ម ឬឧស្សាហកម្មនោះទេ។ មិនខុសពីវិស័យកសិកម្ម យើងសង្កេតឃើញថា វិស័យឧស្សាហកម្មរបស់កម្ពុជាក៏ពឹងផ្អែកស្ទើរទាំងស្រុងទៅលើវត្ថុធាតុដើមនាំចូលពីបរទេស ជាពិសេសប្រទេសចិន។ ការពឹងផ្អែកលើវត្ថុធាតុដើមនាំចូលពីបរទេស អាចនឹងធ្វើឱ្យវិស័យឧស្សាហកម្មរបស់កម្ពុជាមានលទ្ធភាពទាបក្នុងការប្រកួតប្រជែងផ្នែកតម្លៃ មិនចំពោះតែសម្រាប់ការផ្គត់ផ្គង់ក្នុងស្រុកប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ប៉ះពាល់ខ្លាំងផងដែរទៅលើលទ្ធភាពនៃការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ។ ក្រៅពីប៉ះពាល់ខ្លាំងដល់លទ្ធភាពប្រកួតប្រជែងផ្នែកតម្លៃផលិតផលហើយ កង្វះខាតវត្ថុធាតុដើមឧស្សាហកម្ម ឬការពឹងផ្អែកលើការផ្គត់ផ្គង់វត្ថុធាតុដើមពីបរទេសក៏នឹងប៉ះពាល់ផងដែរដល់ខ្សែសង្វាក់ផលិតកម្មទាំងមូល។ ទឡ្ហីករណ៍នេះ យើងអាចពិនិត្យឃើញយ៉ាងច្បាស់អំពីការខ្វះខាតវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ និងឧស្សាហកម្មមួយចំនួនទៀតរបស់កម្ពុជាក្នុងវិបត្តិកូវីដ-១៩នេះ ដែលធ្វើឱ្យខ្សែសង្វាក់ផលិតកម្មរបស់រោងចក្រជាច្រើននៅកម្ពុជាត្រូវគាំង ផ្អាកដំណើរមួយរយៈធំផងដែរ។

## ៣.២. បញ្ហាប្រឈមក្នុងវិស័យសេវាកម្ម

ដោយសារតែមានការរីកចម្រើនក្នុងវិស័យបច្ចេកវិទ្យានិងទំនាក់ទំនង ធ្វើឱ្យវិស័យសេវាកម្មបានដើរតួយ៉ាងសំខាន់ក្នុងចរន្តសេដ្ឋកិច្ចពិភពលោក។ វិស័យមួយនេះ បានចូលរួមចំណែកប្រមាណ ពីរភាគ

បី (២/៣) នៃផលទុនសរុបនៃសេដ្ឋកិច្ចពិភពលោក ជាមួយគ្នានេះ ក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន វិស័យសេវាកម្មអាចទាក់ទាញការវិនិយោគដោយផ្ទាល់ពីក្រៅប្រទេសបានច្រើនជាងវិស័យណាៗទាំងអស់ (OECD.ORG)។ ជាក់ស្តែង វិស័យសេវាកម្មបានផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋទូទាំងពិភពលោកបានច្រើនជាងវិស័យផ្សេងៗ និងបានរួមចំណែកក្នុងការបង្កើតការងារថ្មីៗបានយ៉ាងច្រើនក្នុងមួយឆ្នាំៗ។ នៅក្នុងដំណើរការសេដ្ឋកិច្ច វិស័យសេវាកម្មបានគ្របដណ្តប់ទៅលើសកម្មភាពជាច្រើនដូចជា សេវាកម្មលើជំនាញគណនេយ្យ ផ្នែកច្បាប់ ធនាគារ បច្ចេកទេសកុំព្យូទ័រ ការបង្កើតកម្មវិធីឌីជីថលសម្រាប់គ្រប់គ្រងអាជីវកម្ម សេវាដឹកជញ្ជូន វិស័យទេសចរណ៍ បច្ចេកទេសវិស្វកម្ម និងសេវាទូរគមនាគមន៍ជាដើម។

ក្រៅពីវិស័យផលិតកម្មដូចជាកសិកម្ម ឧស្សាហកម្ម និងសិប្បកម្មជាដើម វិស័យសេវាកម្មបានដើរតួយ៉ាងសំខាន់ក្នុងការដោះដូរពាណិជ្ជកម្មអន្តរជាតិរវាងប្រទេសជាដៃគូ និងរវាងតំបន់និងតំបន់។ ជាទូទៅ ក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិលើវិស័យសេវាកម្ម ប្រទេសដែលជាដៃគូតែងតែធ្វើការផ្ទោះប្តូរផលិតផលសេវាកម្មជាមួយគ្នាក្រោមរូបភាពបួនដូចខាងក្រោម (Beaulieu, 2007)៖

### ១ រូបភាពទី១៖ ការផ្គត់ផ្គង់ឆ្លងដែន (Cross-Border Supply)

ក្នុងរូបភាពនេះ ផលិតផលបែបសេវាកម្មត្រូវបានផ្គត់ផ្គង់ពីប្រទេសមួយទៅប្រទេសមួយទៀត ដោយអ្នកផ្គត់ផ្គង់ និងអ្នកទទួលសេវាកម្មត្រូវស្ថិតនៅក្នុងប្រទេសរៀងៗខ្លួន ក៏ប៉ុន្តែសេវាកម្មត្រូវបានធ្វើចរាចរឆ្លងដែនរវាងប្រទេសជាដៃគូ។

**ឧទាហរណ៍៖**

ក្រុមហ៊ុនវិស្វកម្មឌីហ្សាញនិងរៀបចំប្លង់អគារសំណង់មួយក្នុងប្រទេសចិន បានធ្វើកិច្ចសន្យា *"ផ្តល់សេវាកម្មឌីហ្សាញអគារពាណិជ្ជកម្ម"* ឱ្យដៃគូអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ក្រោមរូបភាពនេះ អ្នកគូស និងឌីហ្សាញប្លង់ស្ថិតនៅក្នុងប្រទេសចិន និងត្រូវរៀបចំគម្រូប្លង់តាមតម្រូវការជាក់ស្តែង រួចផ្ញើទៅកាន់អតិថិជនជាដៃគូរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ក្នុងរូបភាពនេះ សេវាកម្មត្រូវបានផ្ទោះប្តូរឆ្លងដែន ដោយឡែកដៃគូពាណិជ្ជកម្មទាំងពីរពុំបានផ្លាស់ទីចេញពីប្រទេសសាមីរបស់ខ្លួននោះទេ។

### ➲ **រូបភាពទី២៖ ការទទួលសេវាកម្មក្រៅប្រទេស** (Consumption Abroad)

ក្នុងរូបភាពនេះ អ្នកទទួលសេវាកម្មត្រូវធ្វើដំណើរទៅទទួលយកសេវាកម្ម ពីដៃគូរបស់ខ្លួនដែលជាអ្នកផ្តល់សេវាកម្មនៅក្រៅប្រទេស។

**ឧទាហរណ៍៖**

បុគ្គលិកនៃក្រុមហ៊ុន ឬគ្រឹះស្ថានទទួលសេវាកម្មក្នុងប្រទេសកម្ពុជា ត្រូវធ្វើដំណើរទៅកាន់ប្រទេសចិនដើម្បីទទួលសេវាកម្មដូចជា ការបណ្តុះបណ្តាលលើជំនាញឯកទេសថ្មីៗជាដើម។

### ➲ **រូបភាពទី៣៖ វត្តមានសេវាកម្ម** (Commercial Presence)

ក្នុងរូបភាពនេះ ការផ្គត់ផ្គង់ផលិតផលសេវាកម្មត្រូវធ្វើឡើងតាមរយៈសាខាក្រុមហ៊ុនរបស់ខ្លួនដែលធ្វើប្រតិបត្តិការនៅក្នុងប្រទេសដែលទទួលសេវាកម្ម។

**ឧទាហរណ៍៖**

ក្រុមហ៊ុនផ្តល់សេវាកម្មខាងស្ថាបត្យកម្មរបស់ប្រទេសចិន បានបើកសាខារបស់ខ្លួនក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់នូវសេវាកម្មដល់អតិថិជនដែលស្ថិតក្នុងប្រទេសកម្ពុជា។

### ➲ **រូបភាពទី៤៖ វត្តមាននៃបុគ្គល** (Presence of Natural Persons)

ក្នុងរូបភាពនេះ បុគ្គលដែលជាអ្នកផ្តល់សេវាត្រូវធ្វើដំណើរជាបណ្តោះអាសន្នទៅប្រទេសមួយផ្សេងទៀត ដើម្បីផ្តល់សេវាដល់អតិថិជនរបស់ខ្លួន។

**ឧទាហរណ៍៖**

ក្រុមអ្នកជំនាញផ្នែកសុវត្ថិភាពអ៊ីនធើណេតនិងប្រព័ន្ធអនឡាញនៃប្រទេសចិន បានធ្វើដំណើរមកបណ្តុះបណ្តាលអ្នកជំនាញក្នុងប្រទេសកម្ពុជា ពីជំនាញ ឬបច្ចេកទេសថ្មីៗក្នុងវិស័យសុវត្ថិភាពលើបណ្តាញអ៊ីនធើណេត។

នៅក្នុងប្រទេសកម្ពុជា វិស័យសេវាកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយវិស័យមួយនេះបានចូលរួមក្នុងសេដ្ឋកិច្ចកម្ពុជាប្រមាណ ៣៨,៨៥% នៅក្នុងឆ្នាំ២០១៩ (Knoema.com)។ បើពិនិត្យ

ទៅលើតួលេខនេះ យើងហាក់ដូចជាមានទំនោរវិជ្ជមានទៅលើវិស័យសេវាកម្មកម្ពុជា ជាពិសេសក្នុងបរិបទនៃការផ្លាស់ប្តូរពាណិជ្ជកម្មសេរីជាមួយប្រទេសចិន។




*រូបភាពទី 1៖ វិស័យនានាដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចកម្ពុជា*

**ប្រភព៖** Knoema.com

ជាមួយនឹងតួលេខខាងលើនេះ ទេសចរណ៍បានដើរតួសំខាន់ជាងគេក្នុងវិស័យសេវាកម្មរបស់ជាតិ ក៏ប៉ុន្តែក្នុងក្របខណ្ឌនៃការធ្វើពាណិជ្ជកម្មអន្តរជាតិ យើងសង្កេតឃើញថា ការធ្វើពាណិជ្ជកម្មអន្តរជាតិលើវិស័យមួយនេះពុំទាន់មានសក្តានុពលខ្លាំងនៅឡើយទេ ដោយសារតែកម្ពុជាច្រើនតែដើរតួជាអ្នកទទួលទិញសេវាកម្ម ជាជាងជាអ្នកផ្គត់ផ្គង់សេវាកម្ម។ បើប្រៀបធៀបជាមួយនឹងវិស័យផ្សេងៗទៀត វិស័យសេវាកម្មនៅមានកម្រិតទាបជាងគេ[4] និងមិនទាន់មានភាពសម្បូរបែបនៅឡើយទេ ហើយវិស័យ

[4] នៅត្រង់ចំណុចនេះ យើងចង់ផ្តោតទៅលើប្រភេទនៃសេវាកម្មដែលអាចធ្វើការដោះដូរគ្នាបានក្នុងទម្រង់ជាពាណិជ្ជកម្ម ដែលក្នុងករណីនេះ យើងក៏មិនបានផ្តោតទៅលើប្រភេទសេវាកម្មដូចជាទេសចរ ការបម្រើសេវាកម្មជាដើម។

នេះមានទីផ្សារខ្លាំង ក្នុងស្រុក ច្រើនជាងទីផ្សារបរទេស។ បើយើងពិនិត្យមើលទៅលើភាពរីកចម្រើនក្នុងវិស័យនេះ កម្ពុជានៅដើរឆ្ងាយនៅឡើយពីលទ្ធភាពដែលអាចធ្វើការដោះដូរសេវាកម្មជាមួយប្រទេសចិនបាន ដោយសារតែលទ្ធភាពក្នុងការផ្តល់សេវាកម្មរបស់ខ្លួននៅមានកម្រិត។

ក្នុងបរិបទនៃការធ្វើពាណិជ្ជកម្មអន្តរជាតិលើវិស័យសេវាកម្ម ការស្រាវជ្រាវនេះបានកំណត់នូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ដែលវិស័យនេះកំពុងជួបប្រទះ។

## ក) ខ្វះខាតអ្នកជំនាញ

អ្នកជំនាញ គឺជាធនធានសំខាន់បំផុតនៅក្នុងការធ្វើពាណិជ្ជកម្មលើវិស័យសេវាកម្ម ជាពិសេសក្នុងបរិបទនៃការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យា អ៊ីនធើណេត និងនវានុវត្តន៍ជាដើម។ ការស្រាវជ្រាវ និងការបង្កើតអ្វីដែលថ្មីក្នុងវិស័យមួយនេះ គឺជាសក្តានុពលខ្លាំងបំផុតក្នុងការផ្តោះប្តូរពាណិជ្ជកម្មផ្នែកសេវាកម្មជាមួយដៃគូពាណិជ្ជកម្មរបស់ខ្លួន។ ដូចដែលបានបញ្ជាក់ខាងលើ ចំពោះករណីនេះកម្ពុជាបានដើរតួជាអ្នកទទួលសេវាកម្ម ច្រើនជាងអ្នកផ្គត់ផ្គង់សេវាកម្មទៅកាន់ដៃគូរបស់ខ្លួន។

**ឧទាហរណ៍៖**

ក្នុងបរិបទនៃបញ្ញាសិប្បនិម្មិត (Artificial Intelligence-AI) និងវិទ្យាសាស្ត្រទិន្នន័យ (Data Science) ជាដើម កម្ពុជាពុំទាន់មានអ្នកជំនាញផ្នែកនេះដើម្បីផ្តល់សេវាកម្មនូវឡើយទេ។ ដោយឡែកក្នុងប្រទេសជឿនលឿន គេមានក្រុមអ្នកជំនាញដើម្បីផ្តល់ប្រឹក្សាលើទិន្នន័យ ដែលក្រុមហ៊ុនជាច្រើននៅក្រៅប្រទេសទាក់ទងដើម្បីទទួលសេវាកម្មពីក្រុមហ៊ុនទាំងនេះ។

ក្នុងវិសាលភាពនៃការធ្វើពាណិជ្ជកម្មសម្រាប់វិស័យសេវាកម្ម យើងក៏សង្កេតឃើញថា កម្ពុជានៅខ្វះខាតអ្នកជំនាញ ទៅលើបរិបទជាច្រើនទៀតដូចជា៖

- ១ **អ្នកជំនាញគូសប្លង់អគារធំៗ៖** ជាក់ស្តែង បើយើងពិនិត្យមើលទៅលើអគារសំណង់ធំៗក្នុងរាជធានីភ្នំពេញ អ្នកឌីហ្សាញ អ្នកគូសប្លង់ ឬក៏វិស្វករជំនាញៗក្តី ច្រើនតែជាជនជាតិបរទេស ដែលករណីនេះ បានបង្ហាញថា កម្ពុជាបានទិញកញ្ចប់សេវាកម្មពីបរទេសច្រើន។
- ១ **អ្នកសរសេរកម្មវិធីគ្រប់គ្រងអាជីវកម្មធំៗ៖** ឧទាហរណ៍មួយទៀតទាក់ទងនឹងអ្នកសរសេរកម្មវិធីកុំព្យូទ័រដើម្បីគ្រប់គ្រងអាជីវកម្មធំៗ ដូចជាកម្មវិធីគ្រប់គ្រងធនាគារ ផ្សារទំនើបជាដើម ក៏មាន

ការផ្គត់ផ្គង់សេវាកម្ម ឬទិញកញ្ចប់សេវាកម្មទាំងនេះពីក្រុមហ៊ុនដែលមានប្រភពពីបរទេស ឬអាចនិយាយថា ជួលក្រុមហ៊ុនបរទេសដើម្បីរៀបចំកម្មវិធីទាំងនោះ។

### ខ) កង្វះខាតការវិនិយោគ

មិនខុសពីវិស័យធំៗទាំងពីខាងលើ កម្ពុជាមានការខ្វះខាតខ្លាំងនូវការវិនិយោគលើវិស័យសេវាកម្ម ជាពិសេសខាងផ្នែកបច្ចេកវិទ្យាដែលជាតម្រូវការចាំបាច់របស់ពិភពលោកនាពេលបច្ចុប្បន្ន។ ដោយសារតែខ្វះខាតការវិនិយោគ បានធ្វើឱ្យកម្ពុជាខ្វះលទ្ធភាពក្នុងការបង្កើតអ្វីដែលថ្មី ឬខ្វះលទ្ធភាពក្នុងការបង្កើតផលិតផលសេវាកម្មដែលអាចធ្វើពាណិជ្ជកម្មបាន ដែលនេះជាហេតុធ្វើឱ្យកម្ពុជាមិនត្រឹមតែគ្មានលទ្ធភាពក្នុងការផ្គត់ផ្គង់ប៉ុណ្ណោះទេ ផ្ទុយមកវិញ កម្ពុជាចាំបាច់ត្រូវពឹងផ្អែកទៅលើសេវាកម្មរបស់គេទៅវិញ។ ការវិនិយោគក្នុងវិស័យសេវាកម្មដែលកម្ពុជាទទួលបាន ច្រើនតែជាសេវាកម្មដើម្បីបម្រើអតិថិជនដូចជាសេវាកម្មទេសចរណ៍ ធនាគារ ជាដើម។ បើទោះបីជា កម្ពុជាទទួលបានការវិនិយោគមួយចំនួនផ្តោតលើផលិតផលសេវាកម្មក្តី ក៏លទ្ធភាព និងគុណភាពបានត្រឹមផ្គត់ផ្គង់តម្រូវការក្នុងស្រុក ដោយពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តោះផ្តូរសេវាកម្មទាំងនេះ ក្នុងទម្រង់ជាពាណិជ្ជកម្មអន្តរជាតិនៅឡើយទេ។

## ៣.៣. បញ្ហាប្រឈមក្នុងវិស័យដឹកជញ្ជូន

ជាផ្នែកមួយនៃវិស័យសេវាកម្ម វិស័យដឹកជញ្ជូន ឬការដឹកជញ្ជូន បានដើរតួយ៉ាងសំខាន់ក្នុងចរន្តសេដ្ឋកិច្ចជាតិ ទាំងវិស័យផលិតកម្ម និងមិនចំពោះតែសម្រាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិនោះទេ។ ដោយមើលឃើញពីសារៈសំខាន់នៃវិស័យមួយនេះ ក្រុមការងារគម្រោងសូមលើកចំណុចនេះមកសិក្សាដោយឡែក ដោយមិនសិក្សាបញ្ចូលជាមួយវិស័យសេវាកម្មដែលបានលើកឡើងខាងលើ។ បូកផ្សំជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដែលមានស្ថានភាពពិបាក ដែលជាហេតុធ្វើឱ្យថ្លៃដឹកជញ្ជូនកើនឡើង យើងក៏សង្កេតឃើញថា កង្វះនូវមធ្យោបាយដឹកជញ្ជូនដែលមានតម្លៃទាបដូចជារថភ្លើងជាដើមក៏ជាដើមហេតុធ្វើឱ្យតម្លៃផលិតកម្មកើនឡើងផងដែរ។ បន្ថែមពីលើនេះ ការដឹកជញ្ជូនដោយពុំបានរៀបចំទុកដាក់ត្រឹមត្រូវតាមបច្ចេកទេសរក្សាគុណភាពទំនិញ ធ្វើឱ្យមានការខូចខាតផលិតផល និងបានចូលរួមចំណែកយ៉ាងច្រើនដល់ការកើនឡើងនៃតម្លៃផលិតផល។

បើពិនិត្យទៅលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន កម្ពុជានៅមានបញ្ហាប្រឈមខ្លាំងទាក់ទងនឹងស្ថានភាពផ្លូវធ្វើដំណើរមានការពិបាក ពុំមានកំពង់ផែទឹកជ្រៅគ្រប់គ្រាន់[5] ស្ថានភាពផ្លូវដែកមិនទាន់អាចដំណើរការបានទាំងស្រុង និងមានល្បឿនយឺតជាដើម។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធ កម្ពុជាពុំទាន់មានការវិនិយោគដោយផ្ទាល់លើមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក ដើម្បីទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះនៅឡើយទេ។

ជាផ្នែកមួយនៃវិស័យដឹកជញ្ជូននេះផងដែរ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមធ្យោបាយដឹកជញ្ជូន កម្ពុជាក៏ពុំទាន់មានការវិនិយោគទៅលើសំណង់ហេដ្ឋារចនាសម្ព័ន្ធ (ស្តង់ស្តុកទំនិញ) ដែលមានគុណភាពសម្រាប់រក្សាទុកផលិតផលនៅទីតាំងផ្តោះប្តូរទំនិញជាដើម។ ជាក់ស្តែង នៅក្នុងប្រទេសអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធប្រភេទនេះ ត្រូវបំពាក់នូវប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងបែបទំនើប ជាពិសេសក្នុងពេលបច្ចុប្បន្ននេះ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតក៏ត្រូវបានគេប្រើប្រាស់ច្រើនផងដែរក្នុងការគ្រប់គ្រងប្រព័ន្ធដឹកជញ្ជូនអន្តរជាតិ។

## ៣.៤. បញ្ហាប្រឈមក្នុងបរិស្ថានវិនិយោគ

យើងសង្កេតឃើញថា ក្នុងបរិបទបច្ចុប្បន្ន បរិយាកាសវិនិយោគនៅកម្ពុជានៅមានកម្រិតទាបបើធៀបទៅនឹងប្រទេសជិតខាង ដែលធ្វើឱ្យកម្ពុជាពុំទាន់អាចមានលទ្ធភាពក្នុងការទាក់ទាញការវិនិយោគឱ្យបានទូលំទូលាយ។ តាមរយៈការស្រាវជ្រាវ យើងអាចកំណត់បាននូវកត្តាសំខាន់ៗមួយចំនួនដែលបានចូលរួមក្នុងការបង្អាក់នូវសកម្មភាពនៃការវិនិយោគទាំងនេះ ដែលកត្តាទាំងនេះមានដូចជា៖

### ១ ក្របខណ្ឌគតិយុត្តក្នុងការវិនិយោគ

បើពិនិត្យទៅលើគោលនយោបាយវិនិយោគរបស់កម្ពុជា យើងសង្កេតឃើញថាមានភាពល្អប្រសើរ និងផ្តល់នូវលទ្ធភាពប្រកួតប្រជែងគ្រប់គ្រាន់បើធៀបជាមួយនឹងប្រទេសជិតខាង ក៏ប៉ុន្តែការអនុវត្តជាក់ស្តែង នៅមានបញ្ហាប្រឈមច្រើន ដែលបញ្ហាទាំងនោះបែរជាបង្អាក់នូវឱកាសវិនិយោគពី

[5] ត្រង់ចំណុចនេះ យើងផ្តោតលើស្ថានភាពបច្ចុប្បន្នដោយយើងនៅខ្វះខាតនៅឡើយ បើទោះបីជាបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើហេដ្ឋារចនាសម្ព័ន្ធមួយនេះ តាមរយៈការជំរុញការសាងសង់កំពង់ផែទឹកជ្រៅនៅសមុទ្ររាម និងឆ្នេរមួយចំនួនទៀតក្តី។

បរទេសជាពិសេសប្រទេសលោកខាងលិច។ អំពើពុករលួយ និងភាពមិនប្រក្រតីនៅក្នុងដំណើរការនៃការចុះបញ្ជីពាណិជ្ជកម្ម ការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មក្តី បានដើរតួយ៉ាងសំខាន់ក្នុងការបង្អាក់នូវការវិនិយោគពីបរទេស។

### ១ តម្លៃប្រើប្រាស់ទាក់ទងនឹងទឹកស្អាត និងអគ្គិសនី (Utility Costs)

កត្តាមួយទៀតដែលប៉ះពាល់ខ្លាំងដល់បរិស្ថានវិនិយោគនៅក្នុងប្រទេសកម្ពុជាផងដែរនោះគឺ តម្លៃទឹក និងអគ្គិសនីដែលជាផ្នែកដ៏សំខាន់នៃការប្រើប្រាស់ប្រចាំថ្ងៃ។ លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា តម្លៃប្រើប្រាស់ប្រចាំថ្ងៃចំពោះទឹក និងអគ្គិសនីជាដើម (ជាពិសេសអគ្គិសនី) នៅកម្ពុជា មានកម្រិតខ្ពស់ជាងតម្លៃនៅក្នុងប្រទេសជិតខាងរបស់កម្ពុជា ដែលកត្តាមួយនេះក៏បានរួមចំណែកក្នុងការបង្អាក់នូវការវិនិយោគពីបរទេសផងដែរ។ ជាក់ស្តែង តម្លៃទឹកស្អាតប្រើប្រាស់ក្នុងប្រទេសថៃ (www.boi.go.th[6]) គិតជាប្រាក់ដុល្លារក្នុងមួយម៉ែត្រគូប (១ម$^៣$) ស្ថិតនៅចន្លោះ $០,៣១-$០,៥២ ដោយឡែកក្នុងប្រទេសវៀតណាម (Hanoi Water Supply Co. Ltd[7]) មានតម្លៃក្នុងចន្លោះ $០,២៥-$០,៥៣។ ជាមួយនឹងតម្លៃទឹកស្អាតនេះ កម្ពុជាហាក់មានប្រៀបជាងបន្តិចបន្តួច ក៏ប៉ុន្តែចំពោះអគ្គិសនីវិញ កម្ពុជាហាក់ចាញ់ប្រៀបឆ្ងាយដោយសារតែបច្ចុប្បន្ន កម្ពុជាបាននាំចូលអគ្គិសនីច្រើនពីប្រទេសជិតខាងរបស់យើង ដែលកត្តានេះបានធ្វើឱ្យអគ្គិសនីមានតម្លៃខ្ពស់។

ក្រៅពីតម្លៃ យើងក៏សង្កេតឃើញថា ការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនីនៅកម្ពុជាក៏ពុំទាន់មានភាពទូលំទូលាយ និងស្ថិរភាពនៅឡើយដែរ។ ជាក់ស្តែង បណ្តាញទឹកស្អាតសាធារណៈកម្ពុជា គ្របដណ្តប់បានតិចតួចនៅឡើយ ដោយការផ្គត់ផ្គង់មានតែនៅរាជធានី ទីរួមខេត្ត និងតាមស្រុក និងតំបន់សំខាន់ៗមួយចំនួន។ ចំពោះតំបន់ដែលទទួលបានការផ្គត់ផ្គង់ទៀតសោធ ក៏តែងតែជួបប្រទះនូវបញ្ហាជារឿយៗទាក់ទងនឹងបរិមាណទឹកខ្សោយ ឬពេលខ្លះដាច់ទឹកផងក៏មាន។ ក្រៅពីបណ្តាញទឹកសាធារណៈ កម្ពុជា

[6] ទិន្នន័យទាក់ទងនឹងតម្លៃការប្រើប្រាស់ប្រចាំថ្ងៃ (Utility Costs) ក្នុងប្រទេសថៃដែលតម្លៃនេះអាចនឹងប្រែប្រួលបន្តិចបន្តួចទៅតាមទីក្រុង ឬតំបន់ផ្សេងៗ។ ព័ត៌មានយកចេញពីគេហទំព័រ៖ https://www.boi.go.th/index.php?page=utility_costs

[7] ទិន្នន័យនេះយកចេញពីតម្លៃផ្គត់ផ្គង់ទឹកដោយក្រុមហ៊ុនផ្គត់ផ្គង់ទឹកនាទីក្រុងហាណូយ។ តម្លៃនេះអាចប្រែប្រួលបន្តិចបន្តួចតាមទីក្រុង ឬតាមតំបន់ផ្សេងៗ។ ព័ត៌មាននេះយកចេញពីគេហទំព័រ៖ https://en.evn.com.vn/c3/gioi-thieu-l/Electricity-Price-9-28.aspx

ក៏មានក្រុមហ៊ុនឯកជនមួយចំនួនផងដែរ ដែលទទួលខុសត្រូវផ្គត់ផ្គង់ទឹកស្អាតតាមស្រុក ឬឃុំមួយចំនួន ក៏ប៉ុន្តែតម្លៃវិញមានកម្រិតខ្ពស់ខ្លាំង ដែលនេះក៏ជាកត្តាប្រឈមខ្លាំងមួយផងដែរចំពោះកម្ពុជា។ ដោយឡែក ទាក់ទងជាមួយនឹងអគ្គិសនី ក្រៅពីតម្លៃថ្លៃបន្តិច យើងក៏សង្កេតឃើញថា ការផ្គត់ផ្គង់ក៏មានជួបបញ្ហាប្រឈមខ្លះដែរទាក់ទងនឹងស្ថិរភាពនៃការផ្គត់ផ្គង់ ជាពិសេសក្នុងរដូវប្រាំង។

### ១ ហេដ្ឋារចនាសម្ព័ន្ធវិនិយោគ

បញ្ហាប្រឈមទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធវិនិយោគនៅកម្ពុជា ក៏ស្ថិតនៅក្នុងចំណោមបញ្ហាក្តៅមួយផងដែរសម្រាប់បរិបទនៃការវិនិយោគ។ ដូចបានរៀបរាប់ខ្លះៗក្នុង **ចំណុច៣.១** និង **ចំណុច៣.៣** ខាងលើ ស្ថានភាពនៃហេដ្ឋារចនាសម្ព័ន្ធវិនិយោគដូចជាប្រព័ន្ធទឹកស្អាត អគ្គិសនី ប្រព័ន្ធធារាសាស្ត្រ ផ្លូវដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក) និងមធ្យោបាយដឹកជញ្ជូនជាដើម នៅតែជាបញ្ហាចោទដ៏ចម្បងរបស់កម្ពុជា។ បណ្តាញផ្លូវដឹកជញ្ជូន ប្រៀបបាននឹងសរសៃឈាមក្នុងខ្លួនមនុស្សដែរ ដែលមានតួនាទីជាបណ្តាញសម្រាប់ដឹកជញ្ជូនផលិតផលនានា ទាំងវត្ថុធាតុដើមផលិតកម្ម ក៏ដូចជាផលិតផលសម្រេចដើម្បីនាំទៅកាន់ទីផ្សារនានា។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានធ្វើការអភិវឌ្ឍច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ក៏ប៉ុន្តែបញ្ហានៅតែកើតមានទាក់ទងនឹងគុណភាពការសាងសង់ជាដើម។ ទាក់ទងជាមួយនឹងការសាងសង់ផ្លូវថ្នល់ គេពិនិត្យឃើញថា គុណភាពផ្លូវមានកម្រិតទាប ដែលធ្វើឱ្យការប្រើប្រាស់មិនបានយូរ ឬពេលខ្លះក៏មានករណីដែលសង់មុខ ខូចក្រោយ ជួសជុលខាងក្រោយ ខូចខាងមុខ ជាបន្តបន្ទាប់។

### ១ ធនធានមនុស្ស

ដូចដែលបានរៀបរាប់ខ្លះៗទាក់ទងនឹងធនធានមនុស្សនេះ លទ្ធផលស្រាវជ្រាវបានបង្ហាញថា បញ្ហាទាក់ទីងនឹងកង្វះខាតធនធានមនុស្សដែលមានជំនាញបច្ចេកទេសត្រឹមត្រូវ គឺជាបញ្ហាប្រឈមសម្រាប់កម្ពុជា មិនត្រឹមតែក្នុងក្របខណ្ឌតម្រូវការការងារប៉ុណ្ណោះទេ ប៉ុន្តែកត្តាមួយនេះក៏ត្រូវបានគេមើលឃើញថា ជាបញ្ហាប្រឈមក្នុងការបង្អាក់នូវការវិនិយោគបន្ថែមទៀតមកកម្ពុជាផងដែរ។ ផ្អែកទៅលើទីតាំងភូមិសាស្ត្រ កម្ពុជាមានសក្តានុពលខ្ពស់សម្រាប់គ្រប់វិស័យ ក៏ប៉ុន្តែដោយសារកង្វះខាតនូវធនធានមនុស្សដែលអាចបម្រើការបានលើគ្រប់វិស័យ និងជំនាញការងារ បានក្លាយទៅជាឧបសគ្គមួយសម្រាប់ការវិនិយោគផងដែរ។ ជាឧទាហរណ៍ ដោយសារតែរចនាសម្ព័ន្ធសេដ្ឋកិច្ចនៃប្រទេសជឿន

លឿនជាច្រើន មានការអភិវឌ្ឍខ្លាំង ដូចនេះវិនិយោគិននៃប្រទេសទាំងនោះមានទំនោរក្នុងការវិនិយោគលើប្រភេទអាជីវកម្ម ឬវិស័យណាដែលប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ ក៏ប៉ុន្តែកម្ពុជាពុំអាចផលិតធនធានមនុស្សក្នុងស្រុកដើម្បីអាចបំពេញតម្រូវការនេះបាន។ ហេតុនេះ វិនិយោគិនទាំងនោះ ក៏បង្វែរគោលដៅទៅកាន់ប្រទេសផ្សេងទៀត រួមទាំងប្រទេសជិតខាងកម្ពុជាផងដែរ ដែលគេមានសក្តានុពលជាងលើផ្នែកធនធានមនុស្សនេះ។

ជាក់ស្តែង កង្វះខាតធនធានមនុស្ស ឬធនធានមនុស្សដែលមានជំនាញមិនត្រូវ ឬមិនសមស្របនឹងតម្រូវការការងារជាក់ស្តែង ត្រូវបានអ្នកជំនាញខាងមុខរបរ និងការងារ អ្នកស្រាវជ្រាវជាដើម លើកយកមកជជែក និងស្វែងរកដំណោះស្រាយ ក៏ប៉ុន្តែរហូតមកដល់ពេលនេះ កម្ពុជានៅតែជួបនូវបញ្ហាទាំងនេះនៅឡើយ។ ជាមួយនឹងការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យា ក៏ដូចជាការពេញនិយមនូវសេដ្ឋកិច្ចបែបឌីជីថលផងនោះ ធនធានមនុស្សដែលមានពហុជំនាញ បូកផ្សំជាមួយនឹងចំណេះដឹងផ្នែកបច្ចេកវិទ្យាផងនោះ គឺជាកត្តាកំណត់មួយសម្រាប់តម្រូវការការងារនាពេលបច្ចុប្បន្ន និងអនាគត។

តាមរយៈទន្និករណ៍ និងលទ្ធផលដែលបានបង្ហាញជូនខាងលើ គេសង្កេតឃើញថា ក្នុងបរិបទនៃពាណិជ្ជកម្មសេរីកម្ពុជា-ចិន កម្ពុជាចាំបាច់ត្រូវដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយ ព្រមទាំងត្រូវពង្រឹង និងអភិវឌ្ឍខ្លួនបន្ថែមទៀត ដើម្បីអាចឈោងចាប់នូវឱកាសដែលមានតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មនេះ។

# ជំពូក ៤
# សក្ដានុពលនិងឱកាសសម្រាប់កម្ពុជា

ដូចដែលបានធ្វើការបង្ហាញក្នុងជំពូក២ខាងលើ យើងសង្កេតឃើញថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននឹងដើរតួបន្ថែមទៀតទៅលើការពង្រីកនូវវិសាលភាពនៃការនាំចេញរបស់កម្ពុជា ជាពិសេសទៅលើផលិតផលនានាដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ។ ជាមួយនឹងអត្ថប្រយោជន៍នានាដែលកម្ពុជាអាចនឹងទទួលបានពីកិច្ចព្រមព្រៀងនេះ វាបានលេចឡើងនូវបញ្ហាចោទមួយសម្រាប់កម្ពុជា ថាតើកម្ពុជាបានត្រៀមខ្លួនរួចប៉ុណ្ណា ឬថាកម្ពុជាមានសក្ដានុពលបែបណាដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាចេញពីកិច្ចព្រមព្រៀងនេះ។ នៅក្នុងជំពូកនេះ ក្រុមការងារគម្រោងស្រាវជ្រាវពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន បានធ្វើការសិក្សា និងវិភាគទៅលើសក្ដានុពលជាក់ស្ដែងដែលកម្ពុជាមាន ឬអាចនឹងពង្រឹងបន្ថែមទៀតក្នុងគោលដៅទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនបំផុតពីកិច្ចព្រៀងទ្វេភាគីជាមួយដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរបស់ខ្លួន។ ផ្អែកទៅលើវិសាលភាពនៃកិច្ចព្រមព្រៀងនេះ យើងនឹងបង្ហាញនូវសក្ដានុពលនៃវិស័យចម្បងៗដូចខាងក្រោម៖

- សក្ដានុពលលើវិស័យវិនិយោគ
- សក្ដានុពលក្នុងវិស័យផលិតកម្ម និង
- សក្ដានុពលក្នុងវិស័យសេវាកម្ម

បើទោះបីជាវិស័យឧស្សាហកម្ម ពុំស្ថិតក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិនដោយផ្ទាល់ក្ដី ប៉ុន្តែក្នុងនាមជាសមាជិកប្រទេសសហគមអាស៊ាន កម្ពុជានៅមានកិច្ចព្រមព្រៀងសេរីអាស៊ាន-ចិនមួយទៀតដែលវិស័យឧស្សាហកម្មបានស្ថិតក្នុងវិសាលភាពចម្បងមួយផងដែរក្នុងកិច្ចព្រមព្រៀងនេះ។

## ៤.១. សក្តានុពលរបស់កម្ពុជា

ក្រៅពីបញ្ហាប្រឈមមួយចំនួនដែលបានរៀបរាប់ខាងលើ យើងសង្កេតឃើញថា កម្ពុជាក៏មានសក្តានុពលមួយចំនួនក្នុងវិស័យនានា ដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះផងដែរ។ ខាងក្រោមនេះ ជាសក្តានុពលមួយចំនួន ដែលយើងនឹងលើកយកមកសិក្សាសម្រាប់បរិបទនៃកិច្ចព្រមព្រៀងនេះ។

### ៤.១.១. សក្តានុពលក្នុងការវិនិយោគ

រូបភាពវិជ្ជមាននៃការវិនិយោគ ជាពិសេស ការវិនិយោគដោយផ្ទាល់ពីក្រៅប្រទេស (FDI) គឺជាសក្តានុពលដ៏ធំសម្រាប់កម្ពុជា។ តាមទិន្នន័យពីគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា យើងពិនិត្យឃើញថា ការវិនិយោគក្នុងប្រទេសកម្ពុជាក្នុងរយៈពេល៥ឆ្នាំ (២០១៥-២០១៩) មានរូបភាពវិជ្ជមានគួរឱ្យកត់សម្គាល់ ដោយទំហំវិនិយោគមានការកើនឡើងយ៉ាងខ្លាំង (២៤%) ក្នុងចន្លោះឆ្នាំ២០១២ (២,៩ប៊ីលានដុល្លារ) ដល់ឆ្នាំ២០១៦ (៣,៦ប៊ីលានដុល្លារ)។ តួលេខនេះមានការកើនឡើងប្រមាណ ៧៥%ក្នុងឆ្នាំ២០១៧ ប៉ុន្តែមានការកើនឡើងបន្តិចបន្តួច (រង្វង់២%) ក្នុងឆ្នាំ២០១៨។ ក្នុងឆ្នាំ២០១៩ ទំហំនៃការវិនិយោគមានការកើនឡើងប្រមាណ ៤៥% បើធៀបនឹងឆ្នាំ២០១៨។ ជាមួយគ្នានេះ ក្នុងចន្លោះរយៈពេល៥ឆ្នាំ (២០១៥-២០១៩) ទំហំនៃការវិនិយោគដោយសហគ្រិនក្នុងស្រុកមានប្រមាណ៣៥% នៃការវិនិយោគទាំងអស់ (Cambodiainvestment.com.kh, nd)។ ជាមួយនឹងកំណើននៃការវិនិយោគនេះ ប្រទេសចិនគឺជាប្រទេសដែលបានវិនិយោគក្នុងវិស័យកសិកម្មរបស់កម្ពុជាធំជាងគេ (Husain Haider, 2021)។

បើទោះបីជាកំពុងប្រឈមមុខនឹងវិបត្តិកូវីដ-១៩ក្តី កម្ពុជាក៏នៅតែទទួលបាននូវកំណើននៃការវិនិយោគពីក្រៅប្រទេសក្នុងទំហំធំគួរឱ្យកត់សម្គាល់។ ជាក់ស្តែង នៅក្នុងខែមិថុនាឆ្នាំ២០២១ នេះមានក្រុមហ៊ុនចំនួន១២ត្រូវបានអនុញ្ញាតឱ្យបណ្តាក់ទុននៅកម្ពុជា ជាមួយនឹងទឹកប្រាក់វិនិយោគសរុប ១៤៣,៣លានដុល្លារអាមេរិក ដោយបានជួយបង្កើតការងារជូនប្រជាពលរដ្ឋកម្ពុជាប្រមាណ៧,៥៥៥។

តារាងទី 2៖ ទំហំការវិនិយោគនៅកម្ពុជា (គិតជាដុល្លារអាមេរិក)

| ឆ្នាំ | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | | ២០១៩ | |
|---|---|---|---|---|---|---|---|---|---|---|
| សរុប | ៤,៦ប៊ីលាន | | ៣,៦ប៊ីលាន | | ៦,៣ប៊ីលាន | | ៦,៤ប៊ីលាន | | ៩,៤ប៊ីលាន | |
| លំដាប់ | ប្រទេស | % | ប្រទេស | % | ប្រទេស | % | ប្រទេស | % | ប្រទេស | % |
| ១ | កម្ពុជា | ៦៩,២៨ | ចិន | ២៩,៩២ | កម្ពុជា | ៥០,៦៨ | ចិន | ៥១,០៦ | កម្ពុជា | ៤៩,៤៤ |
| ២ | ចិន | ១៨,៦២ | កម្ពុជា | ២៧,៥៥ | ចិន | ២៥,៩៧ | កម្ពុជា | ៣១,១៥ | ចិន | ៣៩,៥៥ |
| ៣ | អង់គ្លេស | ៣ | ជប៉ុន | ២២,៧៨ | វៀតណាម | ៩,២០ | ជប៉ុន | ១៣,៦៩ | BVI | ៤,៩៣ |
| ៤ | សឹង្ហបុរី | ២,១៨ | ថៃ | ៤,៦១ | ម៉ាឡេស៊ី | ៤,៣៧ | ថៃ | ០,៨០ | ជប៉ុន | ៣,១៨ |
| ៥ | វៀតណាម | ១,៩២ | កូរ៉េ | ៤,៥៩ | សឹង្ហបុរី | ៤,១២ | BVI | ០,៧៦ | ថៃ | ០,៧៨ |
| ៦ | ម៉ាឡេស៊ី | ១,៦១ | អាមេរិក | ៣,៣៨ | កូរ៉េ | ៣,២០ | ម៉ាឡេស៊ី | ០,៦៨ | វៀតណាម | ០,៧០ |
| ៧ | ជប៉ុន | ១,២៨ | សឹង្ហបុរី | ៣,០៣ | ជប៉ុន | ១,០០ | Samao | ០,៦៧ | សឹង្ហបុរី | ០,៣២ |
| ៨ | ថៃ | ១,១៨ | វៀតណាម | ២,៤៥ | អង់គ្លេស | ០,៨៨ | សឹង្ហបុរី | ០,២៨ | អង់គ្លេស | ០,២៨ |
| ៩ | កូរ៉េ | ០,២១ | អង់គ្លេស | ០,៦០ | ថៃ | ០,២៥ | អង់គ្លេស | ០,២៣ | កូរ៉េ | ០,២២ |
| ១០ | កាណាដា | ០,១៩ | ឥណ្ឌា | ០,៥៥ | Virgin Islands | ០,១២ | កូរ៉េ | ០,២៣ | ហូឡង់ | ០,១៥ |
| ១១ | ផ្សេងទៀត | ០,៥៣ | ផ្សេងទៀត | ០,៥៤ | ផ្សេងទៀត | ០,២១ | ផ្សេងទៀត | ០,៤៥ | ផ្សេងទៀត | ០,៤៥ |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា (CDC)*

## ៤.១.២. សក្តានុពលក្នុងវិស័យផលិតកម្ម

នៅក្នុងចំណុចនេះ យើងនឹងលើកយកសក្តានុពលក្នុងវិស័យផលិតកម្មធំៗចំនួនពីរគឺ ផលិតកម្មក្នុងវិស័យកសិកម្ម និងផលិតកម្មឧស្សាហកម្ម[៨]។ ខាងក្រោមនេះ ជាលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងសក្តានុពលរបស់កម្ពុជាដោយផ្តោតជាសំខាន់លើវិស័យទាំងពីរនេះ។

### ក) សក្តានុពលក្នុងវិស័យកសិកម្ម

បើទោះបីជា ក្នុងវិស័យកសិកម្ម កម្ពុជាពិតជាមាននូវបញ្ហាប្រឈមច្រើនដូចដែលបានបង្ហាញនៅក្នុង**ចំណុច៣.១.១**ក្តី ប៉ុន្តែបើផ្អែកលើកត្តាគោលនយោបាយ ភូមិសាស្ត្រ ធម្មជាតិ វប្បធម៌ និងប្រជាជនកម្ពុជានៅមានសក្តានុពលខ្លាំងសម្រាប់វិស័យកសិកម្ម។ ខាងក្រោមនេះ គឺជាសក្តានុពលសំខាន់ៗដែលកម្ពុជាមាននៅក្នុងវិស័យកសិកម្ម។

#### ១ សក្តានុពលធម្មជាតិ

បើទោះបីជាកម្ពុជាមានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងវិស័យកសិកម្ម ដូចដែលបានលើកឡើងពីខាងលើក្តី ក៏ស្ថានភាពជាក់ស្តែងនៃអាកាសធាតុ សណ្ឋានដីនៃប្រទេសកម្ពុជាមានសក្តានុពលខ្ពស់សម្រាប់វិស័យកសិកម្ម។ កម្ពុជាមានសណ្ឋានដីដែលអំណោយផលដល់ដំណាំកសិកម្មស្ទើរគ្រប់ប្រភេទ ដោយសារដីរាងបាតខ្ទះ មានដីជាប្រភេទខ្ពង់រាប វាលទំនាប និងដីតាមបឹងទន្លេសាបជាដើម។ បន្ថែមពីលើនេះ សណ្ឋានដីរបស់កម្ពុជាសម្បូរទៅដោយប្រព័ន្ធទឹកធម្មជាតិដូចជាទន្លេ ស្ទឹង បឹង បួរជាដើម។ អាកាសធាតុត្រូពិក ក្តៅហើយសើម ក៏ជាកត្តាមួយទៀតដែលធ្វើឱ្យកម្ពុជាមានអំណោយផលខ្ពស់លើវិស័យកសិកម្មផងដែរ។ ខេត្តមួយចំនួនរបស់កម្ពុជា ជាពិសេសខេត្តដែលនៅជាប់នឹងដងទន្លេមេគង្គ ទន្លេសាប បឹងទន្លេសាប និងស្ទឹងធំៗជាច្រើនដូចជា ខេត្តកណ្តាល កំពង់ចាម និងបាត់ដំបងជាដើម មានការដាំដុះដំណាំកសិកម្ម ដូចជាស្រូវ ពោត កៅស៊ូ ដំឡូងមី បន្លែ និងផ្លែឈើជាដើម ច្រើនជាងខេត្តផ្សេងទៀត។

[៨] ជាក់ស្តែង សិប្បកម្មជាផ្នែកមួយនៃឧស្សាហកម្ម ប៉ុន្តែក្នុងចំណុចនេះ យើងលើកយកឧស្សាហកម្មជារួមដែលក្តោបយកទាំងវិស័យសិប្បកម្មផងដែរ។ ទោះជាយ៉ាងណា ការបង្ហាញលទ្ធផលពុំបានធ្វើការបែងចែករវាងវិស័យពីរនេះទេ ដោយសារតែសិប្បកម្មរបស់កម្ពុជាមិនទាន់អាចដើរតួខ្លាំងសម្រាប់ធ្វើការនាំចេញទៅក្រៅប្រទេស។

### ១ សក្តានុពលមនុស្ស

យើងដឹងហើយថា កម្ពុជាជាប្រទេសកសិកម្មដែលមានប្រជាពលរដ្ឋជាង៨០% រស់នៅដោយពឹងផ្អែកលើវិស័យមួយនេះ។ ការប្រកបមុខរបរកសិកម្ម អាចនិយាយថាបានក្លាយជាវប្បធម៌ ដែលជិតជាប់ក្នុងសង្គមកម្ពុជាតាំងពីបុរាណកាលមក ដែលចំណុចនេះ ធ្វើឱ្យប្រជាកសិករកម្ពុជាមានធន្ទះខ្ពស់ក្នុងការដាំដុះដំណាំកសិកម្ម។ បើទោះបីជាការដាំដុះដំណាំកសិកម្មនៅកម្ពុជា តែងតែជួបប្រទះនូវបញ្ហានានា ទាំងក្នុងផលិតកម្មផ្ទាល់ ក៏ដូចជាទីផ្សារក្តី គេសង្កេតឃើញថា ប្រជាពលរដ្ឋកម្ពុជានៅតែបន្តធ្វើការដាំដុះដំណាំកសិកម្ម។ គួរបញ្ជាក់ថា សក្តានុពលមនុស្សនៅក្នុងចំណុចនេះ ពុំបានផ្តោតទៅលើធនធានមនុស្សដែលប្រកបដោយចំណេះ ឬជំនាញខាងកសិកម្មនោះទេ ប៉ុន្តែយើងចង់សំដៅដល់កម្លាំងពលកម្ម ឬកម្លាំងមនុស្សដែលអាចចូលរួមក្នុងការងារកសិកម្មបាន។

ដោយសារតែវិស័យកសិកម្មនៅកម្ពុជាពុំសូវរីកចម្រើនដូចប្រទេសជិតខាង គេសង្កេតឃើញថាប្រជាពលរដ្ឋប្រកបមុខរបរកសិកម្មយ៉ាងច្រើន បានធ្វើចំណាកស្រុកទៅកាន់ប្រទេសជិតខាង ក៏ដូចជាប្រទេសផ្សេងៗទៀតដូចជា កូរ៉េខាងត្បូង ម៉ាឡេស៊ី ចិនជាដើម។ បើកម្ពុជាមានការអភិវឌ្ឍវិស័យកសិកម្មខ្លាំងជាងនេះ និងអាចធានានូវការងារជូនប្រជាពលរដ្ឋកម្ពុជាប្រកបដោយស្ថិរភាពនោះ ប្រជាពលករចំណាកស្រុកទាំងនោះមួយចំនួនធំអាចនឹងពិចារណាត្រឡប់មកស្វែងរកការងារក្នុងស្រុក ដើម្បីជំរុញវិស័យកសិកម្មរបស់ជាតិឱ្យកាន់តែរីកចម្រើន។

### ខ) សក្តានុពលក្នុងវិស័យឧស្សាហកម្ម

យើងដឹងថា ឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជាពុំទាន់មានភាពសម្បូរបែបនៅឡើយទេ ដោយឧស្សាហកម្មភាគច្រើនផ្តោតលើវាយនភណ្ឌកាត់ដេរ ដូចនេះកម្ពុជានៅមានឱកាសច្រើនក្នុងការពង្រីកការវិនិយោគទៅលើឧស្សាហកម្មប្រភេទផ្សេងដើម្បីបង្កើតជាឱកាសសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះ។ ជាក់ស្តែង ឧស្សាហកម្មមានស្រាប់របស់កម្ពុជា បានដើរតួយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈការទទួលផលិតក្នុងទម្រង់កុងត្រា ឬការស្វែងរកទីផ្សារនៅក្រៅប្រទេសជាដើម។ បើទោះបីជាបច្ចុប្បន្ន កម្ពុជាពុំទាន់មានការវិនិយោគច្រើនក្នុងឧស្សាហកម្ម ឬសិប្បកម្មកែច្នៃផលិតផលកសិកម្មក្តី ក៏ឧស្សាហកម្មប្រភេទមួយនេះ នឹងដើរតួយ៉ាងសំខាន់ក្នុងការក្តាប់យកឱកាសចេញពីកិច្ចព្រមព្រៀងនេះ។ ប្រសិនបើកម្ពុជាទទួលបានការវិនិយោគ និងអភិវឌ្ឍ

ច្រើនលើវិស័យកសិ-ឧស្សាហកម្មនោះ វានឹងក្លាយទៅជាសក្តានុពលដ៏ធំមួយសម្រាប់កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន។

## ៤.២. ឱកាសសម្រាប់កម្ពុជា

យើងសង្កេតឃើញថា ក្រៅពីសក្តានុពលដែលកម្ពុជាមានហើយនោះ យើងក៏សង្កេតឃើញថាមានកត្តាមួយចំនួនដែលស្តែងឱ្យឃើញពីឱកាស ដែលកម្ពុជាអាចទាញបានកាន់តែទូលំទូលាយបន្ថែមទៀតសម្រាប់ពាណិជ្ជកម្មសេរីជាមួយប្រទេសចិន។ តាមរយៈការសិក្សានេះ យើងបានកំណត់នូវកត្តាសំខាន់ៗចំនួនបី ដែលអាចបង្កើតបានជាឱកាសសម្រាប់កម្ពុជាក្នុងបរិបទនៃកិច្ចព្រមព្រៀងកម្ពុជា-ចិននេះ។ កត្តាទីមួយគឺ កិច្ចព្រមព្រៀងមានស្រាប់ កត្តាទីពីរគឺចំណងទំនាក់ទំនងរវាងកម្ពុជានិងចិន និងកត្តាទីបីគឺតម្រូវការជាក់ស្តែងរបស់ប្រទេសចិន។

### ៤.២.១. កិច្ចព្រមព្រៀងមានស្រាប់

មកដល់ពេលបច្ចុប្បន្ន កម្ពុជាមានកិច្ចព្រមព្រៀងមួយចំនួនជាមួយនឹងបណ្តាប្រទេសក្នុងសហភាពអឺរ៉ុប សហរដ្ឋអាមេរិក កាណាដា និងប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីផងដែរ។ ក្នុងវិសាលភាពទូលាយ កិច្ចព្រមព្រៀងទាំងនេះ បានផ្តល់ឱ្យកម្ពុជានូវឱកាសសម្រាប់ធ្វើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនតាមរយៈការទាក់ទាញការវិនិយោគ ការនាំចេញដោយទទួលបានលក្ខខណ្ឌពិសេសជាដើម។ ដោយឡែកក្នុងវិសាលភាពនៃការធ្វើពាណិជ្ជកម្មជាមួយប្រទេសចិនវិញ យើងសង្កេតឃើញថា កិច្ចព្រមព្រៀងមានស្រាប់ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្ពុជា-ចិននេះតែម្តង នឹងបង្កើននូវឱកាសដល់កម្ពុជា មិនត្រឹមតែក្នុងបរិបទនៃការផ្លោះប្តូរទំនិញរវាងប្រទេសទាំងពីរប៉ុណ្ណោះទេ ក៏ប៉ុន្តែកិច្ចព្រមព្រៀងទាំងនេះក៏នឹងបង្កើនឱកាសក្នុងការទាក់ទាញវិនិយោគិនពីប្រទេសចិនបានបន្ថែមទៀតផងដែរ។

### ៤.២.២. កត្តាទំនាក់ទំនងជាមួយប្រទេសចិន

ក្រៅពីកិច្ចព្រមព្រៀងដែលមានស្រាប់ ចំណងទំនាក់ទំនងដែលរដ្ឋាភិបាលរបស់ប្រទេសទាំងពីរទទួលស្គាល់ថាជាទំនាក់ទំនងដៃគូសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយនោះ ក៏អាចនឹងជាឱកាសមួយ

ទៀតផងដែរសម្រាប់កម្ពុជា។ តាមរយៈទំនាក់ទំនងនេះ កម្ពុជាអាចធ្វើការចរចារ ដើម្បីពង្រីកវិសាលភាពទំនិញ ឬស្នើសុំនូវលក្ខខណ្ឌអនុគ្រោះបន្ថែមទៀតសម្រាប់ទំនិញរបស់ខ្លួន ដើម្បីឱ្យកម្ពុជាអាចធ្វើការនាំចេញបានកាន់តែច្រើន និងងាយស្រួលជាងមុនផងដែរ។

### ៤.២.៣. គម្រូចការរបស់ប្រទេសចិន

ដោយសារតែការរីកចម្រើនជាលំដាប់ និងបានឈរជើងជាមហាអំណាចសេដ្ឋកិច្ចលំដាប់ទី២ បន្ទាប់ពីសហរដ្ឋអាមេរិក គេសង្កេតឃើញថា ប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសចិនមានការប្រែប្រួលច្រើន បើធៀបនឹងស្ថានភាពកាលពីជាងពីរទសវត្សរ៍មុន។ សេដ្ឋកិច្ចដែលធ្លាប់តែផ្ដោតលើវិស័យកសិកម្ម ការរុករករ៉ែ និងធនធានធម្មជាតិផ្សេងទៀត និងឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យាមិនសូវទំនើប បានប្រែក្លាយមកជាសេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងលើការប្រើប្រាស់បច្ចេកវិទ្យាបែបទំនើប និងមានទម្រង់ជាឧស្សាហកម្មធន់ធ្ងន់។ លោកបណ្ឌិត ឆេង គឹមឡុង អ្នកជំនាញសេដ្ឋកិច្ចនៃវិទ្យាស្ថានចក្ខុវិស័យអាស៊ី (Asian Vision Institute-AVI) បានធ្វើការគូសបញ្ជាក់ថា៖

> *"ការកើនឡើងនៃប្រជាជនវណ្ណៈកណ្ដាល (Middle Class) នៅក្នុងប្រទេសចិន បានធ្វើឱ្យប្រជាជនក្នុងប្រទេសនេះឈានជើងចេញពីការប្រកបមុខរបរដោយពឹងផ្អែកលើវិស័យកសិកម្មបន្តិចម្ដងៗ ជាហេតុធ្វើឱ្យវិស័យកសិកម្មរបស់ប្រទេសចិនពុំមែនជាវិស័យប្រកួតប្រជែងជាមួយវិស័យកសិកម្មរបស់កម្ពុជានោះទេ។ ផ្ទុយពីប្រទេសចិន កម្ពុជានៅតែផ្ដោតជាសំខាន់លើវិស័យកសិកម្ម និងបើផ្អែកលើវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្ពុជា-ចិន កសិកម្មជាវិស័យដែលត្រូវបានផ្ដល់តម្លៃខ្ពស់ជាងគេ ដូចនេះ វាជាឱកាសមាសសម្រាប់កម្ពុជាក្នុងការទាញយកអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងមួយនេះ។"*

បើទោះបីជាប្រទេសចិនជាមហាអំណាចខាងផលិតកម្មទំនិញសព្វសារពើ មានទាំងផលិតផលកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងបច្ចេកវិទ្យានានាក្ដី ក៏យើងសង្កេតឃើញថា ប្រទេសនេះនៅតែមានតម្រូវការផលិតផលជាច្រើនពីដៃគូពាណិជ្ជកម្មរបស់ខ្លួន ដើម្បីបំពេញតម្រូវការក្នុងស្រុកផងដែរ។ ជាក់ស្ដែង ក្នុងបរិបទពាណិជ្ជកម្ម ការផ្លាស់ប្ដូរទំនិញពីប្រទេសដៃគូ គឺជារឿងសាមញ្ញ ដែលវិសាលភាពរបស់វាអាស្រ័យលើកត្តាជាច្រើនដូចជា តម្រូវការជាក់ស្ដែងក្នុងស្រុក ឬតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសជាដៃគូជាដើម។

# ជំពូក ៥
# សន្និដ្ឋាននិងអនុសាសន៍

## ៥.១. សេចក្តីសន្និដ្ឋាន

យើងសង្កេតឃើញថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននឹងដើរតួយ៉ាងសំខាន់ក្នុងការពង្រីកនូវពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា ក៏ដូចជាជម្រុញនូវកំណើនសេដ្ឋកិច្ចជាតិទាំងមូលផងដែរ។ ក្នុងក្របខណ្ឌគតិយុត្តិ ក៏ដូចជាតាមវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ទាំងកម្ពុជានិងចិន សុទ្ធតែទទួលបាននូវអត្ថប្រយោជន៍យ៉ាងច្រើន បើទោះបីជាវិសាលភាពនៃអត្ថប្រយោជន៍នៃប្រទេសទាំងពីរ ពុំអាចធ្វើការប្រៀបធៀបគ្នាបានក៏ដោយ។ បើផ្អែកលើស្ថានភាពជាក់ស្តែង ក្នុងរយៈពេលខ្លី កម្ពុជាពុំទាន់អាចទាញយកអត្ថប្រយោជន៍ឱ្យបានពេញលេញចេញពីកិច្ចព្រមព្រៀងនេះនៅឡើយទេ ដោយសារតែកម្ពុជាពុំទាន់បានត្រៀមខ្លួនរួចរាល់ក្នុងវិស័យផលិតកម្មរបស់ខ្លួន រួមទាំងបញ្ហាប្រឈមជាច្រើនដែលកម្ពុជាកំពុងជួបប្រទះ ដូចដែលបានរៀបរាប់ក្នុងជំពូកទី៣ខាងលើ។ កម្ពុជាចាំបាច់ត្រូវស្វែងរកដំណោះស្រាយសមស្របសម្រាប់បញ្ហាប្រឈមនានា ទាំងក្នុងវិស័យផលិតកម្ម និងសេវាកម្ម។ ក្រៅពីបញ្ហាប្រឈមទាំងនេះ ចំពោះកម្ពុជា ការពង្រីកនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មឱ្យបានកាន់តែទូលំទូលាយគឺជាគន្លឹះដ៏សំខាន់ ដើម្បីធ្វើឱ្យមានភាពរឹងមាំសម្រាប់សេដ្ឋកិច្ចជាតិ ក៏ប៉ុន្តែ ការពឹងផ្អែកទៅលើតែប្រទេសមួយខ្លាំងពេក នឹងធ្វើឱ្យកម្ពុជាពិបាកនឹងនឹងទ្រាំទ្រទៅនឹងហានិភ័យខាងក្រៅផងដែរ។ ដូចដែលយើងបានឃើញស្រាប់តាមរយៈទឡ្ហីករណ៍នៃតម្រូវការភ្ញៀវទេសចរ ក៏ដូចជាវត្ថុធាតុដើមឧស្សាហកម្មពីសំណាក់កម្ពុជា ក្នុងអំឡុងពេលនៃវិបត្តិកូវីដ-១៩នេះជាដើម។

ដើម្បីឆ្លើយតបទៅនឹងវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិននេះ យើងសង្កេតឃើញថា វិស័យកសិកម្មមានបញ្ហាប្រឈមខ្លាំងជាងគេ ទាំងក្នុងក្របខណ្ឌបរិមាណផលិតកម្ម គុណភាព តម្លៃផលិតកម្ម ក៏ដូចជាកង្វះនូវការច្នៃប្រឌិតផលិតផលកសិកម្ម ដើម្បីតម្រូវការក្នុងវិស័យឧស្សាហកម្ម ឬវិស័យផ្សេងទៀត។ បន្ថែមពីលើនេះ យើងអាចធ្វើការសន្និដ្ឋានបានថា វិស័យសេវាកម្ម

របស់កម្ពុជាពុំទាន់អាចមានសក្តានុពលគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ទៅកាន់ប្រទេសចិនឱ្យបានសម្បូរបែបនៅឡើយទេ ជាពិសេសក្នុងវិស័យបច្ចេកវិទ្យា និងវិស័យដែលមានតម្រូវការជំនាញឯកទេសខ្ពស់។ បើពិនិត្យទៅលើស្ថានភាពជាក់ស្តែងក្នុងវិស័យនេះ កម្ពុជាប្រហែលអាចផ្គត់ផ្គង់បានលើសេវាកម្មប្រឹក្សាដូចជាផ្នែកច្បាប់ ហិរញ្ញវត្ថុ ឬប្រឹក្សាក្នុងការចាប់ផ្តើមអាជីវកម្មក្នុងប្រទេសកម្ពុជាជាដើម។ សេវាកម្មដែលយើងមានប្រតិបត្តិករច្រើនជាមួយប្រទេសចិនអាចក្នុងវិស័យទេសចរណ៍ ក៏ប៉ុន្តែវិស័យមួយនេះច្រើនតែកើតឡើងក្នុងទម្រង់សហប្រតិបត្តិការរវាងប្រតិបត្តិករទេសចរណ៍ក្នុងប្រទេសទាំងពីរ ជាជាងការផ្តល់សេវាកម្មឱ្យគ្នាទៅវិញទៅមកក្នុងទម្រង់ពាណិជ្ជកម្ម។

ផ្ទុយពីកម្ពុជា ប្រទេសចិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់នូវសេវាកម្មគ្រប់ប្រភេទដល់ដៃគូនានាក្នុងប្រទេសកម្ពុជា ទាំងសេវាកម្មបណ្តុះបណ្តាលអ្នកជំនាញ ការប្រឹក្សា បច្ចេកវិទ្យា ស្ថាបត្យកម្ម វិស្វកម្ម និងសេវាកម្មផ្សេងៗជាច្រើនទៀត។

## ៥.២. អនុសាសន៍សម្រាប់កម្ពុជា

បើទោះបីជា កម្ពុជានៅមានឱកាសច្រើនក្នុងការទាញយកអត្ថប្រយោជន៍ចេញពីកិច្ចព្រមព្រៀងពាណិជ្ជសេរីកម្ពុជា-ចិនក្តី ប៉ុន្តែកម្ពុជាកំពុងប្រឈមនឹងបញ្ហាប្រឈមជាច្រើនផងដែរ។ ដើម្បីអាចទាញអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងនេះកម្ពុជាចាំបាច់ត្រូវអនុវត្តនូវកិច្ចការជាច្រើនបន្ថែមទៀត ជាពិសេសត្រូវឆ្លើយតបទៅនឹងបញ្ហាប្រឈមដូចដែលបានលើឡើងនៅក្នុងជំពូកទី៣ខាងលើ។ ខាងក្រោមនេះជាអនុសាសន៍មួយចំនួនសម្រាប់រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានាធ្វើការពិចារណាដើម្បីទាញយកអត្ថប្រយោជន៍ឱ្យបានជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន។

### ៥.២.១. ពង្រឹងកិច្ចសហការរដ្ឋនិងឯកជន

មិនខុសពីប្រទេសនានាក្នុងពិភពលោក នៅកម្ពុជា វិស័យឯកជនគឺជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិយ៉ាងសំខាន់ដោយសារវិស័យនេះ មិនត្រឹមតែបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍនៃវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម និងវិស័យផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបានចូលរួមបង្កើតនូវការងារជូនប្រជាពលរដ្ឋខ្មែររាប់សែននាក់ផងដែរ។ ដើម្បីធ្វើឱ្យការចូលរួមរបស់វិស័យឯកជនកាន់តែសកម្មបន្ថែមទៀតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ជាពិសេសក្នុងដំណាក់កាលដែលកម្ពុជាកំពុងមានតម្រូវការចាំបាច់

បំផុតក្នុងការកៀងគរការវិនិយោគពីគ្រប់មជ្ឈដ្ឋាន កិច្ចសហការគ្នារវាងវិស័យរដ្ឋ និងឯកជន ដោយឈរលើមូលដ្ឋានអត្ថប្រយោជន៍រួមគ្នា ជារឿងចាំបាច់បំផុតសម្រាប់កម្ពុជា។ ជាក់ស្តែងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង ក៏ធ្លាប់បានទទួចផងដែរដល់ស្ថាប័នឯកជនត្រូវសហការគ្នាឱ្យបានជិតស្និទជាមួយភាគីរដ្ឋាភិបាលដើម្បីវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គម (Niem, Chheng, ២០១៩)។ ស្របពេលដែលកម្ពុជាមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសចិន ការពង្រឹងនូវវិស័យផលិតកម្ម និងសេវាកម្មដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ទាមទារឱ្យមានការចូលរួមខ្លាំងពីសំណាក់ក្រុមហ៊ុន និងសហគ្រាសឯកជននានា ដើម្បីទាញយកអត្ថប្រយោជន៍ឱ្យបានជាអតិបរមា។

ដើម្បីទាក់ទាញការវិនិយោគលើវិស័យឧស្សាហកម្មគឺជារឿងចាំបាច់មួយរបស់រាជរដ្ឋាភិបាល ជាពិសេសការកៀងគរការវិនិយោគទុនពីបរទេសឱ្យបានកាន់តែច្រើន។ រាជរដ្ឋាភិបាលកម្ពុជា អាចធ្វើការពិនិត្យ និងរៀបចំគោលនយោបាយវិនិយោគទុន ដែលអាចមានភាពទាក់ទាញច្រើនជាងមុនសម្រាប់អ្នកវិនិយោគបរទេស ជាពិសេសសម្រាប់ការវិនិយោគដែលអាចបង្កើតការងារបានច្រើនសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ដើម្បីសម្រេចកិច្ចការនេះបាន កម្ពុជាអាចពិចារណាលើគំនិតយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

- បង្កើតនូវបរិស្ថានវិនិយោគដែលមានតម្លាភាព សម្រាប់អ្នកវិនិយោគទុនបរទេសតាមរយៈការពង្រឹងវិធានការផ្លូវច្បាប់សម្រាប់ការវិនិយោគជាដើម។
- ត្រូវមានផែនការច្បាស់លាស់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស កម្មករជំនាញដែលស្របទៅតាមតម្រូវការជាក់ស្តែងរបស់ទីផ្សារការងារសម្រាប់ពេលបច្ចុប្បន្ន និងអនាគត។
- ត្រូវពិនិត្យមើលលើគោលនយោបាយសម្បទានផ្នែកវិនិយោគ ដើម្បីធានាឱ្យបាននូវបរិស្ថានដែលមានគុណភាពសម្រាប់ទាក់ទាញវិនិយោគិនបរទេស។
- ត្រូវអនុវត្តគោលនយោបាយទ្រទ្រង់ផលិតករ និងអ្នកផ្គត់ផ្គង់ក្នុងស្រុក និងផ្សារភ្ជាប់ជាមួយនឹងការវិនិយោគបរទេស។

- ពង្រាយតំបន់ឧស្សាហកម្មឱ្យបានរាយប៉ាយទៅតាមខេត្ត ឬតំបន់ជនបទនានា ដែលយន្តការនេះមិនត្រឹមតែអាចបង្កើតការងារបន្ថែមទៀតនោះទេ ប៉ុន្តែថែមទាំងអាចជម្រុញវិស័យអចលនទ្រព្យ និងបង្កើតមុខរបរ ឬអាជីវកម្មជូនប្រជាពលរដ្ឋរស់នៅតំបន់ក្បែរៗនោះផងដែរ។

## ៥.២.២. ធ្វើទំនើបកម្មវិស័យកសិកម្ម

ដូចដែលបានបញ្ជាក់ពីខាងដើម វិស័យកសិកម្មគឺជាវិស័យដែលមានសក្តានុពលខ្ពស់បំផុតមួយរបស់កម្ពុជា សម្រាប់វឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គម ជាពិសេសក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រ។ ដោយឡែក វិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ក៏បានផ្តោតជាសំខាន់ទៅលើវិស័យនេះផងដែរ។ ជាមួយនឹងស្ថានភាពជាក់ស្តែង និងបញ្ហាប្រឈមក្នុងវិស័យកសិកម្មមួយចំនួន ដូចដែលបានបង្ហាញក្នុង**ចំណុច៣.១.១** ខាងលើ កម្ពុជាចាំបាច់ត្រូវធ្វើទំនើបកម្មក្នុងវិស័យមួយនេះ ដើម្បីអាចទាញយកអត្ថប្រយោជន៍ជាអតិបរមាចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលកម្ពុជាមានស្រាប់ជាមួយប្រទេសចិន។ ការធ្វើទំនើបកម្មវិស័យកសិកម្ម មិនត្រឹមតែអាចបង្កើននូវបរិមាណផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចឱ្យកម្ពុជាទទួលបាននូវផលិតផលដែលមានគុណភាពប្រសើរជាងមុន ដែលអាចធ្វើឱ្យកម្ពុជាពង្រឹងបាននូវលទ្ធភាពប្រកួតប្រជែងបន្ថែមទៀតលើវិស័យមួយនេះ ទាំងសម្រាប់ការនាំចេញទៅប្រទេសចិន និងប្រទេសនានានៅលើពិភពលោកផងដែរ។

ខាងក្រោមនេះជាគំនិតអនុសាសន៍មួយចំនួនដែលរាជរដ្ឋាភិបាលកម្ពុជា អាចធ្វើការពិចារណាក្នុងកិច្ចការងារធ្វើទំនើបកម្មវិស័យកសិកម្មរបស់ខ្លួន។

### ក) ពង្រឹងគោលនយោបាយវិនិយោគ

វិស័យឯកជនបានដើរតួយ៉ាងសំខាន់ក្នុងវឌ្ឍនភាពលើគ្រប់វិស័យទាំងអស់ ដូចនេះកម្ពុជាចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយវិនិយោគរបស់ខ្លួនក្នុងវិស័យកសិកម្ម ដើម្បីកៀងគរ និងជំរុញការវិនិយោគបន្ថែមទៀតលើវិស័យមួយនេះ។ ការទាក់ទាញការវិនិយោគពីបរទេសគឺជារឿងចាំបាច់ ក៏ប៉ុន្តែការលើកទឹកចិត្តឱ្យអ្នកវិនិយោគទុនក្នុងស្រុកចូលរួមឱ្យបានសកម្មក្នុងវិស័យនេះ នឹងកាន់

តែធ្វើឱ្យកម្ពុជាមានមូលដ្ឋានកាន់តែរឹងមាំបន្ថែមទៀត។ គោលនយោបាយវិនិយោគ គួរផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ផ្តល់អត្ថប្រយោជន៍បន្ថែមទៀត (ផ្តល់ជាសម្បទានផ្សេងៗដូចជា ការលើកលែងពន្ធ ការផ្តល់ដីសម្បទានកសិកម្ម ។ល។) ចំពោះការវិនិយោគលើវិស័យកសិកម្ម ជាពិសេសការវិនិយោគដែលអាចបង្កើតការងារកាន់តែច្រើនក្នុងវិស័យមួយនេះ។
- លើកទឹកចិត្តខ្ពស់ជាងមុនសម្រាប់វិនិយោគិនក្នុងស្រុក
- លើកទឹកចិត្តខ្ពស់សម្រាប់ការវិនិយោគទៅលើផលិតកម្មវត្ថុធាតុដើមកសិកម្ម (ជីរ គ្រាប់ពូជ ថ្នាំសត្វល្អិត បរិក្ខារកសិកម្មជាដើម) កសិ-ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មកែច្នៃ និងការវិនិយោគផលការបង្កើត ឬច្នៃប្រឌិតបច្ចេកវិទ្យាដែលមានតម្លៃសមរម្យ (Affordable Technology) សម្រាប់កសិកម្មក្នុងស្រុក។
- លើកទឹកចិត្តខ្ពស់ចំពោះការវិនិយោគលើវិស័យកសិកម្ម ដែលផ្តោតទៅលើនិរន្តរភាពបរិស្ថាន និងផលិតកម្ម
- ពង្រឹងគុណភាពនៃកម្មវិធីកសិកម្មដែលបានដាក់ចេញដោយការវិនិយោគបន្ថែមទាំងធនធានថវិកា និងធនធានមនុស្ស
- លើកទឹកចិត្តវិនិយោគិនក្នុងការវិនិយោគលើដំណាំឱ្យបានច្រើនប្រភេទជាជាងផ្តោតតែលើដំណាំយុទ្ធសាស្ត្រមួយចំនួនដែលបានរៀបរាប់ក្នុង **ចំណុច៣.១.១** ខាងលើ។

## ខ) កសាងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ

ដើម្បីបង្កើននូវបរិមាណ ក៏ដូចជាគុណភាពក្នុងផលិតកម្មដំណាំកសិកម្មរបស់ខ្លួន កម្ពុជាចាំបាច់ត្រូវកសាងនូវហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រថ្មីៗបន្ថែមទៀត។ ការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងនេះត្រូវភ្ជាប់ជាមួយនឹងប្រព័ន្ធផ្លូវទឹកខ្វាត់ខ្វែង ជាពិសេសត្រូវរុញទឹកទៅកាន់តំបន់ផលិតកម្មឱ្យបានកាន់តែជិត កាន់តែល្អ។ ការរុញទឹកទៅដល់ ឬក្បែរតំបន់ផលិតកម្ម ក៏ជាការចូលរួមជួយប្រជាពលរដ្ឋ ឬផលិតករនានាក្នុងការកាត់បន្ថយតម្លៃដើមផលិតកម្មបានមួយកម្រិតផងដែរ។ ជាមួយគ្នានេះ ក្រៅពីការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ក៏ជារឿងចាំបាច់មួយផងដែរ។

## ខ) រៀបចំគោលនយោបាយទឹកឱ្យបានច្បាស់លាស់

ក្រៅពីការកសាង ស្តាបនា ឬស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ កម្ពុជាចាំបាច់ត្រូវមានគោលនយោបាយក្នុងការគ្រប់គ្រងទឹកឱ្យបានច្បាស់លាស់ផងដែរ។ ការមានគោលនយោបាយគ្រប់គ្រងទឹកច្បាស់លាស់ អាចនឹងផ្តល់ផលចំណេញក្នុងរូបភាពជាច្រើនដូចជា៖

- ធានាបាននូវនិរន្តរភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ទឹកដល់គោលដៅដែលមានតម្រូវការចាំបាច់
- ធានាបាននូវផលប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីជាតិនានា
- អាចនឹងផ្តល់ផលវិជ្ជមានផងដែរដល់ការគ្រប់គ្រង និងថែទាំហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធទឹកទាំងនោះ
- អាចធ្វើឱ្យប្រជាកសិករ និងផលិតករអាចធ្វើការដាំដុះបានលើសពីមួយដងក្នុងមួយឆ្នាំ ដែលនេះជាការចូលរួមក្នុងការបង្កើននូវបរិមាណផលិតផល ក៏ដូចជាកាត់បន្ថយនូវតម្លៃដើមផលិតកម្មផងដែរ។
- ការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់ដល់ដំណាំ អាចធ្វើឱ្យគុណភាពផលិតផលមានការកើនឡើងថែមមួយកម្រិតទៀតផងដែរ។

## គ) ពង្រឹងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម

ដូចដែលបានធ្វើការគូសបញ្ជាក់ខាងលើ ប្រជាកសិករកម្ពុជាមានការខ្វះខាតខ្លាំងទៅលើបច្ចេកទេសក្នុងការបង្កបង្កើនផលដំណាំ ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាដើម្បីបម្រើការដាំដុះរបស់ខ្លួន។ រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានាចាំបាច់ត្រូវដើរតួជាអ្នកបណ្តុះបណ្តាលជំនាញ និងបច្ចេកទេសដាំដុះដល់កសិករកង្វះខាតនូវបច្ចេកទេសក្នុងការដាំដុះទាំងការរៀបចំដី ការដាក់ជី ការប្រើថ្នាំ ។ល។ ជាមួយនឹងកិច្ចការនេះ រាជរដ្ឋាភិបាលអាចរៀបចំជាគម្រោងអភិវឌ្ឍនានាដោយផ្តោតលើការដាំដុះដំណាំកសិកម្មនានា ដោយប្រើប្រាស់បច្ចេកវិទ្យាដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែងរបស់ប្រជាកសិករ។ ការជម្រុញឱ្យមានការបណ្តុះបណ្តាលការប្រើប្រាស់បច្ចេកវិទ្យា និងការវិភាគទាននានា

(សម្បទានដាថវិកា ឬផ្តល់នូវបរិក្ខារបច្ចេកវិទ្យា) ដល់ប្រជាកសិករដើម្បីចាប់យក និងអនុវត្តក្នុងកិច្ចការងារដាំដុះដំណាំកសិកម្ម។

## ឃ) រៀបចំការដាំដុះដោយប្រមូលផ្តុំ

ដូចដែលបានបង្ហាញក្នុងខាងលើ ការដាំដុះក្នុងប្រទេសកម្ពុជាមានលក្ខណៈជាគ្រួសារ និងស្ថិតនៅរាយប៉ាយ មិនស្ថិតនៅផ្តុំគ្នា ឬការដាំដុះតាមបែបជាសហគមន៍ជាដើម។ ទម្លាប់នៃការដាំដុះប្រភេទនេះ មិនត្រឹមតែពុំអាចធានាបាននូវស្ថិរភាពនៃការផ្គត់ផ្គង់ប៉ុណ្ណោះទេ ថែមទាំងពិបាកក្នុងការទទួលបាននូវកញ្ចប់ថវិកាដើម្បីពង្រីកការដាំដុះ ឬទទួលបានការបណ្តុះបណ្តាលបច្ចេកទេសដាំដុះជាដើម។ ដើម្បីធានាបាននូវនិរន្តរភាពនៃផលិតកម្ម ក៏ដូចជាការផ្គត់ផ្គង់ រដ្ឋាភិបាលត្រូវជម្រុញនិងគាំទ្រតាមគ្រប់រូបភាព នូវការចងជាសហគមនៅតាមស្រុក ខេត្ត ឬតំបន់ដែលមានសក្តានុពលការដាំដុះ។ ការចងក្រងជាសហគមន៍ អាចផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- អាចធានាបាននូវផលិតកម្ម និងការផ្គត់ផ្គង់នៅលើទីផ្សារ
- ងាយស្រួលក្នុងការគ្រប់គ្រងផលិតកម្ម ដែលអាចធ្វើឱ្យមានការជោរជន់ និងតម្លៃថោក
- ងាយស្រួលក្នុងការបំពាក់បំប៉នបច្ចេកទេស ឬបច្ចេកវិទ្យាកសិកម្មនានា
- ងាយស្រួលក្នុងការទទួលបាននូវថវិកាកម្ចី ឬថវិកាឧបត្ថម្ភនានា ជាពិសេសសមាជិកដែលខ្វះលក្ខខណ្ឌដើម្បីទទួលបានប្រាក់កម្ចីពីធនាគារ
- អាចបង្កើនថវិកាសហគមន៍តាមរយៈការបង្កើតជាមូលនិធីសន្សំសម្រាប់ជួយគ្នា
- ងាយស្រួលក្នុងការរៀបចំប្រព័ន្ធធារាសាស្ត្រនិងការស្រោចស្រព

## ង) ផ្តោតលើប្រភេទដំណាំយុទ្ធសាស្ត្រ

ជាឧទាហរណ៍ កាលពីឆ្នាំ២០១៥កន្លងទៅ ក្នុងគោលបំណងជម្រុញនូវការនាំចេញស្រូវអង្ករទៅកាន់ទីផ្សារបរទេស ប្រទេសវៀតណាមបានកែតម្រូវនូវគោលនយោបាយស្រូវអង្ករ (Rice Policy) របស់ខ្លួន ដោយកាត់បន្ថយការដាំដុះប្រភេទស្រូវដែលមានតម្លៃទាប និងជំនួសមកវិញដោយប្រភេទដំណាំស្រូវដែលមានតម្លៃខ្ពស់វិញ។ ប្រភេទដំណាំស្រូវដែលមានតម្លៃខ្ពស់ មានទីផ្សារធំជាងស្រូវដែល

មានតម្លៃទាប។ ទាំងនេះជាយុទ្ធសាស្ត្រមួយក្នុងការឈានជើងពីការដាំដុះដើម្បីបរិភោគ (Production for Local Consumption) មកជាការដាំចុះដើម្បីនាំចេញវិញ (Production for Export)។ ប្រទេសថៃ ក៏បានអនុវត្តនូវគោលនយោបាយប្រហាក់ប្រហែលនេះដែរគឺ ដាំដុះដើម្បីផ្គត់ផ្គង់ក្នុងតំបន់ បន្តលក់ទៅកាន់តំបន់ ឬខេត្តជិតខាង រួចជំរុញបន្តដើម្បីលក់ទៅកាន់ទីផ្សារបរទេស។

ផ្អែកលើមេរៀនរបស់ប្រទេសទាំងពីរនេះ កម្ពុជាចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់ទៅលើប្រភេទដំណាំដែលជាតម្រូវការខ្លាំងរបស់ប្រទេសចិន និងជំរុញឱ្យក្លាយទៅជាដំណាំយុទ្ធសាស្ត្រសម្រាប់ប្រជាពលរដ្ឋកម្ពុជា។

### ច) ទាក់ទាញវិនិយោគលើវិស័យកសិកម្ម

ដើម្បីបង្កើននូវបរិមាណផលិតផល ក៏ដូចជាដើម្បីធានានូវការផ្គត់ផ្គង់ទាំងតម្រូវការប្រើប្រាស់ក្នុងស្រុក និងនាំចេញ កម្ពុជាចាំបាច់ត្រូវទាក់ទាញការវិនិយោគបន្ថែមទៀតក្នុងវិស័យកសិកម្ម។ ដើម្បីធ្វើទំនើបកម្មក្នុងវិស័យកសិកម្ម កម្ពុជាគួរលើកទឹកចិត្ត និងទាក់ទាញការវិនិយោគដោយផ្តោតលើចំណុចមួយចំនួនដូចខាងក្រោម៖

- ផ្តល់អត្ថប្រយោជន៍បន្ថែម (ផ្តល់ជាសម្បទានផ្សេងៗដូចជាការលើកលែងពន្ធ ការផ្តល់ជាដីសម្បទានកសិកម្ម ។ល។) ចំពោះការវិនិយោគលើវិស័យកសិកម្ម ជាពិសេសចំពោះការវិនិយោគដែលអាចបង្កើតការងារបានកាន់តែច្រើនក្នុងវិស័យមួយនេះ។
- លើកទឹកចិត្តខ្ពស់ជាងមុនសម្រាប់វិនិយោគិនក្នុងស្រុក
- លើកទឹកចិត្តខ្ពស់សម្រាប់ការវិនិយោគទៅលើផលិតកម្មវត្ថុធាតុដើមកសិកម្ម (ជី គ្រាប់ពូជ ថ្នាំសត្វល្អិត បរិក្ខារកសិកម្មជាដើម) កសិ-ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មកែច្នៃ និងការវិនិយោគផលការបង្កើត ឬច្នៃប្រឌិតបច្ចេកវិទ្យាដែលមានតម្លៃសមរម្យ (Affordable Technology) សម្រាប់កសិកម្មក្នុងស្រុក។
- លើកទឹកចិត្តខ្ពស់ចំពោះការវិនិយោគលើវិស័យកសិកម្ម ដែលផ្តោតទៅលើនិរន្តរភាពបរិស្ថាន និងផលិតកម្ម
- ពង្រឹងគុណភាពនៃកម្មវិធីកសិកម្មដែលបានដាក់ចេញដោយការវិនិយោគបន្ថែមទាំងធនធានថវិកា និងធនធានមនុស្ស

## ៥.២.៣. សិក្សាពីតម្រូវការរបស់ប្រទេសចិន

នៅក្នុង **ចំណុច៤.២.១** យើងបានធ្វើការគូសបញ្ជាក់ពីការប្រែប្រួលនៃប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសចិន ដោយមិនពឹងផ្អែកខ្លាំងលើវិស័យកសិកម្មច្រើនដូចមុន ក៏ប៉ុន្តែទឡ្ហីករណ៍នេះ ពុំមែនមានន័យថាប្រទេសចិនពុំផលិត និងធ្វើការនាំចេញផលិតផលកសិកម្មនោះទេ។ ជាក់ស្តែង លទ្ធផលស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជាកាលពីឆ្នាំ២០២០កន្លងទៅ បានរកឃើញថា បន្លែនាំចូលពីប្រទេសចិន បានឈរជើងប្រកួតប្រជែងយ៉ាងសកម្មជាមួយនឹងបន្លែក្នុងស្រុក ក៏ដូចជាបន្លែនាំចូលពីប្រទេសជិតខាងយើងមានថៃ និងវៀតណាមជាដើម (លី, ត. et all., ២០២០)។ ទោះជាយ៉ាងនេះក្តី ប្រទេសចិននៅតែមានតម្រូវការផលិតផលកសិកម្ម កសិ-ឧស្សាហកម្មពីប្រទេសនានាដើម្បីបំពេញតម្រូវការឧស្សាកម្មរបស់ខ្លួន ក៏ដូចជាបំពេញតម្រូវការជាក់ស្តែងរបស់ប្រជាជនចិន។ ដូចនេះ បន្ថែមពីការធ្វើទំនើបកម្មវិស័យកសិកម្មរបស់ខ្លួន កម្ពុជាចាំបាច់ត្រូវសិក្សាឱ្យបានលម្អិតពីតម្រូវការជាក់ស្តែងរបស់ប្រទេសចិន ទាំងក្នុងវិសាលភាពនៃទំនិញកសិកម្ម ឧស្សាកម្ម ក៏ដូចជាតម្រូវការក្នុងវិស័យសេវាកម្មផងដែរ។ ការយល់ច្បាស់ពីតម្រូវការរបស់ប្រទេសចិន នឹងធ្វើឱ្យកម្ពុជាអាចត្រៀមខ្លួនបានត្រឹមត្រូវក្នុងការផលិតនូវមុខទំនិញដែលជាតម្រូវការជាក់ស្តែង និងធានាបាននូវនិរន្តរភាពទីផ្សារផលិតផលរបស់ខ្លួន។

## ៥.២.៤. វិនិយោគលើផលិតកម្មវត្ថុធាតុដើម

តាមរបាយការណ៍ពាណិជ្ជកម្មរវាងកម្ពុជា និងចិន កម្ពុជាពឹងផ្អែកខ្លាំងទៅលើវត្ថុធាតុដើមនាំចូលពីប្រទេសចិនទាំងវត្ថុធាតុដើមក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យផ្សេងៗទៀត។ ជាការពិត វត្ថុធាតុដើមមានសារៈសំខាន់បំផុតសម្រាប់ផលិតកម្មលើគ្រប់វិស័យ ព្រោះវាមិនត្រឹមតែចូលរួមរក្សាស្ថេរភាពផលិតកម្មប៉ុណ្ណោះទេ វាថែមទាំងបានជួយកាត់បន្ថយថ្លៃដើមនៃផលិតផលសម្រេច និងបង្កើននូវចំណូលពន្ធជាតិផងដែរ។ ការវិនិយោគទៅលើការផលិតវត្ថុធាតុដើម នឹងធ្វើឱ្យកម្ពុជាទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- កាត់បន្ថយការពឹងពាក់លើបរទេសលើវត្ថុធាតុដើមផលិតកម្ម
- កម្ពុជានឹងអាចក្លាយខ្លួនពីប្រទេសប្រើប្រាស់ទៅជាប្រទេសអ្នកផលិតបន្តិចម្តងៗ

- កម្ពុជាអាចធ្វើការនាំចេញនូវផលិតផលវត្ថុធាតុដើមទៅកាន់ប្រទេសដែលមានតម្រូវការ
- ផលិតបាននូវវត្ថុធាតុដើមដែលសមស្របនឹងតម្រូវការ ឬស្ថានភាពជាក់ស្តែងរបស់ខ្លួន (ឧទាហរណ៍៖ ពូជ ជីរ ថ្នាំ ដែលសមស្របនឹងស្ថានភាពដី និងអាកាសធាតុក្នុងប្រទេស ...)
- កាត់បន្ថយថ្លៃដើមផលិតកម្ម និងការចំណាយផ្សេងៗដូចជាការដឹកជញ្ជូនជាដើម
- បង្កើតការងារក្នុងស្រុកបានកាន់តែច្រើន
- បង្កើនចំណូលពន្ធដល់ជាតិតាមរយៈការបង្កើតឱ្យមាននូវឧស្សាហកម្មផលិតវត្ថុធាតុដើម
- កាត់បន្ថយតម្លៃទំនិញក្នុងស្រុកបានមួយកម្រិតផងដែរ

## ៥.២.៥. ធ្វើឱ្យប្រសើរនូវបរិស្ថានវិនិយោគ

កម្ពុជាមានប្រព័ន្ធសេដ្ឋកិច្ចបែបទីផ្សារសេរី ដែលធ្វើឱ្យវិស័យឯកជនបានដើរតួយ៉ាងសំខាន់នៅក្នុងចរន្តសេដ្ឋកិច្ចជាតិ និងការរីកចម្រើនលើគ្រប់វិស័យ។ ដើម្បីបន្តជម្រុញនូវវឌ្ឍនភាពនេះ កម្ពុជាចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនូវបរិស្ថានវិនិយោគរបស់ខ្លួន ដើម្បីកៀងគរអ្នកវិនិយោគទុនទាំងក្នុងស្រុក និងក្រៅស្រុក។ ហេដ្ឋារចនាសម្ព័ន្ធវិនិយោគ ដើរតួយ៉ាងសំខាន់ក្នុងការទាក់ទាញអ្នកវិនិយោគទុនទាំងក្នុងស្រុក និងក្រៅស្រុក។ ការមានប្រព័ន្ធដឹកជញ្ជូនសម្បូរបែបទាំងផ្លូវទឹក ផ្លូវថ្នល់ ផ្លូវដែក និងផ្លូវអាកាស នឹងជួយកាត់បន្ថយថ្លៃដើមផលិតកម្មបានមួយកម្រិតធំផងដែរ។ បន្ថែមពីលើនេះ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី និងប្រព័ន្ធទឹកស្អាត ក៏ជារឿងចាំបាច់មួយទៀតដែលកម្ពុជាត្រូវបន្ថែមការវិនិយោគផងដែរ។ ដើម្បីកាត់បន្ថយតម្លៃដើមផលិតកម្ម កម្ពុជាចាំបាច់ត្រូវផ្តល់នូវអគ្គិសនីដែលមានតម្លៃទាបជាងពេលបច្ចុប្បន្ន ឬមានតម្លៃថោកជាង ឬប្រហាក់ប្រហែលនឹងប្រទេសជិតខាងកម្ពុជា។ ហេដ្ឋារចនាសម្ព័ន្ធទាំងនេះ នឹងដើរតួយ៉ាងសំខាន់ក្នុងការកាត់បន្ថយការចំណាយលើថ្លៃដើមផលិតកម្ម និងសម្រួលដល់ការដឹកជញ្ជូនផងដែរ។

## ៥.២.៦. លើកទឹកចិត្តសហគ្រាសតូចនិងមធ្យម

សហគ្រាសខ្នាតតូច និងមធ្យម ដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ខណៈដែលវាបានបង្កើតការងារស្មើនឹងចំនួន៧០% នៃការងារសរុបក្នុងស្រុក។ ផ្អែកលើទឡ្ហីករណ៍នេះ រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ខ្ពស់លើការជម្រុញសហគ្រាសធុនតូច និងមធ្យម

លើគ្រប់វិស័យរួមមាន ទេសចរណ៍ អចលនទ្រព្យ បច្ចេកវិទ្យា អប់រំ កសិកម្ម និងសិប្បកម្មជាដើម។ ការសម្រួលនីតិវិធីអាជីវកម្ម និងការផ្ដល់ទុនវិនិយោគដែលមានអត្រាការប្រាក់ទាប ក៏ជាយន្តការមួយដើម្បីជម្រុញសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាបានច្រើនផងដែរ។

ដើម្បីចូលរួមក្នុងការទាញយកអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កម្ពុជាចាំបាច់ត្រូវលើកទឹកចិត្តសហគ្រាសតូច និងមធ្យមតាមគ្រប់មធ្យោបាយដូចជាសម្រួលបែបបទចុះបញ្ជីអាជីវកម្ម ការធ្វើសម្បទានផ្នែកពន្ធ ។ល។ សហគ្រាសដែលគួរត្រូវបានការលើកទឹកចិត្តខ្ពស់ ត្រូវស្ថិតក្នុងវិសាលភាពនៃតម្រូវការជាក់ស្ដែងជាអត្ថិភាពដូចខាងក្រោម៖

- ផលិតកម្មវត្ថុធាតុដើមកសិកម្មដូចជា ជីរ គ្រាប់ពូជ និងថ្នាំសម្លាប់សត្វល្អិតបែបសរីរាង្គជាដើម។
- ការកែច្នៃផលិតផលកសិកម្ម ទៅជាផលិតផល សម្រេច ឬពាក់កណ្ដាលសម្រេចជាដើម។
- ការកែច្នៃកាកសំណល់ក្នុងវិស័យកសិកម្មដែលគាំពារដល់បរិស្ថាន
- ផ្ដោតលើបច្ចេកវិជ្ជាទំនើបប្រកបដោយនវានុវត្តន៍
- ផ្ដោតលើវិស័យសេវាកម្មដើម្បីបំពេញតម្រូវការពាណិជ្ជកម្មក្នុងវិស័យមួយនេះ

### ៥.២.៧. ពង្រឹងនិងវិនិយោគវិស័យដឹកជញ្ជូន

ការដឹកជញ្ជូន អាចចាត់ទុកថាជាវិស័យដ៏សំខាន់មួយក្នុងការធានានូវប្រសិទ្ធិភាព គុណភាព និងភាពជោគជ័យនៃអាជីវកម្មទាំងតូចទាំងធំ ជាពិសេសធ្វើឱ្យវិស័យពាណិជ្ជកម្មដំណើរការប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធិភាព។ ការធានាបាននូវគុណភាព នៃសេវាផ្គត់ផ្គង់ទំនិញតាមពេលកំណត់ ការគ្រប់គ្រង និងផ្ដល់ព័ត៌មានផលិតផលប្រកបដោយតម្លាភាព គឺជាគន្លឹះក្នុងការជំរុញឱ្យខ្សែសង្វាក់តម្រូវការ និងការផ្គត់ផ្គង់ (Demand & Supply Chain) ដំណើរការទៅបានដោយរលូន។ កម្ពុជាចាំបាច់ត្រូវបង្កើនការវិនិយោគលើវិស័យដឹកជញ្ជូនរបស់ខ្លួន ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាជឿន ដើម្បីគ្រប់គ្រង និងជំរុញដំណើរការឱ្យកាន់តែមានប្រសិទ្ធិភាពបន្ថែមទៀត។ ការវិនិយោគ និងពង្រឹងវិស័យដឹកជញ្ជូនរបស់ខ្លួន មិនត្រឹមតែផ្ដល់នូវអត្ថប្រយោជន៍ក្នុងពាណិជ្ជកម្មសេរីកម្ពុជា-ចិនប៉ុណ្ណោះទេ ប៉ុន្តែកម្ពុជាក៏អាចទាញអត្ថប្រយោជន៍ចេញពីពាណិជ្ជកម្មរវាងដៃគូផ្សេងទៀត ក៏ដូចជាសម្រាប់ប្រតិបត្តិការក្នុងស្រុកផងដែរ។ ក្នុងបរិបទនៃការរីកចម្រើនលើបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ឬបច្ចេកវិទ្យា Block

Chain ជាដើម ការវិនិយោគលើវិស័យដឹកជញ្ជូនដោយប្រើបច្ចេកវិទ្យាទាំងនេះ នឹងកាន់តែបង្កើននូវប្រសិទ្ធិភាពទំនាក់ទំនងនៃការដឹកជញ្ជូនរវាងប្រទេសជាដៃគូបានកាន់តែមានប្រសិទ្ធិភាព។

## ៥.២.៨. បង្កើតឱ្យមានចង្កោមឧស្សាហកម្ម

ដើម្បីបង្កើនសក្តានុពលក្នុងវិស័យផលិតកម្មរបស់ខ្លួន កម្ពុជាចាំបាច់ត្រូវរៀបចំបង្កើតនូវចង្កោមឧស្សាហកម្ម (Industrial Cluster ឬ Clustered SMEs) ដែលអាចពឹងផ្អែកគ្នាទៅវិញទៅមកបាន ជាពិសេសក្នុងការផ្គត់ផ្គង់នូវវត្ថុធាតុដើមសម្រាប់ផលិតកម្ម ទាំងប្រភេទវត្ថុធាតុដើមដំបូង ឬផលិតផលពាក់កណ្តាលសម្រេច។ ចង្កោម ឬបណ្តុំឧស្សាហកម្មដែលមានដំណើរការផលិតកម្មច្រើននៅជុំគ្នា នឹងធ្វើឱ្យកម្ពុជានូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- ➩ កាត់បន្ថយការពឹងផ្អែកការផ្គត់ផ្គង់វត្ថុធាតុដើមពីបរទេសដែលធ្វើឱ្យចំណេញថវិកាច្រើនទាំងការបង់ពន្ធនាំចូល ការដឹកជញ្ជូន និងថ្លៃសេវាផ្សេងៗបន្ថែមទៀត
- ➩ កាត់បន្ថយថ្លៃដើមផលិតកម្មបានច្រើនដែលនឹងបង្កើននូវលទ្ធភាពប្រកួតប្រជែងនៃទំនិញរបស់កម្ពុជានៅលើទីផ្សារប្រទេសចិន ក៏ដូចជាប្រទេសផ្សេងទៀត
- ➩ កាត់បន្ថយនូវតម្លៃទំនិញលើទីផ្សារក្នុងស្រុក ដែលជាការចូលរួមចំណែកក្នុងការកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ
- ➩ បង្កើតការងារដល់ប្រជាពលរដ្ឋបានកាន់តែច្រើន និងសម្បូរបែប។
- ➩ ។ល។

## ៥.២.៩. ពង្រីកការអភិវឌ្ឍធនធានមនុស្ស

ធនធានមនុស្សដើរតួសំខាន់បំផុតមិនថាក្នុងវិស័យផលិតកម្ម ឬសេវាកម្មនោះទេ ប៉ុន្តែវាបានចូលរួមចំណែកយ៉ាងច្រើនដល់វិស័យផ្សេងទៀត រួមទាំងការធ្វើឱ្យប្រសើរឡើងនូវកំណើនសេដ្ឋកិច្ច និងសង្គមកម្ពុជាផងដែរ។ កម្ពុជាចាំបាច់ត្រូវមានផែនការច្បាស់លាស់ទៅលើការងារបណ្តុះបណ្តាលកម្មករជំនាញ និងជាពិសេសផ្តោតលើការបច្ចេកវិទ្យាថ្មីៗដូចជា ការវិភាគទិន្នន័យ Logistics បញ្ញាសិប្បនិម្មិតជាដើម។ ការបណ្តុះបណ្តាលធនធានមនុស្សត្រូវមើលទៅលើតម្រូវការជាក់ស្តែងនាពេលបច្ចុប្បន្ន និង

អនាគត។ ស្ថាប័នបណ្ដុះបណ្ដាលដូចជា សាលាបច្ចេកទេស សាកលវិទ្យាល័យជាដើម គួរពិនិត្យឡើងវិញនូវកម្មវិធីសិក្សារបស់ខ្លួន ធ្វើការអភិវឌ្ឍដើម្បីឱ្យស្របទៅនឹងតម្រូវការទីផ្សារការងារជាក់ស្ដែងនាពេលបច្ចុប្បន្ន និងអនាគត។

បន្ថែមពីលើនេះ ការស្រាវជ្រាវ និងបង្កើតថ្មីគឺជាធាតុដ៏សំខាន់បំផុតមួយនៅក្នុងការអភិវឌ្ឍធនធានមនុស្ស។ ជាក់ស្ដែង កម្ពុជាដើរយឺតជាងប្រទេសជិតខាងដូចជាប្រទេសថៃ និងប្រទេសវៀតណាមជាដើម ដែលកត្តានេះទាមទារឱ្យរដ្ឋាភិបាល ក៏ដូចជាវិស័យពាក់ព័ន្ធទាំងអស់ត្រូវពិចារណាឡើងវិញក្នុងការបង្កើនការវិនិយោគលើការស្រាវជ្រាវឱ្យបានទូលំទូលាយ។ ជាមួយនឹងវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កម្ពុជាចាំបាច់ត្រូវបណ្ដុះបណ្ដាលធនធានមនុស្សដែលមានសមត្ថភាពលើចំណុចមួយចំនួនដូចខាងក្រោម៖

- ស្រាវជ្រាវទៅលើការបង្កើត បង្កាត់ ឬវត្ថុធាតុដើមកសិកម្មដូចជាគ្រាប់ពូជ ជី និងថ្នាំសម្លាប់សត្វល្អិតជាដើមដែលសមស្របទៅនឹងស្ថានភាពអាកាសធាតុ ដី និងបរិយាកាសកម្ពុជា
- ស្រាវជ្រាវទៅលើវិស័យបច្ចេកវិជ្ជាទំនើប និងមាននវានុវត្តន៍ ជាពិសេសបម្រើឱ្យវិស័យសេវាកម្មដើម្បីអាចឱ្យកម្ពុជាទាញយកអត្ថប្រយោជន៍បន្ថែមទៀតចេញពីពាណិជ្ជកម្មលើវិស័យមួយនេះ
- ស្រាវជ្រាវ ច្នៃប្រឌិត ឬបង្កើតថ្មីនូវបរិក្ខារ និងបច្ចេកវិទ្យាកសិកម្មដែលមានតម្លៃសមរម្យ និងសមស្របទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ប្រជាកសិករកម្ពុជា
- ស្រាវជ្រាវទៅលើបច្ចេកវិទ្យា ឬវិធីសាស្ត្រសមស្របសម្រាប់ការការពារដំណាំកសិកម្មពីការប្រែប្រួលអាកាសធាតុ និងជំងឺលើដំណាំ ឬសត្វចិញ្ចឹមបែបកសិកម្មផ្សេងទៀត។
- ។ល។

# ឯកសារយោង

ក្រសួងពាណិជ្ជកម្ម. (២០១៦)៖ របាយការណ៍នាំចេញ នាំចូលរបស់កម្ពុជាពីឆ្នាំ ២០០០ ដល់ ២០១៦

ចាន់ មង្គល. (២០២០, ១៣តុលា). កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-កូរ៉េ គ្រោងបញ្ចប់ការចរចានៅចុងឆ្នាំ២០២០, តើវានឹងជួយអ្វីខ្លះដល់សេដ្ឋកិច្ចកម្ពុជា? ដកស្រង់ចេញពីគេហទំព័រ៖ https://cambonomist.com/news/what-cambodia-could-benefit-from-fta-with-south-korea/

លី, ត. et al. (២០២០). បន្លែកម្ពុជា៖ ផលិតកម្ម ចរន្តទីផ្សារ បញ្ហាប្រឈម និងដំណោះស្រាយ. រាជបណ្ឌិត្យសភាកម្ពុជា. ទាញយកចេញពីគេហទំព័រ៖ http://surl.li/aqnui

វណ្ណ សុគន្ធា. (២០២០, ៥សីហា). សារព័ត៌មានបរទេស៖កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន អាចចុះថ្ងៃទី១២ សីហាចំថ្ងៃEUដកផ្នែកខ្លះនៃEBA. ដកស្រង់នៅថ្ងៃ ១៥សីហា ២០២១ ចេញពីគេហទំព័រ៖ https://www.rfi.fr/km/

សឿង ភារៈ. (២០២០, ១១ តុលា). កម្ពុជា-ចិន ចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងដំណើរទស្សនៈកិច្ចរដ្ឋមន្ត្រីការបរទេសចិន. ដកស្រង់ចេញពីគេហទំព័រ៖ https://www.rfi.fr/km/

ហ៊ុន សិរីវឌ្ឍន៍. (២០២០, ១២ កុម្ភៈ). វិភាគ៖ ផលប៉ះពាល់សេដ្ឋកិច្ចកម្ពុជាពីវីរុសកូរ៉ូណាថ្មី. ស្រង់ចេញពីគេហទំព័រសំឡេងប្រជាធិបតេយ្យ VOD៖ https://vodkhmer.news/2020/02/12/affect-of-coronavirus-to-cambodia-economy/

Adam Barone. (2020, 29th January). Free Trade Agreement (FTA). Retrieved from: https://www.investopedia.com/terms/f/free-trade.asp

Beaulieu, E. (2007). Trade in services. *Handbook on International Trade Policy*, 150–162. https://doi.org/10.3362/9781780440996.005

Boi.Com. (nd). Utility Costs. Retrieved from: https://www.boi.go.th/index.php?page=utility_costs

CDC. ( nd ). Investment Trend. Retrieved on 24th October, 2021 from: http://www.cambodiainvestment.gov.kh/why-invest-in-cambodia/investment-enviroment/investment-trend.html

Chea Vannak. ( 2020, 7th March ). Cambodia's imports exceeds exports by $7.7 billion in 2019. Retrieved from: https://www.khmertimeskh.com/699170/cambodias-imports-exceeds-exports-by-7-7-billion-in-2019/#:~:text=Cambodia's%20total%20import%20and%20export,National%20Bank%20of%20Cambodia%20showed.

Chris Devonshire-Ellis. ( 2020, October 15 ). The China-Cambodia FTA to Become Cambodia's First Bilateral Free Trade Agreement. Retrieved on August 5th 2021, from: https://www.aseanbriefing.com/news/the-china-cambodia-fta-to-become-cambodias-first-bilateral-free-trade-agreement/

Deth Ieng. ( ២០២១ ). ៦ ខែឆ្នាំនេះ កម្ពុជានាំចេញកសិផលកសិកម្មទៅក្រៅប្រទេស ជាង ៤ លានតោន កើនជាង ៨០%. ដកស្រង់ចេញពីគេហទំព័រ https://www.kampucheathmey.com/local-news/152314/

Donald J. Boudreaux & Nita Ghei. ( 2018, May 23 ). The Benefits of Free Trade: Addressing Key Myths. Retrieved on August 15, 2021 from: https://www.mercatus.org/publications/trade-and-immigration/benefits-free-trade-addressing-key-myths?utm_source=ad_link&utm_medium=google&utm_campaign=premium_research

Freshnews. ( 2021, 15th November ). កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នឹងចូលជាធរមាននៅខែមករា ឆ្នាំក្រោយ, នាយករដ្ឋមន្ត្រីចិន ចង់ឃើញរាល់កសិផលកម្ពុជាអាចនាំទៅចិនផ្ទាល់ដោយមិនឆ្លងកាត់ប្រទេសដទៃ. ដកស្រង់ចេញពីគេហទំព័រ http://freshnewsasia.com/index.php/en/localnews/219884-2021-11-15-12-02-42.html

Heimkhemra SUY. (2020, 16th September). Cambodia's free trade agreement with China. Retrieved from: https://www.policyforum.net/cambodias-free-trade-agreement-with-china/

Husain Haider. (2021, May 28). Cambodia trade with China hits $3 billion. Retrieved from: https://www.khmertimeskh.com/50863783/cambodia-trade-with-china-hits-3-billion/

KC Virak. (២០២១, ០១ កក្កដា). ១ខែមិថុនានេះមាន១២ក្រុមហ៊ុនបានបោះទុនវិនិយោគនៅកម្ពុជា ជាង១៤០លានដុល្លារ. ដកស្រង់ចេញពីគេហទំព័រ៖ https://www.kampucheathmey.com/business-economic/152637/

Knoema.com. (nd). Cambodia - Contribution of travel and tourism to GDP as a share of GDP. Retrieved from: https://knoema.com/atlas/Cambodia/topics/Tourism/Travel-and-Tourism-Total-Contribution-to-GDP/Contribution-of-travel-and-tourism-to-GDP-percent-of-GDP#

Marcel, Vernooij. (2014, December 11). Public-Private Cooperation for Development: A Working-Together-Apart Relationship. Retrieved from: https://ecdpm.org/talking-points/public-private-cooperation-development-working-together-apart-relationship/

May Kunmakara. (2021, February 22). Exports to China gain modest 8% in 2020. Retrieved on 25th October 2021 from: https://www.phnompenhpost.com/business/exports-china-gain-modest-8-2020

Michael Firn. (2021, July 12). Full ratification of free trade deal with China is now expected early next year. Retrieved on August 15, 2021 from: https://www.khmertimeskh.com/50891934/full-ratification-of-free-trade-deal-with-china-is-now-expected-early-next-year/

Niem, Chheng. (២០១៩, ២៤ធ្នូ). Private sector urged to maintain good relations with government. ដកស្រង់ចេញពីគេហទំព័រ៖ https://www.phnompenhpost.com/national/private-sector-urged-maintain-good-relations-government

NOU SEYHA. (២០២០, ១៣សីហា). កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ជាផ្លូវនាំឲ្យកម្ពុជាឈានទៅជាប្រទេសសិង្ហបុរីទី២. ដកស្រង់ចេញពីគេហទំព័រ៖ https://www.cpp.org.kh/details/225774

ODC.COM. (2016, 15មិថុនា). គោលនយោបាយ និងការគ្រប់គ្រងវិស័យកសិកម្ម. ដកស្រង់ចេញពីគេហទំព័រ៖ https://opendevelopmentcambodia.net/km/topics/agricultural-policy-and-administration/

OECD.ORG. (nd). Services trade in the global economy. Retrieved on 23rd October, 2021 from: https://www.oecd.org/trade/topics/services-trade/

Open Development Cambodia (2015). Economy and commerce. Retrieved from : https://opendevelopmentcambodia.net/topics/economy-and-commerce/#ref-64078-13

Sangeetha Amarthalingam. (2020, 6th August). What's the deal with Cambodia and China's FTA? Retrieved from: https://www.phnompenhpost.com/special-reports/whats-deal-cambodia-and-chinas-fta

Shaun Turton. (2020, October 12). China and Cambodia sign FTA on heels of EU sanctions. Retrieved on August 5th 2021, from: https://asia.nikkei.com/Economy/Trade/China-and-Cambodia-sign-FTA-on-heels-of-EU-sanctions

Sithirith, M. (2017). Water Governance in Cambodia: From Centralized Water Governance to Farmer Water User Community. *Resources*, *6*(3), 44. https://doi.org/10.3390/resources6030044

Sorn Sarath. (2020, October 23). Free-trade deals 'not necessarily good'. Retrieved on August 15, 2021 from: https://www.khmertimeskh.com/50776237/free-trade-deals-not-necessarily-good/

Trend Economy. (2020, 15th November). Cambodia's exports 2019 by country. Retrieved from: https://trendeconomy.com/data/h2/Cambodia/TOTAL

VOA News. (២០២០, ១២តុលា). ចិនចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយកម្ពុជា ផ្តល់ជំនួយ

«ប្រញាប់»១៤០លានដុល្លារ. ដកស្រង់ចេញពីគេហទំព័រ៖
https://khmer.voanews.com/a/china-to-give-140-million-dollars-in-aid-as-it-signs-fta-with-cambodia/5618037.html

WB. ( nd ). Cambodian Agriculture in Transition: Opportunities and Risks. Retrieved on 24th October, 2021 from: https://www.worldbank.org/en/country/cambodia/publication/cambodian-agriculture-in-transition-opportunities-and-risks

Xpediator.com. ( nd ). 5 Ways to improve logistics performance. Retrieved from: https://xpediator.com/5-ways-to-improve-logistics-performance/

Zesius.com. ( nd ). 6 Important Tips for Effective Logistics Performance. Retrieved from: https://zesium.com/6-important-tips-for-effective-logistics-performance/

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន**

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) ត្រូវបានចុះហត្ថលេខាជាផ្លូវការ តាមរយៈប្រព័ន្ធវីដេអូ ដោយ **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និង **ឯកឧត្តម ចុង ស្សាន** (Zhong Shan) រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មចិន ក្រោមសក្ខីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម វ៉ាង យី** (Wang Yi) **ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន។**

ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាមានសន្តិភាពពេញលេញ និងរីកចម្រើនគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម។ ជាក់ស្តែង ដោយអនុលោមតាមអនុសាសន៍ ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា** និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដោយមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រសួងពាណិជ្ជកម្ម បានខិតខំដឹកនាំការចរចាកិច្ចព្រមព្រៀងសេរីកម្ពុជា-ចិន រហូតដល់ចប់ជាស្ថាពរក្នុងរយៈពេលមួយដ៏ខ្លី ដើម្បីទាញនូវផលប្រយោជន៍ដ៏ពេញលេញជូនកម្ពុជា។

ការចុះហត្ថលេខាថ្ងៃនេះ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយថ្មីរបស់កម្ពុជា ដោយកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរបស់ខ្លួនជាលើកដំបូងបង្អស់ ហើយកិច្ចព្រមព្រៀងទ្វេភាគីនេះទៀតសោតត្រូវបានធ្វើឡើងជាមួយមិត្តចិនដែលជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងជាពិសេសជាមិត្តដែលមានទំនាក់ទំនងប្រពៃណីដ៏យូរលង់មកហើយ។

ការពិភាក្សាលើការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន បានប្រព្រឹត្តទៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចផ្លូវការទៅកាន់រដ្ឋធានីប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២១-២៣ ខែមករា ឆ្នាំ២០១៩ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ស៊ី ជីនពីង** (Xi Jinping) **ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិត ចិន** ព្រមទាំងឥស្សរជនជាន់ខ្ពស់សំខាន់ៗមួយចំនួនទៀត។ ក្នុងឱកាសនោះ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ រដ្ឋាភិបាលនៃប្រទេសទាំងពីរបានឯកភាពគ្នាឱ្យក្រុមការងារចម្រុះចាប់ផ្តើមធ្វើការសិក្សាមួយ ដើម្បីពិនិត្យលទ្ធភាពទាំងផលចំណេញ និងបញ្ហាប្រឈមនានានៃការបង្កើតកិច្ចព្រមព្រៀងសេរីកម្ពុជា-ចិន ក្នុងការបើកបន្ថែមនូវច្រកទីផ្សារទំនិញ និងសេវាកម្ម សំដៅពង្រីកសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។ ការសិក្សារួមនេះត្រូវបានបញ្ចប់ក្នុងខែធ្នូ ឆ្នាំ២០១៩ ហើយបានដាក់ឆ្លងនីតិវិធីផ្ទៃក្នុង និងស្នើសុំការអនុម័តយល់ព្រមពីរដ្ឋាភិបាល រៀងៗខ្លួន។ ក្រុមចរចាកម្ពុជា ទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលឱ្យចាប់បើកការចរចានៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469

កិច្ចព្រមព្រៀងនេះត្រូវបានក្រុមអ្នកចរចាកម្ពុជា-ចិន បើកការចរចាជាផ្លូវការតាមកាលបរិច្ឆេទដូចខាងក្រោម៖

- កិច្ចចរចាបានចាប់ផ្តើមជាផ្លូវការលើកទី១ នៅថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២០ នៅទីក្រុងប៉េកាំង ប្រទេសចិន
- កិច្ចចរចាលើកទី២ ធ្វើនៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីដេអូ
- កិច្ចចរចាលើកទី៣ ធ្វើនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីដេអូ (ជាជុំចុងក្រោយ)

ក្រោយពីបានបញ្ចប់កិច្ចចរចាចំនួនបីជុំរួច រដ្ឋមន្ត្រីពាណិជ្ជកម្មនៃប្រទេសទាំងពីរមាន **ឯកឧត្តម ប៉ាន សូរស័ក្តិ** និង **ឯកឧត្តម ចុង ស្សាន** បានប្រកាសបិទបញ្ចប់ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្ម CCFTA នេះ ជាផ្លូវការតាមរយៈប្រព័ន្ធវីដេអូ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០។

ដោយហេតុថានៅមិនទាន់មានការថមថយនៃវិបត្តិជំងឺឆ្លងរាតត្បាតកូវីដ-១៩ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង CCFTA នេះ មិនអាចធ្វើទៅបានភ្លាមៗ ក្រោយពីការប្រកាសបិទបញ្ចប់ការចរចានោះឡើយ។ យ៉ាងណាមិញ បន្ទាប់ពីបានរង់ចាំមើលការវិវត្តន៍ជាសកលនៃវិបត្តិជំងឺឆ្លងរាតត្បាតកូវីដ-១៩ នេះដោយយកចិត្តទុកដាក់ និងដោយហេតុថាភាពមិនច្បាស់លាស់នៃជំងឺកូវីដ-១៩ នេះនៅបន្តមាន ទើបភាគីទាំងពីរបានសម្រេចចុះហត្ថលេខាលើកិច្ចព្រមព្រៀង CCFTA នេះ ក្នុងអំឡុងពេលទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តម** Wang Yi **ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋប្រជាមានិតចិន** នៅថ្ងៃនេះតែម្តង។

ជារួម កិច្ចព្រមព្រៀងសេរីកម្ពុជា-ចិន នឹងផ្តល់ផលប្រយោជន៍ជាច្រើនដល់កម្ពុជា ដូចជា៖

- ការទទួលបានការបើកទីផ្សារឱ្យបានធំជាងមុននិងប្រសើរជាងមុន សម្រាប់មុខទំនិញផលិតផលត្រីសាច់គ្រប់ប្រភេទ កសិផល បន្លែផ្លែឈើ ផលិតផលកែច្នៃនិងសិប្បកម្ម និងផលិតផលជាច្រើនទៀតស្របពេលដែលកម្ពុជាអាចផលិតបាន និងអនុលោមតាមវិធានអនាម័យ និងភូតគាមអនាម័យ
- ការទទួលបានលំហូរទីផ្សារពាណិជ្ជកម្មសេវាកម្ម ដែលកម្ពុជាអាចនាំចេញ ក្នុងករណីមានការបណ្តុះបណ្តាលជំនាញ និងមានគុណវុឌ្ឍិគ្រប់គ្រាន់ ជាពិសេសនៅពេលដែលកម្ពុជាអាចពង្រឹងខ្លួនឯងឱ្យរឹងមាំក្នុងវិស័យសេវាកម្មនាពេលអនាគត។ លើសពីនេះ កម្ពុជានឹងទទួលបានផលប្រយោជន៍ពីការប្រមូលពន្ធដារ ការទទួលបានការងារ ការទទួលបានការបណ្តុះបណ្តាលចំណេះដឹង ចំណេះធ្វើ ជំនាញពីអ្នកផ្គត់ផ្គត់សេវា និងក្រុមហ៊ុនផ្គត់ផ្គង់សេវាបរទេស ដែលជាកត្តាដ៏សំខាន់ដើម្បីពង្រឹងដល់វិស័យផលិតកម្មក្នុងស្រុក
- ការកំណត់ឱ្យកាន់តែច្បាស់នូវរាល់នីតិវិធីទាក់ទងនឹងវិធានដើមកំណើតទំនិញ នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម អនាម័យនិងភូតគាមអនាម័យ និងរបាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម និងការធ្វើសាមញ្ញកម្ម ដើម្បីងាយស្រួលអនុវត្ត និងសម្រួលដល់ការធ្វើពាណិជ្ជកម្ម និង
- ការរៀបចំនិងបង្កើតនូវបរិយាកាសវិនិយោគនិងនយោបាយទាក់ទាញវិនិយោគពីបរទេស ជាដើម។

សូមបញ្ជាក់ជូនផងដែរថា កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទ ដែលភាគីទាំងពីរបានផ្លាស់ប្តូរសេចក្តីជូនដំណឹងអំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន រួមទាំងទទួលបានការអនុម័តពីសភាជាតិនៃប្រទេសទាំងពីរ និងការឡាយព្រះហស្តលេខាផ្តល់សច្ចាប័នពីព្រះមហាក្សត្រ ឬអាចចូលជាធរមាននៅកាលបរិច្ឆេទផ្សេងពីនេះ តាមការឯកភាពរវាងភាគីទាំងពីរ។

ថ្ងៃចន្ទ ១០រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469

# ឧបសម្ព័ន្ធ២៖ បញ្ជីសំណួរសម្ភាស

| ខ្លឹមសារ៖ វិសាលភាពកិច្ចព្រមព្រៀង | | ខ្លឹមសារ៖ ឱកាសសម្រាប់កម្ពុជា | |
|---|---|---|---|
| ល.រ | សំណួរ | ល.រ | សំណួរ |
| ១ | ក្រៅពីវិស័យកសិកម្មដែលបានផ្តោតខ្លាំងជាងគេ តើកម្ពុជាអាចនាំចេញផលិតផលឧស្សាហកម្ម ឬវាយនភ័ណ្ឌផ្សេងៗទៀតបានដែរទេ ? | ១ | តើលោកគិតថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិនគឺជាឱកាសសម្រាប់កម្ពុជាដែរឬទេ ? មូលហេតុអ្វី ? ផ្អែកលើកត្តាអ្វីខ្លះ ? |
| ២ | តើកិច្ចព្រមព្រៀងថ្មីនេះ នឹងផ្តល់អត្ថប្រយោជន៍កម្រិតណាបន្ថែមពីលើកិច្ចព្រមព្រៀងអាស៊ាន-ចិនដែលមានស្រាប់ ? | ២ | ផ្អែកលើស្ថានភាពកម្ពុជាបច្ចុប្បន្ន តើលោកអ្នកគិតថា លទ្ធភាពដែលកម្ពុជាអាចចាប់យកឱកាស ឬទាញយកអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងនេះបានកម្រិតណាដែរ ? លើវិស័យអ្វីខ្លះ ? |

| ខ្លឹមសារ៖ បញ្ហាប្រឈម | | ខ្លឹមសារ៖ ដំណោះស្រាយ | |
|---|---|---|---|
| ល.រ | សំណួរ | ល.រ | សំណួរ |
| ១ | តើលោកយល់ថាកម្ពុជាអាចនឹងមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងគោលដៅទាញយកអត្ថប្រយោជន៍ជាអតិបរមាចេញពីកិច្ចព្រមព្រៀងនេះ ? | ១ | តើលោកយល់ថាកម្ពុជាត្រូវត្រៀមខ្លួនយ៉ាងណាដើម្បីធ្វើឱ្យដំណើរការអនុវត្តកិច្ចព្រមព្រៀងនេះ ទទួលបានផលប្រយោជន៍ច្រើនសម្រាប់កម្ពុជា ? |

| ខ្លឹមសារ៖ មតិនានាជុំវិញកិច្ចព្រមព្រៀង | |
|---|---|
| ល.រ | សំណួរ |
| ១ | មានមតិខ្លះយល់ថា កម្ពុជានឹងពុំទទួលបានអត្ថប្រយោជន៍បន្ថែមច្រើនទេពីកិច្ចព្រមព្រៀងថ្មីនេះ ដោយសារតែក្នុងក្របខណ្ឌអាស៊ាន កម្ពុជាទទួលបានអត្ថប្រយោជន៍ច្រើនស្រាប់ទៅហើយពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-ចិន ផ្ទុយទៅវិញ ចិនទៅវិញទេនឹងទទួលបានអត្ថប្រយោជន៍កាន់តែច្រើនដោយសារតែចិនគឺជាប៉ូលផលិតកម្ម។ តើលោកអ្នកយល់បែបណាដែរចំពោះមតិនេះ ? |

| | |
|---|---|
| ២ | ជាមួយនឹងកិច្ចព្រមព្រៀងនេះ កម្ពុជាអាចនឹងបាត់បង់ចំណូលជាពន្ធលើទំនិញនាំចូលពីចិន តើទំហំនៃការខាតបង់នេះ មានស្ថានភាពបែបណាបើធៀបនឹងផលចំណេញដែលកម្ពុជានឹងទទួលបាន? តាមពេលវេលា៖ **រយៈពេលខ្លី មធ្យម និងវែង**? |
| **អនុសាសន៍សម្រាប់កម្ពុជា** | |
| ១ | តើលោកមានអនុសាសន៍អ្វីសម្រាប់កម្ពុជាក្នុងការរៀបចំខ្លួនដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងនេះ? |
| **បញ្ជាក់៖** បញ្ជីសំណួរអាចនឹងមានភាពខុសគ្នាខ្លះៗ អាស្រ័យលើជំនាញឯកទេសរបស់វាគ្មិន | |

រក្សាសិទ្ធិដោយ

វទ្យាស្ថានមនុស្សសាស្ត្រនិងវទ្យាសាស្ត្រសង្គម